ឧស្សាហដ្ឋីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

វិស្វេនរក
ការពិត



- ឥទ្ធិពលនៃការចងចាំដែលនៅមានជីវិត៖ ការផ្សះផ្សារបួសផ្លូវចិត្តឆ្ពោះមកចេញពីសហគមន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា
- ការខឹងសម្បាខុសរឿង៖ ភាពស្មោះត្រង់ ការទទួលខុសត្រូវ និងវិជ្ជាជីវៈក្នុងកិច្ចការអន្តរជាតិ

ចែកជូនដោយឥតគិតថ្លៃជូនមន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣២១ ខែកញ្ញា ឆ្នាំ២០២៦

ឧស្សាហដ្ឋីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

មាតិកា

សំបុត្រ

- ឥទ្ធិពលនៃការចងចាំដែលនៅមានជីវិត៖ ការផ្សះផ្សារបួសដួរចិត្តឆ្ពើមចេញពីសហគមន៍..... ១
- លាតត្រដាងការបំភាន់៖ ភាពចាំបាច់នៃការ.... ២
- ការខឹងសម្បាខុសរឿង៖ ភាពស្មោះត្រង់.....៤
- ប្រតិបត្តិការសន្តិសុខ ទល់នឹងសំឡេង..... ៦
- មហាវីរកុងសង្គម លេសនៃសង្គ្រាម៖ អាវុធ.....៨

ផ្លែកឯកសារ

- ចម្លើយសារភាពម៉ែនម៉ូនីង៉ាម..... ១២
- ប៉ូច ថឹក អនុលេខាស្រុកដូនពេវ.....១៥

ផ្លែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

- ម្តាយវីរកងទ័ពចុង សុជាន់ណេ៖ ពេលនឹកកូន...១៨
- វីរកងទ័ព ទន់ សារិន៖ ការសន្យានាំ..... ២១
- ជាន់វណ្ណថា ៖ អ្នករស់រានមានជីវិតពី..... ២៤
- ហ៊ឹម ស្នា ៖ អតីតកងទ័ពក្មួង.....២៧
- ជនភៀសសឹក ដែលកំពុងរង់ចាំ ៣១
- សួន ចិន្តា៖ ផ្ទះខ្ញុំត្រូវបានដុតបំផ្លាញ..... ៣៥
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ៣៧
- អង្គការចាត់តាំងឱ្យត្បាញក្រមានៅភូមិ..... ៤០
- ជីវិតជាឧត្តមជន និងបទពិសោធន៍..... ៤២
- ខ្មែរក្រហមបង្ខំឱ្យខ្ញុំធ្វើការងាររហូតរលូតកូន... ៤៥
- អង្គការបានសម្លាប់ប្រធានភូមិ រួចជម្លៀស ...៤៧
- សើង សាវ៉ាង ៖ ក្តីសង្ឃឹម និងការដឹងគុណ...៤៩

ផ្លែកវេទិកាពិភាក្សាសាធារណៈ

- សិស្សានុសិស្សនៃអនុវិទ្យាល័យអន្ទង់វែង សួរយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម..... ៥២
- សិស្សវិទ្យាល័យ ហ៊ុនសែន កំពង់លាវ មកសិក្សាសួរយល់អំពីការបែងចែក..... ៥៤

ផ្លែកស្រាវជ្រាវរកគ្រួសារ

- ជាតិនេះ ខ្ញុំបិះតែនឹងស្លាប់ចំនួន១៨លើក (ត) .. ៥៨



ចោង ម៉ៅ អាយុ៥៩ឆ្នាំ រស់នៅភូមិអន្លង្គប្រស្រែ ឃុំអន្លង្គប្រស្រែ ស្រុកមាសហែក ខេត្តស្វាយរៀង បានផ្តល់បទសម្ភាសន៍ជាក់ទង់រឿងរ៉ាវឆ្នងកាត់របបខ្មែរក្រហម និងសុខភាពរបស់គាត់ជ្រាប់ដល់ដាត ស្ទែនពិសិដ្ឋ អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យចោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.ម.ប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

ស្មៅរលេខនេះ ៖ ឆាំង យុ, មេក វិន, ឆាវ សម្ផស្ស, កែវ សុភី, មឿន ស្រីណុច, ចាន់ណារិទ្ធ, ស៊ាង ចិន្តា, វី ស៊ីថា, ហូ លីនីត, ភី ចាន់ធូ, សិលា បញ្ញាវុធ, ស្រេង លីដា, សួត វិចិត្រ, ថុន ស្រីពេជ្រ និង សៀវ សុជុន
អ្នកនិពន្ធ និងស្រាវជ្រាវ៖ មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ុកឆ និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
ជំនួយការនិពន្ធនាយក៖ ដាវ៉ាន់ដ្ឋ មេត្តា **ក្រាហ៊ិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង ង៉ែង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

ឥទ្ធិពលនៃការចងចាំដែលនៅមានជីវិត៖
ការផ្សះផ្សារបួសផ្លូវចិត្តផ្តើមចេញពីសហគមន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា

ឆាំង យុ



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកអង្គរបុរី ខេត្តតាកែវ កំពុងអានទស្សនាវដ្តីស្វែងរកការពិត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់អាទិភាពលើវិធីសាស្ត្រអប់រំដោយចាប់ផ្តើមពីសហគមន៍ក្នុងការបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅតាមមជ្ឈមណ្ឌលសហគមន៍ចំនួន១៩របស់ខ្លួនដោយផ្តោតលើការប្រើប្រាស់បទពិសោធន៍ជីវិតពិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាជាងការពឹងផ្អែកតែមួយមុខទៅលើការផ្សព្វផ្សាយអំពីសៀវភៅសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម។

វិធីសាស្ត្រនេះគឺផ្តល់អាទិភាពជាចម្បងដល់ដំណើរជីវិតពិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ តាមរយៈការសង្កេតបឋមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា វិធីសាស្ត្រនេះបានបង្ហាញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមយល់ថា សកម្មភាពអប់រំបែបនេះមានប្រយោជន៍យ៉ាងខ្លាំងក្នុងដំណើរការជួយព្យាបាលរបួសផ្លូវចិត្តរបស់ខ្លួន។ ចំណែកឯសាធារណជន និងសិស្សានុសិស្សដែលជាអ្នកស្តាប់វិញគឺថា បទពិសោធន៍ជីវិតពិតទាំងនេះ គឺមិនត្រឹមតែផ្តល់ចំណេះដឹងអំពីអតីតកាលតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតបានជាប្រភពជំរុញការលើកទឹកចិត្ត និងការបំផុសគំនិតក្នុងការចូលរួមទប់ស្កាត់អំពើឧក្រិដ្ឋកម្មដ៏ឃោរឃៅ និងអំពើប្រល័យពូជសាសន៍នៅពេលអនាគតថែមទៀតផង។

លាតត្រដាងការបំភាន់ៈ

ភាពចាំបាច់នៃការអនុញ្ញាតឱ្យក្រុមអ្នកសង្កេតការណ៍អាស៊ាន ចូលអង្កេតដោយគ្មានការរឹតត្បិត ក្នុងតំបន់ជម្លោះព្រំដែនរវាងកម្ពុជា និងថៃ

ឆាំង យុ



រូបពីឆ្វេងទៅស្តាំៈ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក ប៉េង ហ្គីរ៉ាន់ ការស្មៀរហាន ប៉េង ហ្គីរ៉ាន់ តាហៀរ (Pengiran Kasmirhan Pengiran Tahir) ឯកអគ្គរាជទូតនៃប្រទេសប្រ៊ុយណេដារូសាឡាម ប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកស្រី សូ ហ្វារីណា នៅព្រះរាជបណ្ណាល័យហ្វង់ម៉ែ នៅឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមអ្នកសង្កេតការណ៍អាស៊ានបានចុះទៅអង្កេតទីតាំងដែលពាក់ព័ន្ធនឹងមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធអនឡាញ និងតំបន់ប្រជាជនរស់នៅដែលរងការបំផ្ទិចបំផ្លាញដោយសារជម្លោះរវាងកម្ពុជា និងថៃ។ ដូចជាអ្វីដែលគេអាចរំពឹងទុកជាមុនថា ប្រទេសថៃគឺមានបំណងយ៉ាងខ្លាំង ចង់បង្ហាញច្រាប់អំពីទីតាំងទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសកម្មភាពខុសច្បាប់ក្នុងដែនដីរបស់ខ្លួន ដើម្បីដាក់សម្ពាធលើកម្ពុជា ដែលជាប្រទេសជិតខាងរបស់ខ្លួន ដែលមានការរីកចម្រើនលឿនជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានការវិនិយោគពីបរទេសច្រើនជាងគេ ដែលមានការលូតលាស់ខ្ពស់ជាងគេ ដែលមានការកាត់បន្ថយភាពក្រីក្រលឿនជាងគេ ដែលមានការកាត់បន្ថយភាពអត់ការងារធ្វើលឿនជាងគេ ដែលមានការកាត់បន្ថយភាពអត់ធ្មេញ

ចំពោះសកម្មភាពទាហានប្រដាប់អាវុធរបស់ខ្លួនៗ ជារួម ប្រទេសថៃនិងកម្ពុជា ត្រូវតែអនុញ្ញាតឱ្យក្រុមអ្នកសង្កេតការណ៍អាស៊ានិងប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិចូលទៅកាន់គ្រប់តំបន់ទាំងអស់ដែលទទួលរងផលប៉ះពាល់ដោយសារជម្លោះដោយគ្មានការរឹតត្បិតណាមួយ។ ទន្ទឹមនឹងនេះ ក្រុមអ្នកសង្កេតការណ៍អាស៊ានិងប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិគឺមានភាពក្លាហានចុះអង្កេតតំបន់ទាំងអស់នោះ។ ការធ្វើបែបនេះគឺមិនត្រឹមតែជួយធានាតម្លាភាពអំពីព្រឹត្តិការណ៍ដែលបានកើតឡើងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចបង្ហាញឱ្យឃើញអំពីស្ថានភាពដែលកំពុងបន្តកើតមានជាក់ស្តែងនៅក្នុងតំបន់ជម្លោះទៀតផង។

ប្រទេសថៃកំពុងប្រឈមការលំបាកក្នុងការបង្ហាញហេតុផលសមស្របដើម្បីអះអាងភាពស្របច្បាប់នៃការបន្តកាន់កាប់ទឹកដីកម្ពុជា ដោយទាហានប្រដាប់អាវុធរបស់ខ្លួនជាពិសេសនៅក្នុងតំបន់ប្រជាជនរស់នៅ ដែលគ្មានកំហុសអ្វីទាល់តែសោះ។ ក្នុងបំណងដើម្បីសម្រេចគោលដៅនេះភាគីថៃគឺកំពុងតែព្យាយាមដោយចេតនាក្នុងការបំភាន់ឬបិទបាំងរូបភាពទាំងស្រុងនៃជម្លោះ ដោយផ្តល់សិទ្ធិឱ្យក្រុមសង្កេតការណ៍អាស៊ានចូលអង្កេតបានត្រឹមតែមួយផ្នែកស្ថិតនៅក្រោមការរឹតបន្តឹង និងត្រូតពិនិត្យយ៉ាងម៉ឺងម៉ាត់ពីសំណាក់ទាហានប្រដាប់អាវុធថៃ ដែលកំពុងគ្រប់គ្រងតំបន់នោះ។



លោក ប៉ែង ហ្គីរ៉ាន់ កាស្មៀរហាន ប៉ែង ហ្គីរ៉ាន់ តាហៀរ (Pengiran Kasmirhan Pengiran Tahir) ឯកអគ្គរាជទូតនៃប្រទេសប្រ៊ុយណេដារូសសាឡាម ប្រចាំព្រះរាជាណាចក្រកម្ពុជា ទស្សនកិច្ចព្រះរាជបណ្ណាល័យហ្វូនម៉ែ ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការខឹងសម្បាខុសរឿង៖
ភាពស្មោះត្រង់ ការទទួលខុសត្រូវ និងវិជ្ជាជីវៈក្នុងកិច្ចការអន្តរជាតិ

អាំង យុ



លោក អាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកអគ្គរាជទូតថៃប្រចាំប្រទេសបារាំង នីកនដេត ចាឡាំងគូ៉ាក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តើអ្វីទៅគឺជាការទទួលខុសត្រូវ ភាពស្មោះត្រង់ និងវិជ្ជាជីវៈនៅក្នុងកិច្ចការអន្តរជាតិ? តើវាគឺជាការទទួលខុសត្រូវដែរឬទេ សម្រាប់ប្រទេសមួយដែលប្រើប្រាស់កម្លាំងកងទ័ពដើម្បីមកកាន់កាប់ដែនដីរបស់ប្រទេសជិតខាង ដោយបានរំលោភលើកិច្ចព្រមព្រៀងបទឈប់បាញ់? តើវាមានក្រមសីលធម៌វិជ្ជាជីវៈដែរឬទេចំពោះប្រទេសមួយដែលបានជម្លៀសប្រជាជននៃប្រទេសជិតខាងរបស់ខ្លួន និងបង្កឱ្យមានទុក្ខវេទនាយ៉ាងធំធេងរាប់មិនអស់ដល់សហគមន៍នានា ដោយប្រើល្បិចកិច្ចកលថាគឺជាកិច្ចការទូតអន្តរជាតិនោះ? តើវាបង្ហាញនូវភាពស្មោះត្រង់ និងសុចរិតភាពដែរឬទេក្នុងការអះអាងថាព្រំដែនរបស់ប្រទេសជិតខាងគឺជាដែនដីមានវិវាទក្នុងពេលដែលសហគមន៍អន្តរជាតិ និងតុលាការអន្តរជាតិបានទទួលស្គាល់ព្រំដែនទាំងនោះ ជាច្រើនទសវត្សរ៍កន្លងមកហើយ? តើវាជាភាពស្មោះត្រង់ និងការទទួលខុសត្រូវដែរឬទេ ចំពោះប្រទេសមួយក្នុងការអះអាងថាព្រំដែនទាំងនោះ គឺមិនមានភាពយុត្តិធម៌ ទាំងដែលការកំណត់ត្រូវបានទទួលស្គាល់តាំងពីរាប់សតវត្សរ៍មកហើយ?

ឯកអគ្គរាជទូតថៃប្រចាំប្រទេសបារាំងគឺ លោក នីកនដេត ចាឡាំងគូ៉ា បានសម្តែងការខឹងសម្បាចំពោះរបាយការណ៍មួយនាពេលថ្មីៗនេះ ដែលបានចោទប្រកាន់ថា លោក (និងប្រហែលជាមន្ត្រីថៃដទៃទៀត) បានព្យាយាមប្រើឥទ្ធិពលលើការទំនាក់ទំនង និងកិច្ច

សហប្រតិបត្តិការរបស់កម្ពុជាជាមួយប្រទេសផ្សេងៗ ក្នុងគោលបំណងបញ្ចៀសមិនឱ្យដម្ងោះព្រំដែននេះ ក្លាយជាបញ្ហាអន្តរជាតិ។ លោក នឹកនដេត ជាឡាំងគួ ក៏បានច្រានចោលការចោទប្រកាន់ទាំងនោះថាគឺជាព័ត៌មានមិនពិត ដោយលើកឡើងអំពីគោលការណ៍នៃភាពស្មោះត្រង់ ការទទួលខុសត្រូវ វិជ្ជាជីវៈ និងសារសំខាន់នៃការនិយាយការពិតនៅក្នុងបញ្ហានេះ។ ទោះបីជាយ៉ាងណា មិនថាលោក នឹកនដេត ជាឡាំងគួ ក៏ មានភាពត្រឹមត្រូវច្រើនឬតិចប៉ុណ្ណាក្នុងការឆ្លើយតបទៅនឹងអត្ថបទនោះ វាគឺមិនមែនជាបញ្ហាធំបំផុតដែលស្ថិតនៅចំពោះមុខយើងក្នុងពេលនេះឡើយ។

បញ្ហាដែលសំខាន់ជាងនេះទៅទៀតគឺថាតើនរណាអាចកំណត់វាស់វែងនិយមន័យនៃភាពស្មោះត្រង់ ការទទួលខុសត្រូវវិជ្ជាជីវៈ និងការនិយាយការពិតក្នុងកិច្ចការអន្តរជាតិបានដោយរបៀបណា? ក្នុងកាលៈទេសៈដែលប្រទេសមួយកំពុងប្រើកម្លាំងកងទ័ពការពារបែនដីរបស់ប្រទេសជិតខាងខ្លួន។ គោលការណ៍នៃកាតព្វកិច្ចទទួលខុសត្រូវភាពស្មោះត្រង់ និងវិជ្ជាជីវៈ គឺមិនមែនមានដែនកំណត់ចំពោះតែសមាជិកម្នាក់ៗនៃសហគមន៍អន្តរជាតិនោះទេ ប៉ុន្តែវាគឺជាគោលការណ៍ដែលត្រូវតែពិនិត្យ និងដឹកនាំអាកប្បកិរិយារបស់រដ្ឋនានានៅក្នុងសហគមន៍អន្តរជាតិទាំងមូល ហើយវិវាទព្រំដែនទាំងស្រុងនេះ គឺជាភស្តុតាងស្តែងឱ្យឃើញអំពីការបាក់បែក និងការខកខានៃគោលការណ៍ទាំងនេះ។ ដូច្នេះហើយការខឹងសម្បារបស់ឯកអគ្គរាជទូតថៃ លោក នឹកនដេត ជាឡាំងគួ ហាក់ដូចជាខុសទិសដៅទាំងស្រុងពីបញ្ហាស្នូលដែលកំពុងកើតឡើង។



ប្រាសាទព្រះវិហារឆក់ការខូចខាតដោយសារគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែកពីកងទ័ពថៃអំឡុងខែកក្កដា និងខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រតិបត្តិការសន្តិសុខ ទល់នឹង សំឡេងរិះគន់ ថាសាធារណៈ៖ការពិតនៅពីក្រោយចេតនា

របស់ថៃមកលើមជ្ឈមណ្ឌល ឆបោកតាមប្រព័ន្ធអនឡាញនៅកម្ពុជា

អាំង ឃុយ



កងទ័ពថៃដាក់ទុក្ខតឹនរបង និងរាយលួសបន្ទាត់ទ្វេយកទឹកដីប្រទេសកម្ពុជា នៅច្រកចូលព្រំដែនភ្នំតំបន់អូរស្មាច់ ភ្នំខេត្តខ្ពតមានជ័យ។ (រូបថត៖ ក្រសួងការពារជាតិ)

ផ្អែកលើទស្សនយោធាគឺវាបង្ហាញកាន់តែច្បាស់ថា ប្រទេសថៃទំនងជាជ្រើសរើសតំបន់មួយចំនួនតែប៉ុណ្ណោះដើម្បីអនុញ្ញាតឱ្យក្រុមអ្នកសង្កេតការណ៍អាស៊ានចូលអង្កេតក្នុងគោលបំណងរក្សាការសម្ងាត់អំពីទីតាំងជាក់លាក់នៃអាវុធយុទ្ធភណ្ឌ និងការរៀបចំប្រតិបត្តិការសន្តិសុខការពាររបស់ខ្លួន។

ប្រទេសថៃទំនងជាចាត់ទុកការចុះពិនិត្យរបស់ក្រុមអ្នកសង្កេតការណ៍អាស៊ាន គឺជាកត្តាដែលអាចបង្កហានិភ័យគំរាមកំហែងដល់ប្រតិបត្តិការសន្តិសុខទាហានរបស់ខ្លួន។ ហេតុដូច្នេះហើយទើបភាគីថៃដែលយើងស្ទើរតែច្រាកដថាកំពុងរៀបចំ និងកំណត់វិសាលភាពនៃដំណើរទស្សនកិច្ចទាំងនោះយ៉ាងសម្រិតសម្រាំងបំផុត ដើម្បីកាត់បន្ថយហានិភ័យចំពោះប្រតិបត្តិការសន្តិសុខនេះ។

មជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធអនឡាញ ទំនងជាត្រូវបានប្រើប្រាស់ជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់ភាគីថៃក្នុងការបង្កើត និងផ្សព្វផ្សាយរូបភាពអវិជ្ជមានអំពីភាពពាក់ព័ន្ធរបស់កម្ពុជាចំពោះសកម្មភាពខុសច្បាប់ផ្សេងៗ។ ការបង្ហាញរូបភាពបែបនេះគឺជាកត្តាសំខាន់ក្នុងការរក្សាសុពលភាពស្របច្បាប់ ដើម្បី

ដោះសារអំពីការធ្វើសង្គ្រាមរបស់ថៃ ក្នុងពេលដែលប្រទេសថៃនៅតែអាចរក្សាបាននូវប្រតិបត្តិការសន្តិសុខរបស់ខ្លួន។

ប្រសិនបើមើលពីទស្សនៈច្បាប់វិញគឺនៅពេលដែលភាគីថៃរៀបចំបង្កើតរូបភាពចោទប្រកាន់អំពីការផ្សំគំនិត ឬការជាប់ពាក់ព័ន្ធរបស់កងកម្លាំងប្រដាប់អាវុធ និងរដ្ឋាភិបាលកម្ពុជាជាមួយសកម្មភាពខុសច្បាប់-កម្មដែលមានអង្គការចាត់តាំងកាន់តែច្រើន នឹងជួយបង្កើនអំណះអំណាងផ្លូវច្បាប់របស់ថៃឱ្យកាន់តែរឹងមាំក្នុងការប្រើប្រាស់ទាហានថៃមកជ្រៀតជ្រែកចូល ឬយ៉ាងហោចណាស់នេះគឺជាចេតនាជាក់ស្តែងដែលប្រទេសថៃព្យាយាមប្រកាន់យក។

អំណះអំណាងនេះនឹងមានទម្ងន់ខ្លាំងឬខ្សោយអាស្រ័យទៅលើភស្តុតាងដែលអាចបញ្ជាក់ថាវាគឺពិតជាមានឬក្នុងការឃុបឃិត និងទំនាក់ទំនងរវាងក្រុមខ្មែរក្រឹដ្ឋជនដែលមានអង្គការចាត់តាំងទាំងនោះ និងអង្គភាពរដ្ឋឬកងកម្លាំងយោធា។ ទោះបីជាយ៉ាងណា អំណះអំណាងនេះនឹងបាត់បង់ភាពជឿជាក់យ៉ាងខ្លាំង ប្រសិនបើមានការបង្ហាញឱ្យឃើញច្បាស់ថាសកម្មភាពខ្មែរក្រឹដ្ឋកម្មទាំងនោះគឺមិនមែនជាបញ្ហាដែលតម្រូវឱ្យប្រើប្រាស់កម្លាំងយោធានោះទេ ប៉ុន្តែអាចដោះស្រាយបានប្រសើរជាងតាមរយៈប្រតិបត្តិការបង្ក្រាបរួម ឬកិច្ចសហប្រតិបត្តិការរវាងស្ថាប័នកងកម្លាំងនគរបាលនៃប្រទេសពាក់ព័ន្ធ (ដែលជាក់ស្តែងប្រតិបត្តិការបែបនោះគឺមិនបានកើតមានឡើងទាល់តែសោះ)។



សិស្សានុសិស្សនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង មើលដែនទីប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មហារីកក្នុងសង្គម លេសនៃសង្គ្រាម៖
អាថ៌ធម្មខ្មីរនៃការបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ

ឆាំង ឃុ



ក្រុមឆបោកតាមប្រព័ន្ធអនឡាញដែលរដ្ឋាភិបាលកម្ពុជាបង្ក្រាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទោះបីជាការផ្តល់អាទិភាពដល់ការបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធអនឡាញនាពេលថ្មីៗនេះ ហាក់ដូចជាការវិវត្តមួយដ៏គួរឱ្យសាកមន៍ប៉ុន្តែតម្លៃនិងសារសំខាន់នៃកិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានបន្តុយដោយការនាំបញ្ហានេះទៅប្រើប្រាស់ក្នុងគោលបំណងនយោបាយជ្រុលហួសហេតុពេក។ សន្និសីទនាពេលខាងមុខគឺជាឱកាសដ៏ល្អមួយសម្រាប់កំណត់ទិសដៅឡើងវិញ និងស្តារកិច្ចសន្ទនាជាអន្តរជាតិលើប្រធានបទដ៏សំខាន់នេះ។

សកម្មភាពឆបោកតាមប្រព័ន្ធអនឡាញដែលមានអង្គការចាត់តាំង ព្រមទាំងបណ្តាញពាក់ព័ន្ធនឹងការឆបោក គឺស្ថិតក្នុងចំណោមទម្រង់ខ្ពើមរអើមបំផុត ព្រោះបានកេងប្រវ័ញ្ចលើក្រុមមនុស្សដែលងាយរងគ្រោះ និងជនចាស់ជរា។ លើសពីនេះ សកម្មភាពឆបោកតាមប្រព័ន្ធអនឡាញថែមទាំងបានពឹងផ្អែកយ៉ាងខ្លាំងលើការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មមនុស្សថែមទៀតផង។ រាល់សកម្មភាពឆបោកតាមប្រព័ន្ធអនឡាញ និងអង្គការចាត់តាំងដែលពាក់ព័ន្ធ គួរតែទទួលបានចំណាត់ការជាអាទិភាពបំផុតពីស្តាប័នអនុវត្តច្បាប់។ ក្នុងពេលជាមួយគ្នានេះ រដ្ឋាភិបាលនានា និងសហគមន៍អន្តរជាតិត្រូវមានការទទួលខុសត្រូវ និងធ្វើការងាររួមគ្នាដើម្បីប្រយុទ្ធប្រឆាំងជំងឺមហារីកក្នុងសង្គមនេះ ។

ទោះបីជាមានដំណោះស្រាយនិងការទប់ស្កាត់នូវរាល់សកម្មភាពខុសច្បាប់ទាំងនេះយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធអនឡាញ គឺគ្រាន់តែជាផ្នែកមួយនៃប្រព័ន្ធប្រតិបត្តិការខុសច្បាប់សកលប៉ុណ្ណោះ។ ដូច្នេះ ពិភពលោកចាំបាច់ត្រូវរៀបចំយុទ្ធសាស្ត្រលើបញ្ហានេះឱ្យបានល្អិតល្អន់ប្រុងប្រយ័ត្ន ក្នុងបរិបទនៃប្រតិបត្តិការទូលំទូលាយជាងនេះ និងគិតគូរដល់តម្រូវការប្រកួតប្រជែងផ្សេងៗដែលកំពុងប្រឈមមុខដោយស្ថាប័នអនុវត្តច្បាប់ និងអង្គការសង្គមស៊ីវិល។ ការពិពណ៌នាថា ឆបោកតាមប្រព័ន្ធអនឡាញ និងអង្គការខុសច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធគឺជាការគំរាមកំហែងធ្ងន់ធ្ងរបំផុតដល់សង្គមវាគ្រាន់តែជាទស្សនៈខ្លះការមើលឃើញឱ្យបានវែងឆ្ងាយប៉ុណ្ណោះ។ ផ្ទុយទៅវិញ ទោះបីវាគឺជាខុសច្បាប់ដ៏គួរឱ្យព្រួយបារម្ភយ៉ាងណាក៏ដោយ សកម្មភាពពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធអនឡាញ គ្រាន់តែជារោគសញ្ញាមួយនៃបញ្ហាសង្គមដែលស្ថិតក្នុងបញ្ហាផ្សេងៗទៀតមានដូចជាវិបត្តិនៃអភិបាលកិច្ចក្នុងការប្រឈមមុខនិងការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។ ក្របខណ្ឌអភិបាលកិច្ច និងការគ្រប់គ្រងនៅថ្នាក់មូលដ្ឋានថ្នាក់តំបន់ និងថ្នាក់សកល កំពុងឆ្លើយតបយឺតយ៉ាវ គ្មានប្រសិទ្ធភាព និងទទួលបានលទ្ធផលមិនគួរឱ្យពេញចិត្តចំពោះការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាដែលកំពុងជំរុញ។ ក្នុងពេលជាមួយគ្នានេះដែរ កិច្ចការទាំងនេះត្រូវបានជះឥទ្ធិពលដោយភាពបរាជ័យ និងចំណុចខ្សោយជាប្រព័ន្ធនៅគ្រប់កម្រិតនៃសង្គម។ ការផ្តោតគោលដៅលើអង្គការចាត់តាំងនិងបណ្តាញដែលប្រព្រឹត្តសកម្មភាពឆបោកតាមប្រព័ន្ធអនឡាញនានា គឺជាកិច្ចការសំខាន់មួយ។ ទោះបីជាយ៉ាងណាវាគ្រាន់តែជាវិធីសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រផ្សេងទៀតដែលចាំបាច់ត្រូវអនុវត្ត ដើម្បីដោះស្រាយឱ្យបានត្រឹមត្រូវនូវរាល់ភាពខ្វះខាតនៅក្នុងប្រព័ន្ធស្ថាប័ននិងវប្បធម៌នៅកម្រិតសកលដែលបានរួមចំណែកដល់ការពង្រីក និងការរីកចម្រើនកាន់តែស៊ីជម្រៅនៃរាល់សកម្មភាពខុសច្បាប់នៅទូទាំងពិភពលោក។

ចំណុចខ្លះខាងក្រោមដែលពាក់ព័ន្ធនឹងការផ្តោតការយកចិត្តទុកដាក់លើមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធអនឡាញនានានៅកម្ពុជានាពេលបច្ចុប្បន្ន គឺជាការនាំបទល្មើសឆ្លងដែន និងអន្តរជាតិនេះទៅប្រើប្រាស់ក្នុងគោលបំណងយោបាយដោយមិនត្រឹមត្រូវ។ គ្មានការសង្ស័យឡើយថា ប្រទេសកម្ពុជាបានប្រឈមមុខនឹងការកើនឡើងមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធអនឡាញ និងបណ្តាញខុសច្បាប់ដែលប្រតិបត្តិការនៅក្នុងព្រំដែនរបស់ខ្លួនហើយការផ្តោតការយកចិត្តទុកដាក់នាពេលថ្មីៗក្នុងការលុបបំបាត់ និងបង្ក្រាបរាល់បណ្តាញខុសច្បាប់ទាំងនេះ គឺជាកិច្ចការដ៏សំខាន់មួយ។ យ៉ាងណាមិញ ការកើនឡើងនៃមជ្ឈ-មណ្ឌលឆបោកតាមប្រព័ន្ធអនឡាញ និងជាពិសេសអង្គការខុសច្បាប់ដែលប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីពង្រីកសមត្ថភាព និងវិសាលភាពនៃសកម្មភាពរបស់ខ្លួនមិនមែនជាបញ្ហាដែលកើតមានក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះទេ។ បញ្ហានេះមិនមែនគឺជារឿងថ្មីដន្យនោះទេ ដែលការផ្តោតអារម្មណ៍នាពេលថ្មីៗនេះលើមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធអនឡាញនៅកម្ពុជាបានកើតឡើងស្របពេលជាមួយនឹងជម្លោះព្រំដែនរវាងប្រទេសថៃ និងកម្ពុជា។

ក្នុងនាមជាប្រទេសមានអធិបតេយ្យភាពប្រទេសថៃពិតជាមានដួលប្រយោជន៍ស្របច្បាប់ក្នុងការបង្ក្រាបលុបបំបាត់រាល់សកម្មភាពខុសច្បាប់ដែលកើតមាននៅក្នុង និងនៅតាមបណ្តោយព្រំដែនរបស់ខ្លួនផ្ទាល់។ យ៉ាងណាមិញ ការប្រើប្រាស់កងទ័ពរបស់ថៃនៅលើទឹកដីកម្ពុជា និងការកែប្រែយុទ្ធសាស្ត្របង្កែរសាច់រឿងឬការបកស្រាយសាធារណៈជុំវិញការប្រើប្រាស់កងទ័ពបានបង្ហាញយ៉ាងច្បាស់ថា នៅពីក្រោយសកម្មភាពទាំងនេះគឺមានគោលបំណងផ្សេងទៅវិញទេក្រៅពីការអនុវត្តច្បាប់ដែលត្រូវបាននិងកំពុងតែបន្តអនុវត្ត។ ស្ថានភាពនេះត្រូវបានបង្ហាញកាន់តែច្បាស់ទៀតតាមរយៈការបន្តកាន់កាប់ទឹកដីកម្ពុជា

ពីសំណាក់កងទ័ពថៃ។ ជាជាងការឆ្លើយតបស្របច្បាប់ចំពោះបញ្ហាខ្ញុកខ្ញិដ្ឋកម្ម ឬការគំរាមកំហែងពិតប្រាកដដល់សន្តិសុខជាតិ ភាគីថៃបានប្រើប្រាស់មជ្ឈមណ្ឌលឆោកតាមប្រព័ន្ធអនឡាញនៅក្នុងទឹកដីកម្ពុជា ជាលេសដើម្បីបង្ហាញអំពីភាពត្រឹមត្រូវក្នុងការកាន់កាប់ទឹកដីកម្ពុជា ដែលខ្លួនបានព្យាយាមចង់បានយកមកគ្រប់គ្រងអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ។ មជ្ឈមណ្ឌលឆោកតាមប្រព័ន្ធអនឡាញ មិនមានវត្តមាននៅក្នុងតំបន់ប្រាសាទព្រះវិហារឡើយ ប៉ុន្តែកងកម្លាំងប្រដាប់អាវុធថៃបានធ្វើប្រតិបត្តិការយោធានៅក្នុងតំបន់នេះ ព្រមទាំងនៅតាមតំបន់ប្រាសាទបុរាណជាទីសក្ការៈរបស់កម្ពុជាជាច្រើនទីតាំងៗបន្ថែមពីនេះ កងទ័ពថៃបានចូលកាន់កាប់ទ្រព្យសម្បត្តិរបស់ជនស៊ីវិល និងបានបង្ខំប្រជាជនកម្ពុជារាប់ពាន់នាក់ឆ្ងាស់ទីលំនៅដោយខុសច្បាប់ទៀតផង ដែលសកម្មភាពទាំងអស់នេះមិនអាចភ្ជាប់ ឬបង្ហាញភាពសមហេតុផលត្រឹមត្រូវដោយយោងទៅលើការអនុវត្តច្បាប់ ឬការការពារសន្តិសុខជាតិបានឡើយ។ សរុបមក សកម្មភាពទាំងនេះហាក់ដូចជាបង្ហាញអំពីគោលបំណងបង្កើត ឬកំណត់ព្រំដែនតាមរយៈការប្រើប្រាស់កម្លាំងកងទ័ពហើយប្រទេសថៃមិនប្រាកដថាអាចការពារខ្លួនបានតាមរយៈតុលាការអន្តរជាតិ ឬការទូត។

ការឆោកតាមប្រព័ន្ធអនឡាញ គឺពិតជាបញ្ហាខ្ញុកខ្ញិដ្ឋកម្មដ៏ធ្ងន់ធ្ងរដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងការឆ្លើយតបយ៉ាងម៉ឺងម៉ាត់។ ទោះបីជាយ៉ាងណា នៅពេលដែលការឆោកតាមប្រព័ន្ធអនឡាញ ត្រូវបានយកទៅប្រើប្រាស់ជាលេសដើម្បីបម្រើរបៀបវារៈ ឬគោលបំណងផ្សេងក្រៅពីការដោះស្រាយបញ្ហានោះយើងកំពុងតែបំផ្លាញ ទំនុកចិត្ត និងសុចរិតភាព ដែលជាកត្តាចាំបាច់បំផុតសម្រាប់និរន្តរភាពនៃសណ្តាប់ធ្នាប់អន្តរជាតិ។ លើសពីនេះទៅទៀត យើងកំពុងបន្តែមភាពគ្មានប្រសិទ្ធភាព និងការបង្កែរបំណាប់អារម្មណ៍ដោយហេតុដលនយោបាយ ទៅលើបញ្ហាប្រឈមដ៏ស្មុគស្មាញ និងពិបាកដោះស្រាយ ដែលសហគមន៍អន្តរជាតិកំពុងប្រឈមមុខ។

បញ្ហាប្រឈមនានារបស់ពិភពលោកនាពេលបច្ចុប្បន្ន បានក្លាយទៅជាបញ្ហាដែលមានភាពស្មុគស្មាញ ប្រែប្រួលឥតឈប់ឈរ និងពិបាកព្យាករណ៍ទុកជាមុនខ្លាំងពេកហួតដល់យើងមិនត្រូវទុកឱ្យភាពគ្មានប្រសិទ្ធភាព ការបែកបាក់ និងការបង្កែរបំណាប់អារម្មណ៍ដោយហេតុដលនយោបាយកើតមានឡើងនោះឡើយ។ សកម្មភាពខ្ញុកខ្ញិដ្ឋកម្មនានា តែងតែរីកលូតលាស់ និងសាយភាយនៅក្នុងប្រព័ន្ធអភិបាលកិច្ចដែលមានភាពទន់ខ្សោយ ខ្វះប្រសិទ្ធភាព និងមានភាពបែកបាក់។

សកម្មភាពទាំងឡាយណាដែលផ្តោតទៅលើការបង្ក្រាបនិងទប់ស្កាត់បណ្តាញខ្ញុកខ្ញិដ្ឋកម្មទាំងនេះអាចនាំមកនូវលទ្ធដលវិជ្ជមាន។ ប៉ុន្តែលទ្ធដលវិជ្ជមានទាំងនោះ នឹងអាចស្ថិតស្ថេរយូរអង្វែងបាន លុះត្រាតែត្រូវបានកសាងឡើងលើមូលដ្ឋាននៃយុទ្ធសាស្ត្រដែលបានគិតគូរច្បាស់លាស់ និងភាពជាដៃគូដ៏រឹងមាំ។ ផ្ទុយទៅវិញ សកម្មភាពទាំងឡាយណាដែលត្រូវបានអនុវត្តក្នុងគោលបំណងសម្រេចរបៀបវារៈ ឬគោលដៅផ្សេងៗដែលមិនពាក់ព័ន្ធនឹងវត្ថុបំណងស្របច្បាប់នៃការអនុវត្តច្បាប់។ សកម្មភាពនោះគឺមិនត្រឹមតែបំផ្លាញកិច្ចខិតខំប្រឹងប្រែងរួម ដើម្បីដោះស្រាយបញ្ហានេះប៉ុណ្ណោះទេប៉ុន្តែថែមទាំងធ្វើឱ្យប៉ះពាល់ដល់សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើបញ្ហាផ្សេងៗថែមទៀតផង។ បញ្ហានេះគឺកាន់តែគួរឱ្យព្រួយបារម្ភថែមទៀត ខណៈដែលសហគមន៍អន្តរជាតិកំពុងតែប្រឈមមុខនឹងស្ថានភាពខ្វះការប្តេជ្ញាចិត្តគ្រប់គ្រាន់ ខ្វះធនធាន និងនៅតែមិនទាន់មានការត្រៀមខ្លួនបានល្អប្រសើរ សម្រាប់ប្រឈមមុខនឹងបញ្ហាដ៏ស្មុគស្មាញនានានៅសតវត្សរ៍ទី២១ នេះ។

សន្និសីទអន្តរជាតិស្តីពី«ការប្រយុទ្ធប្រឆាំងនឹងការឆោកតាមប្រព័ន្ធអនឡាញ» ដែលគ្រោងនឹង

ប្រព្រឹត្តទៅនៅថ្ងៃទី២៣-២៤ ខែកញ្ញា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ គឺជាឱកាសដ៏សំខាន់មួយសម្រាប់ការកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការនាពេលអនាគតរវាងបណ្តាប្រទេសនានា ស្តាប់ធនអនុវត្តច្បាប់ និងអង្គការសង្គមស៊ីវិល លើប្រធានបទដ៏សំខាន់នេះ។


ព្រឹត្តិការណ៍នេះផ្តល់នូវឱកាសដ៏ប្រសើរមួយសម្រាប់ការពិភាក្សាអំពីទិដ្ឋភាពផ្សេងៗនៃសកម្មភាពខុសច្បាប់ផ្សេងៗ និងការចែករំលែកគំនិតស្តីពីវិធីសាស្ត្រ និងដំណោះស្រាយថ្មីៗក្នុងការឆ្លើយតបចំពោះបញ្ហានេះ។ អនាគតរបស់ពិភពលោកពឹងផ្អែកលើភាពរឹងមាំនៃភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការដែលយើងកសាងឡើងនៅថ្ងៃនេះ។ ខ្ញុំមានសេចក្តីសង្ឃឹមថា នឹងមានការស្តារកិច្ចសន្ទនាឡើងវិញរវាងរដ្ឋាភិបាលនានា ជាពិសេសរវាងកម្ពុជា និងថៃ ដើម្បីស្វែងរកមិនត្រឹមតែវិធីដោះស្រាយវិវាទដែលបានបន្តអូសបន្លាយអស់ជាច្រើនសតវត្សរ៍តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីប្រឈមមុខ និងដោះស្រាយបញ្ហារួមដែលប្រទេសទាំងពីរកំពុងជួបប្រទះថែមទៀតផង។



កងទ័ពថៃរាយលួសបន្ទាត់ទ្វេយកទឹកដីប្រទេសកម្ពុជានៅតំបន់ថ្មដា ស្រុកភ្នំលៀង ខេត្តពោធិ៍សាត់ ដោយយកលេសថាជាកន្លែងប្រព្រឹត្តអំពើឆបោកតាមអនឡាញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចម្លើយសារភាព ម៉ែន ម៉ូនីដាម អំពីខ្សែបណ្តាញ កា-ហ្សេ-បេ នៅប្រទេសសូវៀត

មីន សាណាស់



ឯកសារប្រវត្តិរូប ម៉ែន មូនីដាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ ខុចបានសរសេរចំណាលើឯកសារចម្លើយសារភាពលើកទី៣ របស់ ម៉ែន ម៉ូនីដាំម អតីតនិស្សិតរៀននៅប្រទេសសូវៀត ផ្ញើជូនទៅអង្គការថ្នាក់លើ។ នៅក្នុងចម្លើយសារភាព ម៉ែន ម៉ូនីដាំម បាននិយាយអំពីឈ្មោះ អៀង សីហា គឺជាភ្នាក់ងារ កា-ហ្សេ-បេ ស្ថិតក្នុងខ្សែរបស់ ហាក់ សៀង ឡាយនីនិង ប៉ែន ថោង អាន។ ខាងក្រោមនេះគឺជាប្រវត្តិរូបសង្ខេបរបស់ ប៉ែន ថោង អាន អាយុ៣៦ឆ្នាំ (១៩៧៦) គឺជានិស្សិតពេទ្យ និងភ្នាក់ងារ កា-ហ្សេ-បេ ដែលមាននៅក្នុងចម្លើយសារភាព ម៉ែន ម៉ូនីដាំម៖

នៅឆ្នាំ១៩៥៨ ខ្ញុំបានស្គាល់ ប៉ែន ថោង អាន នៅវិទ្យាល័យស៊ីសុវត្ថិ ប៉ុន្តែនៅពេលនោះ ថោង អាន មិនបាននិយាយទាក់ទងរឿងនយោបាយឡើយ។ នៅឆ្នាំ១៩៦០ ប៉ែន ថោង អាន បានប្រឡងបញ្ចប់ថ្នាក់នៅវិទ្យាល័យស៊ីសុវត្ថិ នៅទីក្រុងភ្នំពេញ និងបានទទួលអាហារូបករណ៍ទៅរៀនបន្តខាងវិជ្ជាពេទ្យនៅសហភាពសូវៀត។

នៅឆ្នាំ១៩៦២ ឈ្មោះ ហាក់ សៀង ឡាយនី និស្សិតខាងទំនប់ទឹក និងជាមពលអគ្គិសនី ដែលកំពុងរស់នៅក្រុងគៀវ រដ្ឋធានីរបស់សាធារណរដ្ឋអ៊ុយក្រែន បានមកជួបជាមួយ ប៉ែន ថោង អាន នៅទីក្រុងមូស្គូសហភាពសូវៀត។

នៅឆ្នាំ១៩៦៣ ខ្ញុំបានជួបជាមួយ ហាក់ សៀង ឡាយនី ដែលមករកខ្ញុំដល់បន្ទប់ស្នាក់នៅនិស្សិតពេទ្យ ដែលស្ថិតនៅជិតសមុទ្រខ្មៅ និងទីក្រុងមូស្គូ។ ហាក់ សៀង ឡាយនីបានសួរនាំខ្ញុំអំពីជីវភាពរស់នៅប្រចាំថ្ងៃការរៀនសូត្រ និងឱ្យខ្ញុំទាក់ទងជនជាតិរុស្ស៊ីម្នាក់ដែលអាចជាទីពឹងពាក់បានឈ្មោះ អ៊ីវណូវ។ អ៊ីវណូវ គឺជាភ្នាក់ងារ កា-ហ្សេ-បេ និងមានផ្ទះនៅក្នុងទីក្រុងមូស្គូ។ សៀង ឡាយនីបានប្រាប់ខ្ញុំថា កាលពីខែវិច្ឆិកា ឆ្នាំ១៩៦២ បានបញ្ជូន ប៉ែន ថោង អាន ឱ្យទៅជួប អ៊ីវណូវ ដើម្បីចូលជាភ្នាក់ងារ កា-ហ្សេ-បេ។ ក្រោយមក រំលងបានពីរសប្តាហ៍ ប៉ែន ថោង អាន បានមកជួបខ្ញុំដល់បន្ទប់ស្នាក់នៅ ក្នុងគោលបំណងបបួលខ្ញុំទៅចូលរួមប្រជុំនៅបន្ទប់ស្នាក់នៅកូនសិស្សរបស់

ហាក់ សៀង ឡាយនី។ ពេលខ្ញុំទៅដល់បន្ទប់ប្រជុំ ឃើញមានប្រធានអង្គប្រជុំជាភ្នាក់ងារ កា-ហ្សេ-បេ និងមានឈ្មោះ ហាក់ សៀង ឡាយនី (ជាម្ចាស់បន្ទប់), ប៉ែន ចោងអាន, អៀង សីហា គឺជានិស្សិតផ្នែកសំណង់ស្ពាន, ឡោ ជិនហុង គឺជានិស្សិតផ្នែកគណិតសាស្ត្រ និងខ្ញុំផ្ទាល់។ ការហៅមកប្រជុំលើកនេះគឺគ្រាន់តែចង់ណែនាំនិស្សិតមកពីប្រទេសកម្ពុជាឱ្យបានស្គាល់គ្នា ដើម្បីងាយស្រួលទាក់ទងគ្នាបន្តទៅថ្ងៃមុខ។

នៅឆ្នាំ១៩៦៨ ប៉ែន ចោងអាន និង ហាក់ សៀង ឡាយនីបានខិតខំធ្វើការយកចិត្តទុកដាក់ជាមួយខ្ញុំក្នុងគោលបំណងឱ្យខ្ញុំបំពេញការកិច្ចរួមឱ្យបានលទ្ធផលល្អ។ ក្រៅពីនោះ ប៉ែន ចោងអាន និង ហាក់ សៀង ឡាយនី បានដើរទាក់ទងនិស្សិតខ្មែរឱ្យចូលធ្វើជាភ្នាក់ងារ កា-ហ្សេ-បេ បន្ថែមទៀតមានដូចជាឈ្មោះ ហេង, សៀង និង ក្រែន លាន គឺជានិស្សិតនៅសាលាចាមពលអគ្គិសនី និងទំនប់ទឹក (រស់នៅបរទេស)។ សកម្មភាពក្នុងឆ្នាំ១៩៦៨ គឺដើរទាក់ទងរកខ្មែរយ:ដ្យុំគំនិតថ្មីឱ្យបានច្រើនប៉ុន្តែនៅក្នុងប្រទេសកម្ពុជា គឺលេចឮដំណឹងថា រាជរដ្ឋាភិបាលលែងបញ្ជូននិស្សិតខ្មែរឱ្យមកសិក្សានៅប្រទេសសូវៀតហើយ។

នៅឆ្នាំ១៩៦៩ សកម្មភាពដើរទាក់ទាញកម្លាំងថ្មីស្រាកស្រាន្តបន្តិច ហេតុនេះ ប៉ែន ចោងអានបានទុកពេលវេលាច្រើនសម្រាប់ជជែកគ្នាពីរឿងនយោបាយនៅក្នុងប្រទេសកម្ពុជាវិញ។ ពេលពិភាក្សាគ្នានៅក្នុងអង្គប្រជុំ សមាជិកមួយចំនួនលើកយកដែនការទូទៅពេលត្រឡប់មកប្រទេសកម្ពុជា ដើម្បីយកអំណាចពីសង្គមរាស្ត្រនិយម ដែលជាគណបក្សតែមួយនៅក្នុងប្រទេស។ ដូច្នេះ កម្លាំងទាំងអស់ត្រូវខិតខំឱ្យបានឈរជាបេក្ខជនតំណាងរាស្ត្រ។ ពេលបានជាប់ជាបេក្ខជនតំណាងរាស្ត្រដែលមានសំឡេងច្រើនគឺអាចកែប្រែច្បាប់រដ្ឋឱ្យមកតាមលំនាំនយោបាយដែលសមាជិកត្រូវការ។

នៅឆ្នាំ១៩៦៦ ខ្ញុំផ្លាកសកម្មភាពជាមួយ ប៉ែន ចោងអាន និង ហាក់ សៀង ឡាយនី ប៉ុន្តែខ្ញុំមកទាក់ទងជាមួយឈ្មោះ ស្ងាវ គឺជាជនជាតិរុស្សីដែលរស់នៅជាមួយខ្ញុំនៅផ្ទះនិស្សិត។

នៅឆ្នាំ១៩៦៧ ស្ងាវ បាននាំខ្ញុំទៅជួបឈ្មោះ វ៉ី គឺជនជាតិរុស្សីម្នាក់ទៀតដែលរស់នៅក្នុងផ្ទះនិស្សិតជាមួយគ្នា និងជាអ្នកដឹកនាំ កា-ហ្សេ-បេ ផ្នែកផ្ទះនិស្សិត។ នៅក្នុងឆ្នាំនេះដែរ ខ្ញុំ និង ប៉ែន ចោងអាន បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ ពេលមកដល់កម្ពុជា ក្រសួងសុខាភិបាលមិនទទួលស្គាល់សញ្ញាបត្រផ្នែកពេទ្យរបស់ខ្ញុំទេ។ ហេតុនេះ ប៉ែន ចោងអាន បាននាំខ្ញុំ និងពេទ្យនារីពីរនាក់ទៀតឈ្មោះ អ៊ឹង វ៉ាត់ឃីវ និង តាត ចាន់សាវី ធ្វើការតវ៉ាសុំចូលក្របខណ្ឌ។ ក្រោយមក ក្រសួងអនុញ្ញាតឱ្យខ្ញុំទាំងបួននាក់ចូលធ្វើការនៅមន្ទីរពេទ្យសូវៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឈ្មោះ អ៊ុន សូកាន ពេទ្យផ្នែកជំងឺរបេង។

នៅខែឧសភា ឬ មិថុនា ឆ្នាំ១៩៦៨ ខ្ញុំ, ប៉ែន ចោងអាន, អ៊ឹង វ៉ាត់ឃីវ និង តាត ចាន់សាវី ត្រូវរដ្ឋការលន់ នល់ ចោទប្រកាន់ពីបទប្រឆាំងនឹងរដ្ឋាភិបាល។ ជាពិសេស ប៉ែន ចោងអាន ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការសឹក និងខាងប៉ូលីសពិសេស។ ឃើញដូច្នេះ ក្រុមនិស្សិតដែលរស់នៅប្រទេសសូវៀត និងជាប់ខ្សែទាក់ទងជាមួយ ប៉ែន ចោងអានមិនហ៊ានវិលត្រឡប់មកប្រទេសកម្ពុជាទេ។

នៅឆ្នាំ១៩៦៩ ប៉ែន ចោងអាន ត្រូវអង្គភាពផ្ញាស់ឱ្យទៅធ្វើការផ្នែកឱសថស្ថាន នៅខាងតាខ្មៅ។ ក្រោយរដ្ឋប្រហារ ឆ្នាំ១៩៧០ ប៉ែន ចោងអានបានឱយប្រាប់ខ្ញុំថា បានចូលរួមបម្រើក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ទៅតាមសេចក្តីប្រកាសរបស់វិទ្យុប៉េកាំង។

នៅឆ្នាំ១៩៧៣ ប៉ែន ចោងអានបានទទួលការខបត្តម្ភពីគណ:កម្មាធិការទន្ទេមេគង្គ ទៅរៀនភាសាអង់គ្លេសនៅប្រទេសថៃ។ បន្ទាប់មកខ្ញុំទទួលដំណឹងថាក្រសួងសុខាភិបាលហៅពេទ្យថ្មីៗដែលមកពីប្រទេសសូវៀតឱ្យទៅបម្រើជាការហានចំនួន១៨ខែ។

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៣ ដោយខ្ញុំគ្មានបានទទួលអាហារូបករណ៍នៅប្រទេសបារាំង ហេតុនេះខ្ញុំត្រូវតែធ្វើការងារយាមក្នុងមន្ទីរពេទ្យនៅពេលយប់។


ចំណែក ប៉ែន ចោង‌អាន មានការខឹង‌ក្តៅក្រហាយ ព្រោះសុំឱ្យប្រពន្ធចេញមកក្រៅប្រទេសមិនបាន ដោយសារអាជ្ញាធរខ្មែរធ្វើការឃាត់ឃាំង។

នៅឆ្នាំ១៩៧៥ ខ្ញុំបានជាប់ដំណឹង ប៉ែន ចោង‌អាន ជាច្រើនខែរហូតដល់បានទទួលសំបុត្រមកពីអាមេរិក ថា ប៉ែន ចោង‌អាន នៅរៀនផ្នែកអនាម័យ និង‌ក្លួន ចាត់ចែង‌ផ្នែកសុខាភិបាលនៅអាមេរិក ដោយទទួលបានអាហារូបករណ៍ពីគណៈកម្មាធិការទន្លេមេគង្គ។ នៅពេលរៀនសូត្រ ប៉ែន ចោង‌អាន មិនដែលរអ៊ូ ថាខ្លួនមានការខុះខាតអ៊ីឡើយ។ រហូតដល់ក្រោយថ្ងៃរំដោះ ប៉ែន ចោង‌អាន បានផ្ញើសំបុត្រមួយច្បាប់ទៀត សួរថា តើមានជម្លៀសប្រជាជនចេញពីក្រុង ភ្នំពេញដែរឬទេ? ចំណែកខ្ញុំនៅប្រទេសបារាំង គឺបានត្រឹមតែអានការសែត ហេតុនេះខ្ញុំឆ្លើយតបថា មិនទាន់ដឹង‌ច្បាស់ដង‌ឡើយ។ អស់រយៈពេលជាច្រើនខែកន្លង‌ផុតទៅ ខ្ញុំបានទទួលដំណឹង‌ពីគណៈកម្មាធិការអ្នកស្នេហាជាតិខ្មែរ នៅប្រទេសបារាំង ស្តីពីការជម្លៀសប្រជាជនចេញពីភ្នំពេញប្រកបដោយរបៀបរៀបរយ។ ពេលដឹង‌ដំណឹង‌នេះភ្លាម ខ្ញុំបានសរសេរសំបុត្រទៅជ្រាប់ ប៉ែន ចោង‌អាន ភ្លាម។ ក្រោយពីទទួលបានសំបុត្ររួច ប៉ែន ចោង‌អាន មានបំណង‌ចង់វិលចូលមកប្រទេសកម្ពុជាវិញ។ ខ្ញុំបានឱ្យយោបល់ថា បើមានការពិបាក ពេលមកដល់ប្រទេសបារាំង អាចមកនៅផ្ទះខ្ញុំរង់ចាំទម្រាំបានទទួលសេចក្តីអនុញ្ញាតឱ្យចូលប្រទេសកម្ពុជាវិញ។

នៅខែមេសា ឆ្នាំ១៩៧៦ ប៉ែន ចោង‌អាន បានមកដល់ទីក្រុង‌ប៉ារីស ប្រទេសបារាំង និង‌មកស្នាក់អាស្រ័យនៅផ្ទះខ្ញុំ។ ខ្ញុំធ្វើការរាក់ទាក់ ប៉ែន ចោង‌អាន ព្រោះជាមិត្តភក្តិ ដែលធ្លាប់ជាប់គុកនៅព្រៃសជាមួយគ្នាភ្លង‌ឆ្នាំ១៩៦៨។ បន្ទាប់មកខ្ញុំបានជូន ប៉ែន ចោង‌អាន ទៅដាក់ពាក្យស្នើសុំមកប្រទេសកម្ពុជា តាមរយៈបេសកកម្មទូតរបស់របបបរណាសិរ្សរួបរួមជាតិកម្ពុជា នៅប្រទេសបារាំង។ ទីតាំង‌បេសកកម្មទូត គឺមានភារកិច្ចទទួលពាក្យ និង‌បញ្ជូនពាក្យសុំមកប្រទេសកម្ពុជាវិញតែប៉ុណ្ណោះ។ រហូតដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៦ ប៉ែន ចោង‌អាន បានត្រឡប់ចូលមកដល់ភ្នំពេញ។ នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ ស្ថិតនៅភ្នំពេញ ខ្ញុំបានសួរនាំមិត្តភក្តិដែលទទួលខុសត្រូវភ្នាក់ង‌ារទទួលនិស្សិតមកពីបរទេស ទើបទទួលបានដំណឹង‌ថា ប៉ែន ចោង‌អាន កំពុងរស់នៅមុំស៊ឹង‌មានជ័យ។

បើតាមឯកសារតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ែន ម៉ូនីង‌ាម កើតនៅឃុំកំពង់លាវ ខេត្តព្រៃវែង មានឪពុកឈ្មោះ ម៉ែន ឈុំ និង‌ម្តាយឈ្មោះ ម៉ី សារៀម។ ម៉ូនីង‌ាម មានប្រពន្ធឈ្មោះ អ៊ីវ រាត់ឈីវ និង‌កូនប្រុសចំនួន៣នាក់។ ម៉ូនីង‌ាម ត្រូវបានយាត់ខ្លួននៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ នៅប្រទេសកម្ពុជា។

កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្ងាយសារភាពលេខ J00២៩៦ និង I១០៧២០។ រាល់ចម្ងាយសារភាពរបស់អ្នកទោសទាំង‌អស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លង‌កាត់ការបង្ខិតបង្ខំ និង‌ធ្វើទារុណកម្ម យ៉ាង‌ធ្ងន់ធ្ងរពីកង‌សួរចម្ងាយរបស់ខ្មែរក្រហម។ ដូច្នេះយើង‌មិនអាចសន្និដ្ឋានបានថា ចម្ងាយសារភាពរបស់ ម៉ែន ម៉ូនីង‌ាម ពិតប្រាកដឬយ៉ាង‌ណានោះទេ។



អតីតមន្ទីរសន្តិសុខស-២១ បុគ្គលទួលស្វែង នៅភ្នំង‌របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។
(ប៉ណ្ណាសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ូច ថឹក អនុលេខាស្រុកដូនពេញ

រមេក ទិន



យុទ្ធនារីកម្មករបដិវត្តន៍នៅពោធិចក្រដលិតជាវ ដូនពេញវ ក្នុងតំបន់បាត់ដំបង កំពុងបញ្ជាម៉ាស៊ីនដេរជាវ ទុកដាល់ទៅសហករណ៍ដើម្បីដាក់ស្រូវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ូច ថឹក ហៅ គឿម ភេទប្រុស អាយុ៣៩ឆ្នាំ មានគ្រួសារហើយ។ ថឹក មានស្រុកកំណើតនៅភូមិ ឫស្សីព្រៃ ឃុំគាស់ក្រឡ ស្រុកមោង តំបន់៤។

ថឹក បានរៀបរាប់ថា ចាប់តាំងពីធំដឹងក្តីមក ខ្ញុំរស់នៅជាមួយឪពុកម្តាយ និងធ្វើស្រែ។ រហូតដល់ឆ្នាំ១៩៥៣ ខ្ញុំបានបួសរៀននៅក្នុងវត្តឆ្នាល់មាន់ ឃុំគាស់ក្រឡ។ នៅចន្លោះឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៣ ខ្ញុំបានសឹក និងត្រឡប់មកផ្ទះដើម្បីជួយធ្វើស្រែឪពុកម្តាយវិញ។ នៅក្នុងឆ្នាំ១៩៦៣ ខ្ញុំបានទាក់ទងជាមួយឈ្មោះ មានហៅ សារិកា នៅភូមិជាមួយគ្នាដើម្បីចូលបម្រើបដិវត្តន៍។ អ្នកធ្វើការជាមួយ សារិកា មានឈ្មោះ ចែត (អតីតអ្នកតស៊ូចាស់) និងឈ្មោះ អ៊ិន (អតីតអ្នកតស៊ូនៅជំនាន់បារាំង) ក្រោយមកគាត់ធ្វើជាតណៈឃុំឆ្នាល់មាន់ ស្រុកមោង។

នៅឆ្នាំ១៩៦៤ ឈ្មោះ ចែត បានអប់រំខ្ញុំឱ្យឃើញបដិវត្តន៍ខ្មៅងងឹតដោយលើកឡើងថាបដិវត្តន៍បំផ្លាញជាតិ និងធ្វើខ្ញុំបម្រើបរទេស។ ភាពជិតស្និទ្ធស្នាល និងការអប់រំនេះមានជាបន្តបន្ទាប់រហូតដល់ចុងឆ្នាំ ១៩៧៤ ចែត បានបញ្ជូលខ្ញុំជា សេ.អ៊ុ.អា ដោយមានឈ្មោះ អ៊ិន ទទួលស្គាល់ និងឈ្មោះ សារិកា ជាអ្នកដឹងឮ។ កាលនោះ អ្នកដែលចូល សេ.អ៊ុ.អា ជាមួយខ្ញុំមានឈ្មោះ បើយ ហ៊ោ:។ បន្ទាប់ពីខ្ញុំចូលសេអ៊ុអារួច ខ្ញុំមានការកិច្ច ទីមួយ) បង្កប់ខ្លួនដើម្បីបំផ្លាញបដិវត្តន៍ គឺទាំងកម្ចាំង និងទាំងមាគ៌ាបក្ស។ ទីពីរ)

បំបែកកម្លាំងបដិវត្តន៍ និងកសាងកម្លាំង សេ.អ៊ី.អា។ ទីបី) បំផុសប្រជាជនឱ្យស្អប់ និងមិនចូលរួមជាមួយបដិវត្តន៍។ ក្រោយមកឈ្មោះ អ៊ិនបានចាត់តាំងខ្ញុំឱ្យទាក់ទងខ្សែរបស់គាត់ពីរនាក់ មានឈ្មោះ ចន និងណឹម ដើម្បីរួមសកម្មភាពបំផុសនិងចលនាប្រជាជនឱ្យស្អប់របបខ្មែរក្រហម។ នៅចន្លោះឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៥ ខ្ញុំកសាងកម្លាំងបានចំនួន១២នាក់។ កម្លាំងទាំងអស់ដែលខ្ញុំកសាងបាន ខ្ញុំបានប្រគល់ទៅឱ្យ សារិកា អប់រំបន្តែម និងត្រៀមដាក់បង្គុំបក្ខងបដិវត្តន៍។

នៅក្នុងឆ្នាំ១៩៦៥ បដិវត្តន៍បំផុសប្រជាជនឱ្យធ្វើបាតុកម្មនៅតាស់ក្រ ឡពេលខ្លាំងចូលមករាតត្បាត ហើយកម្លាំងបដិវត្តន៍មួយចំនួនបានរត់ចូលព្រៃ។ អំឡុងពេលនោះ ខ្ញុំរួមទាំង ចែត, សារិកា និង អ៊ិនបានបន្ទំខ្លួនរត់ចូលព្រៃបុស្សចេកក្នុងស្រុកមោងបង្គុំបធ្វើជាជនបដិវត្តន៍ដែរ។ នៅចុងឆ្នាំ១៩៦៥ សារិកាចាត់តាំងគឿមឱ្យនាំឈ្មោះណឹម, ហ៊ាំ:, គឿ, វុិច, ហម និងញឹមកនៅក្នុងភូមិបុស្សីព្រៃ ស្របពេលអង្គការឱ្យកម្លាភិបាលបដិវត្តន៍ត្រឡប់មកធ្វើការក្នុងភូមិវិញ។ ការធ្វើបែបនេះគឺដើម្បីបំបែកកម្លាំងបដិវត្តន៍នៅក្នុងភូមិ ដោយបានចាត់តាំងឱ្យកម្លាំងចំនួន៥នាក់ដើរតាមដានសកម្មភាពបដិវត្តន៍ និងប្រជាជនដែលលួចយកអង្គរចូលក្នុងព្រៃ ដើម្បីទៅប្រាប់ប៉ុស នៅឆ្នាល់មាន់ និងឈ្មោះស្រ៊ុន ដើម្បីនាំទាហានមកចាំចាប់។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ អង្គការបែងចែកកម្លាំងចាស់ៗនៅក្នុងស្រុកតាស់ក្រឡតំបន់១ ចំណែកខ្ញុំនិងមេឃុំត្រូវទៅនៅក្នុងស្រុកដូនទ្រីតំបន់៨ ដូច្នេះខ្ញុំមិនបានទាក់ទងខ្សែចាស់ៗទៀតទេ។ ក្នុងខែឧសភាឆ្នាំ១៩៧០ ខ្ញុំបានភ្ជាប់ទំនាក់ទំនងជាមួយ ស៊ូ និង ស៊ុយ គឺជាគណៈតំបន់៨។ បន្ទាប់ពីខ្ញុំបានភ្ជាប់ខ្សែជាមួយ ស៊ូ ហើយ ស៊ូ បានចាត់តាំងខ្ញុំឱ្យធ្វើជាប្រធានភូមិស្តី។ រហូតដល់ឆ្នាំ១៩៧២ ស៊ូ បានចាត់តាំងខ្ញុំ និងបក្ខពួកឱ្យមានតួនាទីកាន់តែខ្ពស់នៅក្នុងបក្ស ដោយពេលនោះខ្ញុំគឺជាអនុលេខាស្រុក៨៣។ បន្ទាប់មកទៀត ខ្ញុំបានចូលរួមប្រជុំនៅឃុំដូនទ្រី ដោយអ្នកដឹកនាំប្រជុំមាន ស៊ូ និង ស៊ុយ។ ខ្លឹមសារការប្រជុំគឺ ស៊ូ បានប្រកាសឱ្យសមាជិកបក្សទាំងអស់ស្គាល់គ្នា ហើយរួមសកម្មភាពជាមួយគ្នាឱ្យជាប់។ ក្រោយពីប្រជុំចប់ ខ្ញុំរួមទាំងសមាជិកចូលរួម៧នាក់ទៀតបានបំផុសប្រជាជនឱ្យរត់ចូលតំបន់ខ្លាំងអស់ចំនួនពីរគ្រួសារ នៅក្នុងភូមិបីឥក្រសា។ ក្រៅពីនេះ ខ្ញុំ និង សឹម បានរួមគ្នាកសាងកម្លាំងបានចំនួន៨នាក់បន្តែមទៀត។

នៅចន្លោះឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ ខ្ញុំនិងបក្ខពួកមានឈ្មោះ លឹម, ភី, ប៉ឿយ, រ៉ែន, រ៉ែ, ភ័ន និង ថង បានទទួលដែនការពី ស៊ូ ជាបន្តបន្ទាប់គឺ ទីមួយ) ត្រូវកសាងកម្លាំងបង្គុំបក្ខងជួរបដិវត្តន៍។ ទីពីរ) បំផុសប្រជាជនឱ្យរត់ទៅតំបន់ខ្លាំង។ ទីបី) បំផុសយុវជនយុវនារីមិនឱ្យចូលបម្រើបដិវត្តន៍។ ទីបួន) បំភ្លៃមាគ៌ារបស់បក្សទាក់ទងបញ្ជូនម្ហូបប្រជាជនពីតំបន់ខ្លាំង។ ចំពោះការជម្លៀសប្រជាជនតាមដែនការគឺ ជម្លៀសត្រឹមតែ១០ ទៅ ២០គ្រួសារតែប៉ុណ្ណោះ។

មកដល់ឆ្នាំ១៩៧៥ ប្រជាជនខ្លះខាតស្បៀងយ៉ាងខ្លាំង ដូច្នេះអង្គការបានចាត់តាំង គឿម ទៅដឹកជញ្ជូនស្រូវពីស្រុកដូនទ្រីមកដាក់នៅស្រុកដូនទាវិញ។ ខណៈពេលដឹកជញ្ជូននោះ គឺមានកម្លាំងពីរនាក់ទៅជាមួយ គឺឈ្មោះ យ៉ុន និង និត។ ពេលទៅដល់ស្រុកដូនទ្រី គឿម បានជួបជាមួយ រ៉ែន និង ភី ហើយបានសហការគ្នាធ្វើឱ្យយឺតយ៉ាវដើម្បីឱ្យប្រជាជនអត់បាយ ដោយយកលេសថាខូចនេះខូចនោះ មិនព្រមដឹកឱ្យប្រជាជនតាមដែនការរបស់បក្សកំណត់ពីរសប្តាហ៍ដឹកមកម្តង ប៉ុន្តែយើងបានពន្យារហួតដល់ពីរខែ។

ក្រោយរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឿម និងបក្ខពួកបានមកទទួលដែនការពី ស៊ូ និង ស៊ុយ នៅភូមិអូរដំបងក្នុងខ្លឹមសារដូចតទៅ៖ ទីមួយ) បង្កត់អាហារប្រជាជន និងមិនដោះស្រាយជម្រកឱ្យប្រជាជនដែលជម្លៀសមកទេ ដើម្បីឱ្យប្រជាជនមានជម្លោះជាមួយបដិវត្តន៍។ ទីពីរ) បន្តកសាងកម្លាំងឱ្យខ្លាំងក្លា ដើម្បីត្រៀមវាយបដិវត្តន៍នៅថ្ងៃខាងមុខ។ ទីបី) ប្រមូលអាវុធ គ្រាប់ និងថ្នាំពេទ្យ ក្នុងក្រុងបាត់ដំបងត្រៀមវាយបដិវត្តន៍។ ទីបួន) បំភ្លៃមាគ៌ាក្នុង

ការដោះស្រាយជីវភាពជូនប្រជាជនៗ ទីប្រាំ) បំផុសរឿងពុករលួយក្នុងស្រុកៗ ក្រោយថ្ងៃរំដោះ ប្រជាជនជាង៥ម៉ឺននាក់ត្រូវអង្គការជម្លៀសមកនៅស្រុកដូនទាវ ពេលនោះខ្ញុំរួមទាំង សឹម និង កែម បានចាត់តាំងកម្លាំងក្បត់ឱ្យមកក្តោបក្តាប់ប្រជាជនទាំងនេះ។

នៅក្នុងឆ្នាំ១៩៧៦ មួច, ស៊ូ និង ស៊ុយ បានហៅបក្ខពួកទៅប្រជុំនៅសាលាអន្តរាំលក្នុងគោលបំណងប្រាប់ពីការវាយបក្សនៅខែកុម្ភៈ ឆ្នាំ១៩៧៧។ ក្រោយពីទទួលដែនការពី មួច រួចហើយ នៅដើមឆ្នាំ១៩៧៧ ខ្ញុំ និង សឹម បានហៅខ្សែភាគក្រោមមានយ៉ុន, ញឿង, នឹត និង នុត មកប្រាប់អំពីដែនការវាយបក្សបន្តពីថ្នាក់លើ និងជំរុញឱ្យធ្វើសកម្មភាពបំផ្លាញដល់ដំណាំបដិវត្តន៍តទៀត។ តាមការបញ្ជារបស់ មួច គឺឈ្មោះ សឹម, កែម រួមទាំងខ្ញុំ បានលាក់ស្រូវជាង៨,000បាវ តាមរូបភាពពាក់កណ្តាលស្របច្បាប់។ សកម្មភាពនេះធ្វើដោយមិនបានរាយការណ៍ជូនអង្គការ ហើយប្រសិនបើអង្គការដឹងឱ្យប្រាប់ថាស្រូវទុកសម្រាប់ធ្វើពូជ។

នៅក្នុងខែឧសភា ឆ្នាំ១៩៧៧ អង្គការបានដកឈ្មោះ ស៊ុយ ពីតំបន់៦មកធ្វើជាអនុលេខាតំបន់៨ និងដោយខ្លួនទទួលជាលេខាស្រុកដូនទាវ។ រហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំបានរួមសកម្មភាពជាមួយបក្ខពួកនៅខាងលើបំភ្លៃមាគ៌ារបស់បក្ស ដោយយកស្រូវស្រាលទៅព្រុសក្នុងស្រែជម្រៅ យកស្រូវធ្ងន់ព្រុសដីគោកធ្វើឱ្យស្រូវលិចទឹកខូចអស់១៣០ហិកតា បង្កឱ្យប្រជាជនខ្វះស្បៀងអាហារយ៉ាងខ្លាំង។ មកដល់ខែកក្កដា ឆ្នាំ១៩៧៧ នៅពេលអង្គការឱ្យទប់ទឹកភ្លៀងសម្រាប់ព្រោះសំណាប់ចំនួន១០០ហិកតា បក្ខពួកខាងលើបានបំភ្លៃមិនឱ្យទប់ទឹកភ្លៀងធ្វើគ្មានទឹកសម្រាប់ព្រោះសំណាប់៥០ហិកតាទៀតដែលនៅសល់។ នៅក្នុងខែសីហា ឆ្នាំ១៩៧៧ ខ្ញុំនឹងបក្ខពួកបានពន្លឿនអាយុសំណាបសម្រាប់ស្រូវស្រាលទុកឱ្យចាស់ធ្វើឱ្យស្រូវមិនបែកគុម្ព។ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនខ្ញុំតែម្តង ចំណែកកម្លាំងដែលខ្ញុំ និងបក្ខពួកកសាងបានមានចំនួនសរុប៧០នាក់។

កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខJ00៣0១។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ប៉ូច ចឹក ហៅ គឿម ពិតប្រាកដឬយ៉ាងណានោះទេ។



កងមនុស្សចាស់នៅក្នុងស្រុកសង្កែ កំពុងធ្វើបង្គី ដងចប ដងវែក និង សង្រែកៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្ដាយទីរកឥន្ធ ថុង សុផាន់ណុះ
ពេលនឹកកូនប្រុសពេក ខ្ញុំមានបំណងចង់ទៅជួបកូននៅសមរភូមិមុខ

ភាព សម្ភស្ស

«ពេលនឹកកូនប្រុសខ្លាំងពេក ខ្ញុំមានបំណងទៅជួបកូននៅសមរភូមិមុខប៉ុន្តែកូនប្រុសនិយាយថា ម៉ែ! បន្តិចទៀតចប់សង្គ្រាមខ្ញុំទៅលេងម៉ែ និងបងៗហើយ ម៉ែមិនជាប់មកលេងខ្ញុំទេ ពីព្រោះផ្លូវពិបាក ហើយ ទាហានថៃនៅឈ្លាតក្បៀវៗហ្នឹង ម៉ែកុំមកអី ចាំខ្ញុំទៅលេងម៉ែនៅផ្ទះ»។ អ្នកស្រី យូ ឃុន្នីង អាយុ៦៣ឆ្នាំ មានមុខរបរជាបុគ្គលិកពេទ្យប្រចាំនៅមន្ទីរពេទ្យបង្អែក១៦មករា ខេត្តព្រះវិហារ ត្រូវជាម្ដាយវីរកងទ័ព ថុង សុផាន់ណុ បានរៀបរាប់រឿងរ៉ាវកូនប្រុសរបស់ខ្លួនទាំងអួលដើមករដូចខាងក្រោម៖

ខ្ញុំមានទីកន្លែងកំណើតនៅ ភូមិវៀងត្បូង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិ ឡតដ្ឋ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។ ខ្ញុំមានប្ដីឈ្មោះ លឹម ថុង ស្លាប់នៅឆ្នាំ២០២៣ និងមានកូនចំនួន៥នាក់ក្នុងនោះមានស្រី២នាក់ និងប្រុស៣នាក់។ កូនទី១) ឈ្មោះ ង្ហាង ភារុន ភេទប្រុស អាយុ៣៩ឆ្នាំ កូនទី២) ឈ្មោះ ង្ហាង ភារិទ្ធ ភេទស្រី អាយុ៣៧ឆ្នាំ កូនទី៣) ឈ្មោះ ង្ហាង ភារ៉ា ភេទស្រី អាយុ៣៥ឆ្នាំ កូនទី៤) ឈ្មោះ ថុង សុផាន់ណា ភេទប្រុស អាយុ២៥ឆ្នាំ និងកូនពៅឈ្មោះ ថុង សុផាន់ណុ ភេទប្រុស អាយុ២៣ឆ្នាំ។ កូនប្រុសពៅខ្ញុំ ថុង សុផាន់ណុ កើតនៅភូមិ ឡតដ្ឋ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

កាលពីក្មេងកូនខ្ញុំ សុផាន់ណុ បានចូលរៀននៅសាលាក្នុងភូមិ ឡតដ្ឋ និងបានបន្តការសិក្សានៅវិទ្យាល័យចំណោះទូទៅ និងបច្ចេកទេស ជា ស៊ីម ក្រៃងមានជ័យ ក្នុងក្រុងព្រះវិហារ រហូតប្រឡងជាប់ជាក់ខុប នៅឆ្នាំ២០២១។ បន្ទាប់មក សុផាន់ណុ បានចូលរៀនផ្នែកគ្រប់គ្រងធនធានមនុស្សនៅវិទ្យាស្ថានពហុបច្ចេកទេស ខេត្តព្រះវិហារ។



វីរកងទ័ព ថុង សុផាន់ណុ ពលីជីវិតដើម្បីការពារទឹកដីពីការឈ្លានពានរបស់កងទ័ពថៃ នៅតំបន់អានសេះ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៅខែធ្នូ ឆ្នាំ២០២៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ២០២៣ ពេល សុផាន់ណុ កំពុងរៀនឆ្នាំទី២ បានសម្រេចចិត្តឈប់រៀន និងស្ម័គ្រចិត្តចូលធ្វើកងទ័ពនៅតំបន់ប្រតិបត្តិការសឹករងខេត្តព្រះវិហារ។ បន្ទាប់ពីចូលបម្រើកងទ័ព សុផាន់ណុ តែងតែធ្វើដំណើរទៅ ហឹក ហឺនកាយសម្ប ទាក់ម្រិតដំបូងនៅបន្ទាយកងទ័ពដែលមានចម្ងាយប្រហែល ៣គី ឡូម៉ែត្រពីផ្ទះជារៀងរាល់ព្រឹក។ សុផាន់ណុ ហឹក ហឺននៅបន្ទាយកងទ័ពតាំងពីពេលព្រឹករហូតដល់យប់ទើប

ត្រឡប់មកផ្ទះវិញ និងមានពេលខ្លះ សុជាន់ណូ សម្រាកនៅក្នុងបន្ទាយកងទ័ពតែម្តង។ សុជាន់ណូបានហ៊ឺកហ៊ឺនកាយសម្បទាអស់រយៈពេល៦ខែទើបបញ្ចប់។ បន្ទាប់មក សុជាន់ណូ ត្រូវបានថ្នាក់លើបញ្ជូនឱ្យទៅឈ្លាតដើម្បីការពារព្រៃឈើ និងសត្វព្រៃ នៅស្រុកសង្គមថ្មី ខេត្តព្រះវិហារ ជាមួយក្រុមការងារអភិរក្សព្រៃឈើ និងធនធានធម្មជាតិ។

នៅក្នុងខែមិថុនា ឆ្នាំ២០២៥ សុជាន់ណូ បានមកលេងផ្ទះ និងបាននិយាយប្រាប់ខ្ញុំថា «ម៉ែអើយ! នៅព្រំដែនកម្ពុជា-ថៃ ឥឡូវកំពុងតែមានសភាពតឹងតែងខ្លាំងណាស់ ខ្ញុំចុះមកពីស្រុកសង្គមថ្មីលើកនេះ ត្រូវបានថ្នាក់លើបញ្ជូនទៅឈរជើងនៅសមរភូមិតំបន់អានសេះវិញហើយម៉ែ»។ ខ្ញុំបានតបទៅកូនវិញថា «អឺ! បើកូនទៅសមរភូមិជួរមុខកូនត្រូវចេះការពារខ្លួន និងប្រយ័ត្នប្រយែង កូនត្រូវតែរៀន និងមើលគំរូតាមបងៗ និងពួកគង់ទ័ពយើងណាកូន»។ ខ្ញុំនិយាយចប់ កូនស្រីទី២ខ្ញុំឈ្មោះ ង្ហាង ភារិទ្ធ បានជូន សុជាន់ណូ ទៅឡើង ឡានទៅកន្លែងតំបន់ប្រតិបត្តិការសឹករង ខេត្តព្រះវិហារ។ ចាប់តាំងពី សុជាន់ណូ ទៅឈរជើងនៅសមរភូមិតំបន់អានសេះ ជារៀងរាល់ថ្ងៃខ្ញុំតែងតែឆ្លៀតពេលទូរសព្ទទៅកូនប្រុស ដើម្បីសួរសុខទុក្ខ និងប្រាប់កូនឱ្យប្រយ័ត្នប្រយែងខ្លួន។ នៅពេលមួយ ខ្ញុំបានសួរកូនប្រុសថា កូនមានដែលឃើញទាហានថៃឡើងមកក្បែរកន្លែងកូនឈរជើងដែរឬទេ? កូនខ្ញុំតបមកវិញថា វាឡើងមករាល់ថ្ងៃហ្នឹងម៉ែ! ខ្ញុំសួរកូនបន្តែមទៀតថា កូនមានឃើញវាកាន់កាំភ្លើងទេ? កូនខ្ញុំតបមកវិញថា ជួនណាវាឡើងមកមិនកាន់កាំភ្លើងទេ ឃើញអ៊ីចឹងក្រមខ្ញុំបានដេញវាឱ្យចុះទៅក្រោមវិញ។ ចាប់តាំងពី សុជាន់ណូ ត្រូវបញ្ជូនទៅប្រចាំការនៅសមរភូមិមុខតំបន់អានសេះ គឺ សុជាន់ណូ មិនដែលបានមកលេងផ្ទះម្តងណាឡើយ។

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៥ ពេលចប់ពិធីសែនក្បាលទឹកនៅផ្ទះ ខ្ញុំនិងកូនៗដទៃទៀតបាននាំគ្នាធ្វើដំណើរទៅលេងកូន សុជាន់ណូ នៅសមរភូមិតំបន់អានសេះ។ ពេលទៅដល់ខ្ញុំបានហៅទូរសព្ទទៅប្រាប់ សុជាន់ណូ ថាម៉ែបានមកដល់កន្លែងកូនហើយ។ សុជាន់ណូ ប្រញាប់ប្រញាល់ចុះមកជួបខ្ញុំ និងបងៗ។ បន្ទាប់ពីបានអង្គុយសំណេះសំណាល និងសួរសុខទុក្ខគ្នាបានបន្តិច ខ្ញុំ និងកូនៗទាំងអស់បានថតរូបជុំគ្នាទុកជាអនុស្សាវរីយ៍។ បន្ទាប់មកខ្ញុំបានទុកម្ហូប និងរបស់របរប្រើប្រាស់ឱ្យកូនប្រុសយកទៅកន្លែងលេណដ្ឋានវិញ។ ចំណែកខ្ញុំ និងកូនៗដទៃទៀតបាននាំគ្នាត្រឡប់មកផ្ទះវិញ។ ជារៀងរាល់ថ្ងៃខ្ញុំតែងតែទូរសព្ទទៅសុជាន់ណូ និងសួរសុខទុក្ខតាមទម្លាប់ដូចធម្មតា។

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានទូរសព្ទទៅកូនប្រុសតាមវីដេអូឆាត ខ្ញុំឃើញកូនប្រុសដេកលើអង្រឹងខិបកាំភ្លើង ខ្ញុំបាននិយាយទៅកាន់កូនថា កូនប្រយ័ត្នប្រយែងខ្លួនណាកូន។ កូនប្រុសខ្ញុំបានឆ្លើយតបមកខ្ញុំវិញថា «បាទម៉ែ! ខ្ញុំមិនអីទេ»។ ខ្ញុំបាននិយាយបន្តទៅកាន់កូនថា ម៉ែនឹកកូនឯងណាស់ ម៉ែមានបំណងចង់ទៅលេងកូនឬកូនសុំច្បាប់ថ្នាក់លើមកលេងផ្ទះម្តងមក។ កូនប្រុសខ្ញុំតបមកវិញថា «ម៉ែ! តិចទៀតបប់សង្គ្រាមខ្ញុំទៅលេងម៉ែហើយ ម៉ែមិនបាច់មកលេងខ្ញុំទេដ្ឋវាពិបាកណាស់ហើយទាហានថៃនៅឈ្លាតក្បែរៗហ្នឹង ម៉ែកុំមកអី ចាំខ្ញុំទៅលេងម៉ែនៅផ្ទះ»។

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានឃើញកងទ័ពត្រូវដាមិត្តភក្តិកូនខ្ញុំ សុជាន់ណូ ឈ្មោះ វិន មកសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យបង្អែក ១៦ មកពី ខេត្តព្រះវិហារ ដែលជាកន្លែងខ្ញុំកំពុងបម្រើការងារ។ ភ្លាមៗនោះខ្ញុំបាននឹក និងជារម្ភពីកូនប្រុស ខ្ញុំបានទូរសព្ទទៅកូនប្រុស ប៉ុន្តែមិនមានអ្នកទទួល និងឆ្លើយតបឡើយ។ បន្ទាប់មកខ្ញុំបានទៅសួរមិត្តភក្តិកូនប្រុសខ្ញុំឈ្មោះ វិន។ វិនបាននិយាយថា ពេលផ្ទុះអាវុធខ្លាំងខ្ញុំបានឃើញ សុជាន់ណូ ចុះមកក្រោមហើយ ប៉ុន្តែមិនដឹងចុះមកដល់ណាទេ។ ខ្ញុំខ្លាចតែ សុជាន់ណូ រងគ្រោះធ្ងន់ទេ។ ពេលខ្ញុំបានទទួលដំណឹងពីកងទ័ពឈ្មោះ វិន ហើយ លុះដល់យប់ខ្ញុំដេកមិនលក់ឡើយ ព្រោះខ្ញុំព្រួយបារម្ភពីកូនប្រុស។ នៅអំឡុងពេលបាត់ដំណឹងកូនប្រុស ខ្ញុំតែងតែព្យាយាមទូរសព្ទទៅកូនប្រុសប៉ុន្តែមិនអាចទាក់ទងបានឡើយ។

នៅវេលាម៉ោងប្រមាណ៨ព្រឹកថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ ត្រូពេទ្យកងទ័ពឈ្មោះ ជា វុទ្ធី បានទូរសព្ទ

ប្រាប់ខ្ញុំថា បានឃើញសាកសពកូនប្រុសខ្ញុំឈ្មោះ ជុត សុដាន់ណូ មានសភាពស្ទុយរលួយសាច់អស់ហើយ នៅសល់តែសម្បៀកបំពាក់ និងស្លាកឈ្មោះដែលអាចសម្គាល់អត្តសញ្ញាណកូនប្រុសខ្ញុំបាន។ ពេលខ្ញុំទទួលដំណឹងនេះភ្លាម ខ្ញុំទន់ដៃទន់ជើងអស់ និងបានយំរហូត។ នៅវេលាម៉ោង១១ព្រឹកថ្ងៃដដែល សពកូនប្រុសខ្ញុំបានដឹកមកដល់តំបន់ប្រតិបត្តិការសឹករង ខេត្តព្រះវិហារ ហើយខ្ញុំបានសុំអនុញ្ញាតមេបញ្ជាការយកសពកូនប្រុសមកផ្ទះ ដើម្បីរៀបចំពិធីបុណ្យតាមទំនៀមទម្លាប់សាសនាខ្មែរ។

ពិធីបុណ្យសពកូនប្រុសខ្ញុំ គឺអនុសេនីយ៍ត្រី ជុត សុដាន់ណូ ត្រូវប្រារព្ធធ្វើនៅភូមិ ឡវដ្ឋ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ នាថ្ងៃព្រហស្បតិ៍ទី១ ខែមករា ឆ្នាំ២០២៦។ ចំណែកពិធីបុណ្យគម្រប់ខួប៧ថ្ងៃ បានប្រារព្ធធ្វើនៅថ្ងៃពុធទី៧ ខែមករា ឆ្នាំ២០២៦ និងពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ប្រារព្ធធ្វើនៅថ្ងៃសៅរ៍ទី២១ ខែមីនា ឆ្នាំ២០២៦។

ចាប់តាំងពីកូនប្រុសខ្ញុំបានពលីជីវិតរហូតមកដល់ពេលនេះ ខ្ញុំមិនទាន់អាចកាត់ចិត្តបានឡើយ ព្រោះកូនប្រុសខ្ញុំគឺជាមនុស្សដែលមានអត្តចរិកល្អ មិនចេះប្រកែក និងនិយាយពាក្យសម្តីអសុរោះដាក់ឪពុកម្តាយ បងប្អូនសាច់ញាតិឡើយ។ ពេលនេះខ្ញុំនៅតែនឹកស្រណោះកូនប្រុសខ្ញុំហើយឱ្យតែមានអ្នកជិតខាងនិយាយឈ្មោះកូនប្រុសខ្ញុំយំរហូត។ កូនប្រុសខ្ញុំនៅប្រចាំការនៅសមរភូមិតំបន់អានសេះអស់រយៈពេល៦ខែ មិនដែលបានមកផ្ទះសូម្បីតែម្តង។ កូនប្រុសរបស់ខ្ញុំនិយាយថា ពេលចប់សង្គ្រាមនឹងមកលេងផ្ទះជួបម្តាយបងប្អូនសាច់ញាតិ ប៉ុន្តែបែរជាជួបរឿងអកុសលបែបនេះ។ ខ្ញុំអាណិតកូនប្រុសខ្ញុំណាស់ កូនប្រុសខ្ញុំតាំងពីតូចរហូតដល់ធំ ខ្ញុំមិនដែលវាយដំឬជេរប្រមាថសូម្បីតែម្តង ហេតុអ្វីកូនប្រុសខ្ញុំត្រូវស្លាប់។

ជាចុងក្រោយនាងខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់ជួយខបត្តម្ភ និងសាងសង់ផ្ទះមួយខ្នងនៅក្នុងភូមិ ឡវដ្ឋ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ សម្រាប់នាងខ្ញុំ និងកូនៗអាចមានជម្រកសំនៅបានសមរម្យ។



វីរកងទ័ព ជុត សុដាន់ណូ ពលីជីវិតដើម្បីការពារទឹកដីពីការឈ្លានពានរបស់កងទ័ពថៃ នៅតំបន់អានសេះ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៅខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ពិធីបុណ្យសពវីរកងទ័ព ជុត សុដាន់ណូ នៅផ្ទះស្ថិតនៅក្នុងភូមិ ឡវដ្ឋ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វីរកងឆ័ត ទន់ សារិន៖

ការសន្យាដាំប្រពន្ធកូនដើរកម្សាន្ត លែងមានឱកាសជារៀងរហូត

កែវ សុគី



វីរកងឆ័ត ទន់ សារិន ពលីជីវិតដើម្បីការពារទឹកដីពីការឈ្លានពានរបស់កងទ័ពថៃនៅសមរភូមិ ភូមិព្រៃចាន់ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វីរកងឆ័ត ទន់ សារិន បានពលីនៅសមរភូមិភូមិព្រៃចាន់ នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ បានបន្សល់ទុកនូវក្តីអាឡោះអាល័យជាពន់ពេកចំពោះក្រុមគ្រួសារ ហើយការសន្យាថានាំប្រពន្ធកូនដើរកម្សាន្តជារៀងដរាបនឹងលែងមានឱកាសជារៀងរហូត។ អ្នកស្រី ម៉ុន សុភ័ក្រ អាយុ៣៩ឆ្នាំ រស់នៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ត្រូវជាប្រពន្ធរបស់វីរកងឆ័ត ទន់ សារិន បានរៀបរាប់រឿងរ៉ាវក្រុមគ្រួសារ ដូចខាងក្រោម៖

ប្តីរបស់ខ្ញុំមានឈ្មោះ ទន់ សារិន អាយុ៣៦ឆ្នាំ មានឋានន្តរសក្តិវរសេនីយ៍ឯក មានស្រុកកំណើតនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ប្តីរបស់ខ្ញុំគឺជាកូនទីពីរក្នុងចំណោមបងប្អូនចំនួន ៣នាក់ គឺស្រីម្នាក់ និងប្រុសពីរនាក់។ ប្តីរបស់ខ្ញុំមានឪពុកឈ្មោះ ទន់ ញឿន និងម្តាយឈ្មោះ កង លី ប៉ុន្តែអ្នកទាំងពីរបានស្លាប់តាំងពីប្តីខ្ញុំមានអាយុទើបតែ៩ឆ្នាំ។ ក្រោយពេលឪពុកម្តាយចែកឋានទៅ ប្តីរបស់ខ្ញុំបានទៅរស់នៅជាមួយយាយតារហូតដល់ពួកគាត់ទទួលមរណភាព ទើបប្តីរបស់ខ្ញុំផ្ទាល់មករស់នៅជាមួយបងស្រីបង្កើតវិញ។

កាលពីក្មេងប្តីរបស់ខ្ញុំបានចូលរៀននៅសាលាក្នុងភូមិកំណើត និងបន្តការសិក្សានៅវិទ្យាល័យអង្គរកា។ នៅក្នុងឆ្នាំ២០១២ ប្តីរបស់ខ្ញុំបានប្រឡងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ឌុប)។ ក្រោយបញ្ចប់ការសិក្សាភ្លាម ប្តីរបស់ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ព។ ថ្នាក់ដឹកនាំក្នុងអង្គភាពកងទ័ពបានបញ្ជូនប្តីរបស់ខ្ញុំទៅបណ្តុះបណ្តាលនៅសាលាហ៊ឹកហ៊ឺនរថក្រោះ រថពាសដែក៨៦ ក្នុងស្រុកភ្នំស្រុច ខេត្តកំពង់ស្ពឺ។ ប្តីរបស់ខ្ញុំបានចូលរៀនវគ្គខ្លីៗជាច្រើនលើកថែមទាំងបានទៅបន្តការសិក្សាភាសាវៀតណាម និងផ្នែកបច្ចេកទេសរថក្រោះ រថពាសដែកនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។

នៅឆ្នាំ២០១៥ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំ និងបង្កើតបានកូនស្រីចំនួន២នាក់ គឺកូនស្រីច្បងឈ្មោះ ញឿន លីណេត អាយុ១១ឆ្នាំ និងកូនស្រីទីពីរឈ្មោះ ញឿន ស្រីនីត អាយុ៩ឆ្នាំ។

មុនពេលសភាពការណ៍តានតឹងនៅតាមព្រំដែន

កម្ពុជា-ថៃប្តីរបស់ខ្ញុំបានបម្រើការងារនៅបញ្ជាការដ្ឋានរថក្រោះ រថពាសដែក កងទ័ពជើងគោក ដែលមានទីតាំងស្ថិតនៅភូមិឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ប្តីរបស់ខ្ញុំតែងតែធ្វើដំណើរមកលេងប្រពន្ធកូនភូមិត្រពាំងជ្រៃ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ជាញឹកញាប់។

នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ កងទ័ពថៃបានបាញ់សម្លាប់វីរកងទ័ពកម្ពុជាម្នាក់ដែលគ្មានអាវុធនៅក្បែរលេណដ្ឋាន ក្នុងភូមិសាស្ត្រតំបន់ម៉ុបី ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ បន្ទាប់មកនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ ប្តីរបស់ខ្ញុំបានទទួលបេសកកម្មទៅប្រចាំការនៅបញ្ជាការដ្ឋានរថក្រោះ ប្រចាំទិសយោធភូមិភាគទី៥ ស្ថិតនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅពេលផ្ទុះអាវុធលើកទី១ ចន្លោះពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ សមរភូមិខេត្តបន្ទាយមានជ័យមិនទាន់មានផ្ទុះអាវុធធំដុំឡើយ។ ក្រោយមកអង្គភាពប្តីរបស់ខ្ញុំត្រូវបានផ្ទាស់ទៅប្រចាំការនៅសមរភូមិភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ប្តីរបស់ខ្ញុំបានសុំច្បាប់ពីមេបញ្ជាការមកលេងផ្ទះរយៈពេលមួយសប្តាហ៍ដើម្បីមើលថែខ្ញុំដែលកំពុងមានជំងឺ និងជួយប្រមូលផលស្រូវអំឡុងពេលជួបជុំគ្នានៅផ្ទះ ប្តីរបស់ខ្ញុំមានគម្រោងថា៖ ពេលកូនៗធំ យើងនឹងដើរកម្សាន្តជុំគ្នាបានម្តង។ កាលពីមុនគ្រួសារខ្ញុំមានជីវភាពខ្វះខាតហើយខ្ញុំធ្លាប់បបួលប្តីនាំកូនៗទៅដើរកម្សាន្តជុំគ្នាម្តងហើយ ប៉ុន្តែប្តីខ្ញុំនិយាយថា «យើងមិនសូវមានលុយកាក់ទេអូន កុំទាន់ទៅអី»។ ប្តីរបស់ខ្ញុំបានច្រាប់ដំណឹងមួយទៀតដល់ខ្ញុំថា ពេលចប់សង្គ្រាមលើកនេះគាត់ត្រូវប្តូរមកប្រចាំការនៅបញ្ជាការដ្ឋានកងរថក្រោះ រថពាសដែកវិញ ព្រោះគាត់បានបំពេញបេសកកម្មគ្រប់រយៈពេល៧ខែហើយ។ ពេលដឹងថាប្តីនឹងផ្ទាស់មកប្រចាំការនៅបញ្ជាការដ្ឋានរថក្រោះរថពាសដែកខ្ញុំសប្បាយចិត្តខ្លាំងណាស់ព្រោះគ្រួសារយើងអាចរស់នៅជួបជុំគ្នាវិញ។ ប្តីរបស់ខ្ញុំថែមទាំងមានគម្រោងថា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ត្រូវថ្ងៃឆ្លងឆ្នាំសកល យើងនឹងទៅចូលរួមពិធីខួបកំណើតក្មួយនៅទីក្រុងភ្នំពេញ។ បន្ទាប់មកនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ យើងនឹងនាំគ្នាដើរកម្សាន្តជួបជុំគ្រួសារជាលើកដំបូង ប៉ុន្តែពេលនេះក្តីស្រមៃ និងការសន្យាត្រូវរលាយបាត់អស់គ្មានថ្ងៃវិលវិញឡើយ។

ទោះបីប្តីខ្ញុំមានបំណងប្រាថ្នាចង់រស់នៅជួបជុំគ្រួសារប៉ុន្តែប្តីរបស់ខ្ញុំបានបង្ហាញពីទឹកចិត្តស្នេហាជាតិនិងការពារទឹកដីយ៉ាងធំធេង។ ប្តីរបស់ខ្ញុំបាននិយាយថា កងទ័ពមិនខ្លាចពិបាកទេ ជាពិសេសនៅពេលប្រទេសមានសង្គ្រាមគឺកងទ័ពមិនអាចរត់ចោលជួរជាដាច់ខាត គឺត្រូវតែស៊ូ និងឈរជើងការពារនៅលើសមរភូមិរហូតដល់ទីបញ្ចប់។

ក្នុងរយៈពេលមួយសប្តាហ៍ដែលប្តីខ្ញុំរស់នៅជួបជុំប្រពន្ធកូនគឺជាពេលវេលាដែលមានសុភមង្គលបំផុតសម្រាប់គ្រួសារខ្ញុំ។ ប្តីរបស់ខ្ញុំយកចិត្តទុកដាក់មើលថែទាំប្រពន្ធកូនខុសពីធម្មតា ហើយតែងតែនិយាយជ្រាប់ខ្ញុំឱ្យរឹងមាំ និងថែរក្សាសុខភាពខ្លួនឯង និងមើលថែកូនៗដោយមិនចាំបាច់បារម្ភពីគាត់នៅសមរភូមិមុខទេ។ នៅយប់ចុងក្រោយមុនពេលប្តីរបស់ខ្ញុំឡើងជិះរថយន្តត្រឡប់ទៅសមរភូមិវិញ គាត់បានសួរសំណួរមួយដែលធ្វើឱ្យខ្ញុំមានការចម្ងែកក្នុងចិត្តថា៖ «តាំងពីយើងចាប់ដៃគ្នាជាប្តីប្រពន្ធមក អូនមានដែលប្រកាន់ឬខឹងស្អប់បងទេ?» ខ្ញុំបានឆ្លើយទៅវិញថា៖ «ប្តីប្រពន្ធយើងមិនដែលប្រកាន់គ្នារឿងអ្វីឡើយ ខ្ញុំនៅតែស្រឡាញ់បង និងមើលថែគ្រួសារជានិច្ច»។

នៅព្រឹកព្រលឹមថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ប្តីរបស់ខ្ញុំធ្វើដំណើរត្រឡប់ទៅអង្គភាពវិញ ទោះជាក្នុងចិត្តគាត់បានដឹងច្បាស់ថា ខ្ញុំមិនចង់ឱ្យគាត់ត្រឡប់ទៅវិញ។

នៅថ្ងៃចន្ទទី៨ ខែធ្នូ ឆ្នាំ២០២៥ នៅអង្គភាពប្តីរបស់ខ្ញុំមានការប្រជុំធំមួយ ហើយប្តីរបស់ខ្ញុំត្រូវមេបញ្ជាការបញ្ជូនទៅសមរភូមិនៅភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ នៅថ្ងៃដែលមានការផ្ទុះអាវុធយ៉ាងខ្លាំងរវាងកងទ័ពកម្ពុជា និងទាហានថៃ។ ខ្ញុំបានតាមដានព័ត៌មាន

ជាប់រហូត និងបានទូរសព្ទទៅសួរសុខទុក្ខប្តីរបស់ខ្ញុំ ហើយគាត់បានប្រាប់ថា គាត់ស្នាក់នៅអង្គភាពនិងសុខសប្បាយ។ ទោះបីយ៉ាងណាមានការប្រយុទ្ធគ្នាកាន់តែខ្លាំង ពេលនោះប្តីរបស់ខ្ញុំបានទូរសព្ទប្រាប់ខ្ញុំថា មេបញ្ជាការបានបញ្ជូឱ្យគាត់បើករថក្រោះចេញដំណើរទៅសមរភូមិព្រៃចាន់នោយប់នោះ។

ខ្ញុំបានទាក់ទងទៅប្តីរបស់ខ្ញុំជាប់រហូតគាត់ទៅដល់សមរភូមិមុខៗ ប្តីរបស់ខ្ញុំបានផ្តាំថា បើទាក់ទងគាត់មិនបានមានន័យថា គាត់ចូលសមរភូមិហើយ មិនបាច់ទូរសព្ទទៅគាត់ទៀតទេ។ ចាប់ពីម៉ោង៦ព្រឹកថ្ងៃអង្គារ ទី៩ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានដាច់ទំនាក់ទំនងជាមួយប្តីរហូតដល់ម៉ោង១២ ថ្ងៃត្រង់ថ្ងៃដដែល ទើបប្តីរបស់ខ្ញុំហៅទូរសព្ទមកខ្ញុំជាលើកចុងក្រោយ ទាំងសំឡេងកាំភ្លើងកំពុងបាញ់គ្នាយ៉ាងខ្លាំង។ ប្តីរបស់ខ្ញុំបានសួរកូនប៉ុន្តែគាត់មិនបាននិយាយជាមួយកូនទេព្រោះកូនៗទៅសាលារៀនអស់ហើយ។ ប្តីរបស់ខ្ញុំបានសួរថា៖ «កូនៗបានដេកថ្ងៃឬទេ?» ខ្ញុំបានប្រាប់គាត់ថា កូនៗបានដេក និងចេញទៅរៀនអស់ហើយរួចហើយខ្ញុំសួរគាត់វិញថា បងហូបបាយឬនៅ? គាត់តបថា គាត់បានឈប់សម្រាក និងចេញមកខាងក្រៅរថក្រោះ ប៉ុន្តែមិនទាន់បានហូបបាយទេព្រោះជាប់រវល់ខ្លាំង។ បន្ទាប់មកគាត់បានបិទទូរសព្ទ និងដាច់ការទាក់ទងរហូត។ ខ្ញុំកាន់ទូរសព្ទរង់ចាំប្តីហៅទូរសព្ទមកវិញ រហូតដល់ឈឺក្បាលពីព្រោះខ្ញុំមិនបានដេកពេញមួយយប់ទៅហើយ។ បន្ទាប់មកខ្ញុំបានទុកទូរសព្ទចោលរួចសម្រេចដេកបានកន្លះម៉ោង។ លុះដល់ម៉ោង ៣:៣០នាទីរសៀលថ្ងៃដដែល ខ្ញុំយកទូរសព្ទមកមើលម្តងទៀតបានឃើញលេខទូរសព្ទរបស់មេបញ្ជាការប្តីរបស់ខ្ញុំទាក់ទងមកខ្ញុំ។ ភ្លាមៗនោះ មេបញ្ជាការប្តីរបស់ខ្ញុំបានទូរសព្ទមកខ្ញុំម្តងទៀត និងប្រាប់ដំណឹងដ៏រន្ធត់ថា ប្តីរបស់ខ្ញុំបានពលីនៅសមរភូមិភូមិព្រៃចាន់តាំងពីវេលាម៉ោង ប្រមាណ២រសៀល នៅខណៈពេលដែលគាត់កំពុងបិទគម្របរថក្រោះមិនទាន់ទាំងជិតជង អំបែងគ្រាប់ផ្លោងបានហោះមកត្រូវចំក្បាលបណ្តាលឱ្យស្លាប់ភ្លាមៗតែម្តង។ នៅវេលាម៉ោង១២អធ្រាត្រ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ រថយន្តពេទ្យបានដឹកសពប្តីរបស់ខ្ញុំមកដល់ផ្ទះខ្ញុំស្ថិតនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីរៀបចំប្រារព្ធពិធីបុណ្យតាមប្រពៃណីសាសនា។

បុងក្រោយអ្នកស្រីម៉ុន សុភ័ក្រ្តបានរៀបរាប់ទាំងទឹកភ្នែកថា ខ្ញុំបានក្លាយជាស្ត្រីមេម៉ាយ កូនៗខ្ញុំបានក្លាយជាកូនកំព្រាឪពុក ដោយសារប្តីរបស់ខ្ញុំមានកាតព្វកិច្ចការពារទឹកដី។ ប្តីរបស់ខ្ញុំនិងវីរកងទ័ពកម្ពុជាដទៃទៀតបានលះបង់ដ៏ធំធេងដើម្បីជាតិមាតុភូមិ ដូច្នេះ សូមឱ្យប្រជាជនកម្ពុជាគ្រប់រូបចងចាំនូវវីរភាពរបស់យុទ្ធជនទាំងអស់ដែលបានពលីជីវិតក្នុងសមរភូមិជារៀងរហូត។



វីរកងទ័ព ទន់ សារិន ប្រពន្ធ និងកូនស្រី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ពិធីបុណ្យសពវីរកងទ័ព ទន់ សារិន នៅផ្ទះស្ថិតនៅក្នុងភូមិត្រពាំងជ្រៃ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាន់ វណ្ណាថ ៖
អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រងគ្រោះដោយសារជាហានថែ ឈួសឆាយ ព័ទ្ធយកដី និងផ្ទះសម្បែង

ម៉ៅ ស្រីណុច



ជាន់ វណ្ណាថ អាយុ៥៥ឆ្នាំ រស់នៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកកាលវែង ខេត្តពោធិ៍សាត់។ បច្ចុប្បន្ន វណ្ណាថ មកស្នាក់នៅជិតវត្តកៀសសីក វិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ ស្ថិតនៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកកាលវែង ខេត្តពោធិ៍សាត់ បណ្តោះអាសន្ន ដោយសារការឈ្លានពានទឹកដីពីកងទ័ពថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជាន់ វណ្ណាថ ភេទស្រី អាយុ៥៥ឆ្នាំ កើតនៅក្នុងភូមិបាក់ខែង ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល (សព្វថ្ងៃសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ)។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិសង្គមថ្មី ឃុំថ្មដា ស្រុកកាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ជាន់ ដល និងម្តាយខ្ញុំឈ្មោះ ជ្រាំង ភឿន។ ឪពុកម្តាយខ្ញុំស្លាប់ក្នុងរបបខ្មែរក្រហម ដោយឪពុករបស់ខ្ញុំស្លាប់ដោយសារអត់អាហារ។ ខ្ញុំមានបងប្អូនស្រីបង្កើតចំនួន២នាក់ ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ ប្អូនស្រីរបស់ខ្ញុំឈ្មោះ ជាន់ វណ្ណា បានបែកគ្នាក្នុងឆ្នាំ១៩៧៨ និងបាត់ដំណឹងរហូតមកដល់សព្វថ្ងៃ។ ខ្ញុំមានប្តីឈ្មោះ ស សុគុណដេត (ស្លាប់)។ ខ្ញុំមានកូនប្រុសចំនួន៨នាក់។

ខ្ញុំនៅចាំថា នៅឆ្នាំ១៩៧៥ ម្តាយរបស់ខ្ញុំបានសម្រាលបានប្អូនស្រីរបស់ខ្ញុំឈ្មោះ ជាន់ វណ្ណា។ នៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយឈ្នះលើរបប លន់ នល់ ទាំងស្រុង។ គ្រួសារខ្ញុំរួមទាំងប្រជាជនក្នុងខេត្តកណ្តាល ត្រូវបានខ្មែរក្រហមជម្លៀសឱ្យទៅកាន់ខេត្តពោធិ៍សាត់។ នៅថ្ងៃមួយ ឪពុករបស់ខ្ញុំបានបរទេះដឹកខ្ញុំម្តាយខ្ញុំ ព្រមទាំងប្អូនស្រី សំដៅទៅភូមិមួយ ក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់។ ខ្ញុំបានដើរថ្មើរជើងដង និងជិះរទេះដង។ បន្ទាប់មក ខ្មែរក្រហមបានបែងចែកគ្រួសាររបស់ខ្ញុំឱ្យរស់នៅត្រឹមស្រុកក្រគរ ខេត្តពោធិ៍សាត់។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យចូលក្នុងកងកុមារនៅក្នុងស្រុកក្រគរមួយរយៈ។ មិនយូរប៉ុន្មាន គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីស្រុកក្រគរឱ្យទៅកាន់ឃុំបឹងខ្នារ ស្ថិតក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ នៅស្រុកបាកាន ប្រធានកងប្រើខ្ញុំឱ្យជញ្ជូនកណ្តាប់យកទៅដាក់ក្នុងស្រែ ចំណែកឪពុកម្តាយរបស់ខ្ញុំទៅសូងស្រូវ។ នៅពេលថ្ងៃ ខ្ញុំត្រូវធ្វើការបែកពីឪពុកម្តាយ លុះដល់យប់ទើបខ្ញុំមកសម្រាកជាមួយឪពុកម្តាយរបស់ខ្ញុំវិញ។ បន្ទាប់ពីជញ្ជូនកណ្តាប់ដាក់ស្រែ ខ្ញុំត្រូវដើរពីសអាចម៍គោ និងកាប់ដើមទន្ទ្រានខែត្រជាមួយកងកុមារក្នុងឃុំបឹងខ្នារយកលាយធ្វើជីដាក់ស្រែ។ ប្រធានកងកុមារ

របស់ខ្ញុំមានប្រុសម្នាក់ និងស្រីម្នាក់ ប៉ុន្តែខ្ញុំមិនបានស្គាល់ឈ្មោះទេ។

នៅឆ្នាំ១៩៧៧ ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺដោយសារធ្វើការងារធ្ងន់ធ្ងរ គ្មានពេលសម្រាក និងមិនមានអាហារហូបគ្រប់គ្រាន់ហើយក្រោយមកគាត់បានស្លាប់ទៅ។ ចំណែកខ្ញុំត្រូវបានខ្មែរក្រហមប្រើឱ្យធ្វើការងារកាន់តែច្រើន និងហួសកម្លាំង។ ខ្មែរក្រហមកំណត់ឱ្យខ្ញុំជញ្ជក់ឱ្យគ្រប់ចំនួនដែលបានកំណត់ទើបឱ្យឡើងទៅហូបបបរ។ នៅពេលដល់ម៉ោងហូបអាហារ ខ្ញុំបានលួចបេះស្លឹកប្រស់ស្វាដែលដុះនៅតាមភ្នំស្រែយកមកលាយហូបជាមួយបបរ។

នៅឆ្នាំ១៩៧៨ ម្តាយរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺទៀត។ ម្តាយរបស់ខ្ញុំត្រូវបានបញ្ជូនឱ្យទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមួយក្នុងស្រុកបាកាន។ ចំណែកប្អូនស្រីខ្ញុំដែលមានអាយុ៣ឆ្នាំ ត្រូវបានដាក់ឱ្យនៅជាមួយម្តាយនៅក្នុងមន្ទីរពេទ្យ។ នៅពេលខ្ញុំទៅមើលម្តាយឈឺ ខ្ញុំបានឃើញគ្រូពេទ្យ២នាក់ប្តីប្រពន្ធយកចិត្តទុកដាក់ចំពោះប្អូនស្រីរបស់ខ្ញុំ និងស្រឡាញ់ប្អូនខ្ញុំយ៉ាងខ្លាំង។ គ្រូពេទ្យទាំង២នាក់ប្តីប្រពន្ធបានលួចយកបាយទុកឱ្យប្អូនស្រីរបស់ខ្ញុំហូបជាញឹកញាប់។ ក្រោយមកម្តាយរបស់ខ្ញុំបានស្លាប់នៅក្នុងមន្ទីរពេទ្យ។ ខ្ញុំបានឃើញកម្មាភិបាលខ្មែរក្រហមលើកម្តាយរបស់ខ្ញុំដាក់លើរទេះគោ រួចដឹកយកទៅទម្លាក់ចូលក្នុងរណ្តៅធំមួយស្ថិតក្នុងស្រុកបាកាន។ ខ្ញុំបានឃើញរណ្តៅដែលមានសាកសពជាច្រើននាក់។ ក្រោយពេលម្តាយរបស់ខ្ញុំបានស្លាប់ គ្រូពេទ្យទាំង២នាក់ប្តីប្រពន្ធបានស្នើសុំប្អូនស្រីរបស់ខ្ញុំយកទៅចិញ្ចឹមធ្វើជាកូនព្រោះពួកគាត់ទាំង២នាក់មិនមានកូនទេ។ កាលនោះ ប្អូនស្រីរបស់ខ្ញុំតែងតែយំតាមគ្រូពេទ្យទាំងពីរ ហើយគ្រូពេទ្យទាំងពីរបានមើលថែប្អូនស្រីរបស់ខ្ញុំទើបខ្ញុំយល់ព្រមឱ្យប្អូនស្រីទៅគាត់ចិញ្ចឹម។ ខ្ញុំស្រឡាញ់ប្អូនស្រីខ្លាំងណាស់ ប៉ុន្តែពេលនោះខ្ញុំមិនមានលទ្ធភាពចិញ្ចឹមបីបាច់ប្អូនព្រោះខ្ញុំនៅវ័យក្មេងនៅឡើយ។ ប្អូនស្រីរបស់ខ្ញុំមានសប្បុរសសក់រួចអង្គាដ៏ និងមានមុខមាត់ស្រដៀងម្តាយរបស់ខ្ញុំណាស់។ បន្ទាប់មក ខ្ញុំបានទៅរស់នៅជាមួយដីដូនបង្កើតខាងម្តាយខ្ញុំ ហើយខ្ញុំមិនដែលបានជួបជាមួយប្អូនស្រីទៀតទេ។

ថ្ងៃមួយ ខ្ញុំបានឃើញខ្មែរក្រហមបានចាប់ស្ត្រីមានផ្ទៃពោះម្នាក់យកទៅធ្វើពុរណាកម្មដោយចាប់ចងជាប់នឹងដើមត្នោត និងវះពោះ។ ខណៈពេលនោះ ខ្ញុំមានការភិតភ័យ រួចស្រែក ប៉ុន្តែដីដូនរបស់ខ្ញុំបានមកខ្ទប់មាត់ខ្ញុំជិត ទើបខ្មែរក្រហមមិនបានឮសំឡេង និងឃើញខ្ញុំ។ បន្ទាប់ពីវះពោះរួច ខ្មែរក្រហមបានយកទារក និងស្ត្រីនោះបោះទម្លាក់ចូលក្នុងរណ្តៅ។ ក្រោយពីខ្ញុំបានឃើញខ្មែរក្រហមសម្លាប់ស្ត្រីមានផ្ទៃពោះ ខ្ញុំមានអារម្មណ៍ភិតភ័យកាន់តែខ្លាំង។ ខ្មែរក្រហមតែងតែធ្វើពុរណាកម្ម និងបង្ហត់អាហារកុមារដែលធ្វើការងារមិនគ្រប់ចំនួនតាមដែនការកំណត់ ហេតុនេះខ្ញុំបានខិតខំប្រឹងប្រែងព្យាយាមធ្វើការងារឱ្យហើយរួចរាល់តាមការចាត់តាំង។

នៅឆ្នាំ១៩៧៩ ខ្ញុំជីដូន និងសាច់ញាតិខ្ញុំបានធ្វើដំណើរដោយថ្មើរជើងចេញពីខេត្តពោធិ៍សាត់ទៅកាន់ស្រុកកំណើតរបស់ខ្ញុំនៅខេត្តកណ្តាលវិញ។ ពេលមកដល់ភូមិ ខ្ញុំឃើញស្មៅ និងព្រៃដុះរុំព័ទ្ធជុំវិញផ្ទះ និងឃើញប្រជាជនចំនួន២គ្រួសារកំពុងស្នាក់នៅក្នុងផ្ទះរបស់ខ្ញុំ។ បន្ទាប់មកប្រជាជន២គ្រួសារនោះ បានធ្វើដំណើរទៅមុខបន្តទៀត ហើយគ្រួសារខ្ញុំបានចូលមករស់នៅក្នុងផ្ទះរបស់ខ្លួនវិញ។ ខ្ញុំនិងយាយបានកាប់ឆ្ការព្រៃ និងមើលថែដូង និងដំណាំផ្សេងទៀត។ ដំបូងការរស់នៅរបស់ខ្ញុំមានការលំបាកវេទនាណាស់ ព្រោះខ្ញុំគឺជាក្មេងកំព្រា និងមិនមានទ្រព្យសម្បត្តិអ្វីនៅសេសសល់ឡើយ។ បន្ទាប់មក ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ ស សុគុណដេត គឺជាវិស្វករក្នុងក្រុមហ៊ុនរបស់លោក ទ្រី ភាព។

នៅឆ្នាំ២០១៤ ដោយសារប្តីខ្ញុំត្រូវផ្ទាល់មកធ្វើការងារនៅព្រំដែនថ្មដា ទើបខ្ញុំសម្រេចចិត្តផ្ទាល់ប្តូរទីលំនៅមករស់នៅក្នុងភូមិសង្គមថ្មីឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ដំបូងខ្ញុំ និងប្តីបានជួលផ្ទះសម្រាប់ស្នាក់នៅ។ ក្រោយមក លោក ទ្រី ភាពបានផ្តល់ថវិកាមួយចំនួន និងអនុញ្ញាតឱ្យខ្ញុំ និងប្តីសាងសង់ផ្ទះរស់នៅលើដីរបស់គាត់នៅក្នុងភូមិសង្គមថ្មី។ ខ្ញុំបានចាប់ផ្តើមលើកគូបលក់បាយ គុយទាវមួប និងលក់កាហ្វេនៅមុខ

ផ្ទះរបស់ខ្ញុំ។ ខ្ញុំលក់ដូរដាច់ណាស់ ព្រោះនៅថ្មដាមានមនុស្សចូលមករស់នៅកាន់តែច្រើន។ ជាច្រើនឆ្នាំកន្លងមក ខ្ញុំ និងប្តីបានសន្សំលុយទិញដីនៅតំបន់អូរភ្នុកដីរទុកសម្រាប់សាងសង់ផ្ទះនៅលើដីរបស់ខ្លួនឯងផ្ទាល់។

នៅពេលកើតមានជម្លោះប្រដាប់អាវុធរវាងកងទ័ពកម្ពុជា និងទាហានថៃចំនួន២លើកកន្លងមកនៅតាមព្រំដែនថ្មដា ខ្ញុំភៀសខ្លួនចេញពីផ្ទះ និងបាននាំកូនៗធ្វើដំណើរមកស្នាក់នៅភ្នំជំរំជនភៀសសឹកភ្នំឃុំប្រម៉ោយ។ នៅពេលខ្ញុំស្នាក់នៅជំរំភៀសសឹក ខ្ញុំមានការព្រួយបារម្ភពីផ្ទះសម្បែងរបស់ខ្ញុំយ៉ាងខ្លាំង។ ក្រោយមានកិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃបានចូលមករុះរើរបស់របរ និងរាយលួសបន្ទាហ៊ុមព័ទ្ធយកដី និងផ្ទះរបស់ខ្ញុំ និងបានយកម៉ូតូរបស់ខ្ញុំចំនួនមួយគ្រឿងចេញពីផ្ទះនៅភ្នំភូមិសង្គមថ្មី។

ក្រោយយកម៉ូតូរបស់ខ្ញុំ ទាហានថៃបានដុះបង្កូតនិងថតបង្ហោះជាសាធារណៈថែមទៀត។ មិនត្រឹមតែប៉ុណ្ណោះ ទាហានថៃបានហ៊ុមព័ទ្ធយកដីរបស់ខ្ញុំនៅតំបន់អូរភ្នុកដីរ ស្ថិតក្នុងភូមិឯកភាព ឃុំថ្មដាថែមទៀត។ បន្ទាប់ពីខ្ញុំបានឃើញទាហានថៃហ៊ុមព័ទ្ធយកដី និងផ្ទះ ខ្ញុំពិតជាមានការឈឺចាប់ខ្លាំងណាស់។ នៅពេលស្ងប់ស្ងាត់សង្គ្រាម ខ្ញុំ និងកូនៗបានធ្វើដំណើរចេញពីឃុំប្រម៉ោយទៅមើលផ្ទះ ក្រែងលោអាចចូលទៅយករបស់របរ និងទ្រព្យសម្បត្តិបានមួយចំនួនប៉ុន្តែទាហានថៃនៅតែបន្តហ៊ុមព័ទ្ធបន្ទាលួស និងដាក់ទុកគឺនរបិទជិត ធ្វើឱ្យខ្ញុំមិនអាចចូលទៅផ្ទះរបស់ខ្ញុំបានទេ។ ខ្ញុំពិបាកចិត្តខ្លាំងណាស់ ព្រោះខ្ញុំនិងកូនៗមិនមានដី និងផ្ទះសម្រាប់រស់នៅបន្តទៀត។ បច្ចុប្បន្ននេះ ខ្ញុំបានដឹងតាមរយៈមេភូមិសង្គមថ្មីដែលបានទូរស័ព្ទមកប្រាប់ខ្ញុំថា ទាហានថៃបានបន្តឈូសឆាយផ្ទះរបស់ខ្ញុំចោលអស់ហើយ។ មិនត្រឹមតែប៉ុណ្ណោះ ទាហានថៃនៅតែបន្តហ៊ុមព័ទ្ធ និងឈូសឆាយលើដីរបស់ខ្ញុំនៅតំបន់អូរភ្នុកដីរ។ បន្ទាប់ពីបានដឹងដំណឹងនេះ ខ្ញុំមានអារម្មណ៍សោកសៅ រកគិតអ្វីមិនចេញ ព្រោះខ្ញុំបានបាត់បង់ទ្រព្យសម្បត្តិ ដីធ្លី និងផ្ទះអស់ទៅហើយ។ ខ្ញុំចង់ត្រឡប់ទៅរស់នៅភ្នំផ្ទះរបស់ខ្ញុំវិញដូចប្រជាជនដទៃ ប៉ុន្តែខ្ញុំមិនមានដី និងផ្ទះនៅសេសសល់ទៀតទេ។ ខ្ញុំបានដឹងថា ទាហានថៃកំពុងឈរជើងខុសច្បាប់ហ៊ុមព័ទ្ធបន្ទាលួស ដាក់ទុកគឺនរព័ទ្ធយកដី និងផ្ទះរបស់ប្រជាជនក្នុងភូមិសង្គមថ្មីចំនួន២៧ គ្រួសារទៀត។ ខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាលបន្តជួយដោះស្រាយបញ្ហាជម្លោះព្រំដែនជាមួយថៃឱ្យបានឆាប់រហ័ស និងទាមទារយកដីធ្លី ផ្ទះសម្បែងរបស់ប្រជាជនក្នុងឃុំថ្មដា មកវិញ។



ជំរំជនភៀសសឹកស្ថិតនៅវត្តប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហ៊ឹម ស្នាះ អតីតកងជ័ព ក្នុងកងពលលេខ៧១ តំបន់ថ្មជា

ចាន់ ណារិទ្ធ



ហ៊ឹម ស្នា អាយុ៨៨ឆ្នាំ រស់នៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកកាលវែង ខេត្តពោធិសាត់។ បច្ចុប្បន្ន ស្នា មកស្នាក់នៅជំរំជនភៀសសឹកវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ ស្ថិតនៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកកាលវែង ខេត្តពោធិសាត់ បណ្តោះអាសន្ន ដោយសារតែការឈ្លានពានរបស់កងទ័ពថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហ៊ឹម ស្នា អាយុ៨៨ឆ្នាំ កើតនៅភូមិបឹងទឹង ឃុំទង្គ្រ ឡាច ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកកាលវែង ខេត្តពោធិសាត់។ ខ្ញុំមានឪពុកឈ្មោះ ហ៊ុម ហ៊ឹម អាយុ៨១ឆ្នាំ មានស្រុកកំណើតនៅភូមិជ័យធំ ឃុំជ័យធំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងម្តាយឈ្មោះ គិន ធារី អាយុ៧៥ឆ្នាំ។ ខ្ញុំមានបងប្អូនបង្កើតចំនួន ១២នាក់ គឺប្រុស២នាក់ និងស្រី១០នាក់។ បងប្អូនស្រីរបស់ខ្ញុំបានស្លាប់ចំនួន៧នាក់ហើយ។ ខ្ញុំគឺជាកូនទី៥ នៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ឆាង សាំង អាយុ៨២ឆ្នាំ មានស្រុកកំណើតនៅភូមិកំប៉ាង ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិសាត់។ ខ្ញុំមានកូនចំនួន៥នាក់ គឺប្រុសម្នាក់ និងស្រី៤នាក់ ហើយសព្វថ្ងៃខ្ញុំប្រកបមុខរបរធ្វើចម្ការ។

កាលពីក្មេងខ្ញុំរៀនបានត្រឹមថ្នាក់ទី២ នៅសាលាបឋមសិក្សាភូមិបឹងទឹង។ ក្រោយមក ខ្ញុំបានឈប់រៀនដោយសារតែឪពុកម្តាយខ្ញុំត្រូវផ្ទាល់នៅប្រកបរបររកស៊ីរាយមង និងនេសាទនៅខេត្តកោះកុង ហើយបាននាំខ្ញុំមករស់នៅជាមួយ។ ពេលនោះ ខ្ញុំមិនបានត្រឡប់ទៅរៀនសូត្រនៅស្រុកកំណើតវិញទេ។ ខ្ញុំបាននៅជួយឪពុកម្តាយធ្វើស្រែនិងចិញ្ចឹមបង្គា។ នៅឆ្នាំ ១៩៩៦ ខ្ញុំមានអាយុ១៥ឆ្នាំ ពេលនោះខ្ញុំស្ម័គ្រចិត្តចូលបម្រើកងទ័ពពិសេសនៅក្នុងកងពលលេខ៥ មានទីតាំងនៅតំបន់ថ្មជ្រាំង ខេត្តកោះកុង ដែលមានប្រធានកងពលឈ្មោះ គឹម សុខុន និងអនុកងពលឈ្មោះ ស្វាយ ញាន។ បន្ទាប់មក កងពលលេខ៥ ត្រូវបានបំបែកជា៣វរសេនាធំ គឺមានវរសេនាធំលេខ១៥ វរសេនាធំលេខ១៦ និងវរសេនាធំលេខ១៧។ វរសេនាធំលេខ១៥ ត្រូវបានគឹម សុខុនបំបែកឱ្យទៅឈរជើងការពារនៅជាប់ព្រំប្រទល់តាកែនកោះស្វា ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត។ ពេលនោះ ខ្ញុំស្ថិតនៅក្នុងវរសេនាធំលេខ១៦ ឈរជើងនៅស្រុកថ្មជ្រាំង ខេត្តកោះកុង។ ចំណែកវរសេនាធំលេខ១៧ ត្រូវបានគឹម សុខុនបំបែកឱ្យទៅឈរជើងការពារនៅឃុំអណ្តូងទឹក ស្រុកបទុមសាគរ ខេត្តកោះកុង។ ខ្ញុំបានហ្វឹកហ្វឺននៅតំបន់ថ្មជ្រាំងបានរយៈពេល១ឆ្នាំ រួចបានលាឈប់ពី

កងទ័ពវិញ ដោយសារតែឪពុកម្តាយបានផ្ញាស់ទៅរកស៊ីនៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ពេលចូលមកដល់ឃុំថ្មដាដំបូង ឪពុកម្តាយរបស់ខ្ញុំបានទៅរស់នៅភូមិសង្គមថ្មី ឃុំថ្មដា ដោយបានប្រកបមុខរបរដើរកកាប់ខ្ទឹមច័ន្ទត្រីស្នា ដើម្បីយកទៅលក់ឱ្យប្រជាជនថៃ។ ចំណែកម្តាយខ្ញុំនៅផ្ទះចិញ្ចឹមសត្វជ្រូក មាន់ ទា និងកាប់ឆ្អាល្រៃ ដើម្បីដាំស្រូវទុកផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ។ បន្ទាប់ពីជួយការងារឪពុកម្តាយខ្ញុំបានប្រហែល២ទៅ៣ខែ ខ្ញុំបានសម្រេចចិត្តសុំឪពុកម្តាយចូលបម្រើកងទ័ពនៅក្នុងកងវរសេនាតូចលេខ១០៤ ចំណុះឱ្យកងពលលេខ៧១ និងមានប្រធានកងពលឈ្មោះ គឹម ពៅ (អតីតកងទ័ពខ្មែរក្រហម)។ កងវរសេនាតូចលេខ១០៤ របស់ខ្ញុំមានកម្លាំងប្រហែល ១០០នាក់។ បន្ទាប់មកកងវរសេនាតូចលេខ១០៤ ត្រូវបានលោក គឹម ពៅ ផ្ញាស់ឱ្យទៅឈរជើងការពារនៅទីតាំងចម្ការចេក (៣០៣) ស្ថិតនៅភាគខាងលិចភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលចម្ងាយប្រមាណ២០គីឡូម៉ែត្រពីរង្វង់មូលឃុំថ្មដា និងមានព្រំប្រទល់ជាប់ជាមួយខេត្តកោះកុង និងភូមិសុជាន់ហ៊ីន ខេត្តត្រាតប្រទេសថៃ។ ខណៈពេលខ្ញុំកំពុងដើរល្បាត ខ្ញុំបានឃើញកុងត្រូលរបស់ទាហានថៃបានហោះកុងត្រូលនៅតំបន់ថ្មដាតូច ដែលមានចម្ងាយប្រហែល៥០០ម៉ែត្រ ពីកុងត្រូលរបស់កងទ័ពកម្ពុជា។ ទាហានថៃប្រហែល៥០នាក់ (កងហ) បានឡើងមកដាក់កុងត្រូលថ្មីចូលមកក្នុងដែនដីរបស់ប្រទេសកម្ពុជា ប៉ុន្តែមិនមានការផ្ទុះអាវុធឡើយ។ នៅចុងឆ្នាំ១៩៩៧ ឪពុកម្តាយខ្ញុំបានរៀបចំឱ្យខ្ញុំមានគ្រួសារ។

នៅឆ្នាំ១៩៩៨ ខណៈពេលកំពុងដើរល្បាតនៅតាមព្រំដែន ខ្ញុំបានដើរជាន់មីនដែលនៅសេសសល់ពីសង្គ្រាមរវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហម។ ខ្ញុំមានអារម្មណ៍តក់ស្លុតជាខ្លាំងហើយខ្ញុំបានស្រែកប្រាប់ទៅកាន់មិត្តរួមអាវុធថា «ពួកម៉ាក់អើយ! ឯងដើរជាន់មីនហើយ ជួយយកឯងទៅមន្ទីរពេទ្យផង»។ មិត្តរួមអាវុធមិនទាន់ហ៊ានចូលមកជួយខ្ញុំភ្លាមៗនោះទេព្រោះខ្លាចមានមីនដែលនៅសេសសល់ផ្ទុះបន្តែមទៀត។ បន្ទាប់ពីយកម៉ាស៊ីនមកវាមីនរួច ខ្ញុំត្រូវបានមិត្តភក្តិរួមអាវុធដឹកយកទៅព្យាបាលនៅមន្ទីរពេទ្យ ស្ថិតក្នុងខេត្តត្រាត ប្រទេសថៃ។ នៅអំឡុងពេលនោះដើងខាងស្តាំរបស់ខ្ញុំមានសភាពធ្ងន់ធ្ងរខ្លាំង ទើបពេទ្យថៃបានសម្រេចចិត្តកាត់ដើងខាងស្តាំខ្ញុំម្ខាងចោល។ បន្ទាប់ពីសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យខេត្តត្រាត បានរយៈពេល២១ថ្ងៃ ខ្ញុំបានសុំចេញពីមន្ទីរពេទ្យត្រឡប់មកសម្រាកព្យាបាលនៅផ្ទះរបស់ខ្ញុំ ស្ថិតនៅក្នុងភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់វិញ។ ក្រោយពីខ្ញុំសម្រាកព្យាបាលនៅផ្ទះអស់រយៈពេល ២ទៅ៣ខែ របួសនៅជើងរបស់ខ្ញុំបានធូរស្បើយជាងមុន។ បន្ទាប់ពីឃើញខ្ញុំមិនអាចចូលបម្រើអង្គភាពវិញ បានប្រធានកងពលគឺមពៅ ដកខ្ញុំមកនៅអតីតយុទ្ធជនដោយទទួលបានប្រាក់បៀវត្សជារៀងរាល់ខែ។ ខ្ញុំបានបន្តសម្រាកព្យាបាលនៅផ្ទះអស់រយៈពេល២ឆ្នាំទើបអាចចេញប្រកបមុខរបរធ្វើចម្ការ ដូចជា ដាំកៅស៊ូ ដាំដើមចន្ទី ដាក់ជីតាមដើមឈើ និងដើរស៊ីឈ្នួលគ្រាយព្រៃ។

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ទាហានថៃបានប្រើគ្រឿងចក្រចូលមកឈូសឆាយធ្វើផ្លូវចាប់ពីកង៥០ រហូតទៅទល់នឹងបន្ទាយអូរភ្នកដីរ។ ខណៈពេលនោះកងកម្លាំងរបស់យោធភូមិភាគទី៥ របស់ខេត្តមសេនីយ៍ឯក ឯក សំអូនបានបញ្ជូនឱ្យកម្លាំងឈរជើងការពារយ៉ាងមុឺងម៉ាត់មិនឱ្យទាហានថៃចូលមកឈូសឆាយចូលមកក្នុងទឹកដីរបស់ប្រទេសកម្ពុជាទេ។ បន្ទាប់មក នៅតាមព្រំដែនថ្មដាចាប់ផ្តើមមានភាពតានតឹងជាមួយទាហានថៃ ដោយសារតែទាហានថៃនៅតែបន្តឈូសឆាយធ្វើផ្លូវចូលមកក្នុងភូមិសាស្ត្រអូរភ្នកដីរ ដែលជាទឹកដីរបស់ប្រទេសកម្ពុជា។ កងទ័ពកម្ពុជាដែលឈរជើងការពារនៅព្រំដែនថ្មដា បានទំនាក់ទំនងទៅកាន់មេភូមិសង្គមថ្មីឈ្មោះ រ៉ែត និងមេឃុំថ្មដាឈ្មោះ ព្រុំ ង៉ុនឱ្យជម្លៀសប្រជាជនទៅរកកន្លែងសុវត្ថិភាពជាបន្ទាន់ ពីព្រោះទាហានថៃអាចនឹងបើកការវាយប្រហារចូលមកឃុំថ្មដា គ្រប់ពេលវេលា។ ឪពុកម្តាយ

របស់ខ្ញុំបានដឹះរថយន្តឈ្នួលភៀសខ្លួនទៅខេត្តកំពត ដើម្បីទៅស្នាក់នៅជាមួយបងប្អូនខាងឪពុកខ្ញុំបណ្តោះអាសន្ន។ ចំណែកខ្ញុំ និងប្រពន្ធបានដឹកក្មួយដែលមានជំងឺឈាមសស៊ីឈាមក្រហមយកទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់។ នៅវេលាម៉ោង ៥ និង២នាទីព្រឹក ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០២៥ ខ្ញុំទទួលបានដំណឹងថា ទាហានថៃបានបើកការវាយប្រហារដោយកាំភ្លើងធំសរុបចំនួន១៧គ្រាប់ មកលើទីតាំងភូមិសាស្ត្រអូរភ្កដំរី និងភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលបណ្តាលឱ្យខូចខាតដល់ដំណាំ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនប៉ុន្តែមិនបណ្តាលឱ្យកងទ័ពស្លាប់ឬរងរបួសឡើយ។ បន្ទាប់ពីសភាពការណ៍នៅតាមព្រំដែនមានសភាពស្ងប់ស្ងាត់ឡើងវិញ ក្មួយរបស់ខ្ញុំក៏បានធូរស្បើយពីជំងឺ ហើយខ្ញុំនិងប្រពន្ធបានដឹះរថយន្តឈ្នួលវិលត្រឡប់មករស់នៅផ្ទះស្ថិតនៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់វិញ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ នៅតាមព្រំដែនស្ថិតនៅក្នុងឃុំថ្មដា ចាប់ផ្តើមមានភាពតានតឹងសាឡើងវិញ។ ទាហានថៃចាប់ផ្តើមសម្រុកដឹកលេណដ្ឋាននៅតាមព្រំដែនចល័តទាហាន និងដឹកជញ្ជូនសព្វាវុធធុនធ្ងន់មកទុកនៅតាមព្រំដែនសាជាថ្មីម្តងទៀត។

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំបានឃើញជ្រូនថៃជាច្រើនបានហោះឆ្លៃលនៅតាមបណ្តាយព្រំដែន និងបានចូលមកឈ្លបយកការណ៍នៅក្នុងដែនដីរបស់ប្រទេសកម្ពុជា។ ដោយឃើញសភាពការណ៍នៅតាមព្រំដែនមានសភាពតានតឹងមេភូមិឈ្មោះ រ៉ែត និងមេឃុំឈ្មោះ ព្រំ ង៉ុនបានប្រកាសជ្រាប់ប្រជាជនឱ្យភៀសខ្លួនទៅរកកន្លែងមានសុវត្ថិភាព។ ពេលនោះខ្ញុំ និងប្រពន្ធមិនទាន់ជម្លៀសចេញពីភូមិទេ ព្រោះគិតថាមិនមានការវាយប្រយុទ្ធគ្នា។

នៅវេលាម៉ោង៥ និង១៥នាទីព្រឹក ត្រូវនឹងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ មុននឹងទាហានថៃបើកការវាយប្រហារចូលមកក្នុងឃុំថ្មដា ខ្ញុំបានឃើញទាហានថៃបាញ់គ្រាប់កាំភ្លើងទៅលើមេឃជាច្រើនគ្រាប់ ដើម្បីកំណត់ទីតាំងឈរជើងរបស់វីរកងទ័ពកម្ពុជា។ បន្ទាប់ពីបាញ់គ្រាប់កាំភ្លើងបានប្រហែល ២ទៅ ៣ នាទី ទាហានថៃបានចាប់ផ្តើមបាញ់ផ្លោងដោយកាំភ្លើងត្បាល់ទំហំ៦០មីលីម៉ែត្រ កាំភ្លើងត្បាល់ទំហំ៨០មីលីម៉ែត្រ និងបាញ់ចេញពីនាវចម្បាំងជាច្រើនគ្រាប់ទៀតចូលមកក្នុងភូមិសាស្ត្រអូរភ្កដំរី ស្ថិតនៅក្នុងភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បន្ទាប់ពីឮសំឡេងគ្រាប់ផ្លោងផ្ទុះជាបន្តបន្ទាប់ ខ្ញុំបានដាស់ប្រពន្ធឱ្យរៀបចំអីវ៉ាន់ រួចបានចុះពីលើផ្ទះទៅប្រលែងមាន់ចេញពីទ្រុង ហើយបានឡើងដឹះម៉ូតូចេញពីផ្ទះ សំដៅទៅរកកន្លែងដែលមានសុវត្ថិភាព។ បន្ទាប់ពីដឹះម៉ូតូចេញផុតពីភូមិសង្គមថ្មីបានបន្តិច ខ្ញុំបានឮសូរសំឡេងគ្រាប់ផ្លោងរបស់ទាហានថៃនៅតែបន្តបាញ់ផ្លោងចូលមកក្នុងភូមិសាស្ត្រអូរភ្កដំរីឥតឈប់ឈរ។ ខ្ញុំដឹះម៉ូតូដឹកប្រពន្ធអស់រយៈពេលប្រហែល២ម៉ោង ទើបទៅដល់វត្តគិរីបុទុម្ពរ ហៅវត្តប្រម៉ោយ ដែលមានទីតាំងស្ថិតនៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំ និងប្រពន្ធបានស្នាក់បណ្តោះអាសន្ននៅក្នុងវត្តគិរីបុទុម្ពរ ហៅវត្តប្រម៉ោយ បានប្រហែលមួយសប្តាហ៍។ ពេលនោះសភាពការណ៍នៅតាមព្រំដែនកាន់តែមានភាពតានតឹងខ្លាំងទៅៗ។ អភិបាលខេត្តពោធិ៍សាត់ឈ្មោះ ខូយ រីដា បានប្រកាសជ្រាប់ប្រជាជនដែលកំពុងស្នាក់ក្នុងវត្តឱ្យរំសាយទៅស្នាក់នៅជាមួយបងប្អូន នៅតាមបណ្តាខេត្តផ្សេងៗ បណ្តោះអាសន្នសិនពីព្រោះនៅតាមព្រំដែនកំពុងតែមានសភាពតានតឹងខ្លាំង។ បន្ទាប់ពីឮប្រសាសន៍របស់អភិបាលខេត្តពោធិ៍សាត់ ខូយ រីដា ខ្ញុំ និងប្រពន្ធបានដឹះម៉ូតូចាកចេញពីវត្តគិរីបុទុម្ពរ ហៅវត្តប្រម៉ោយ សំដៅទៅស្នាក់នៅ ទីរួមខេត្តពោធិ៍សាត់មួយរយៈ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ សភាពការណ៍នៅតាមបណ្តាយព្រំដែនក្នុងឃុំថ្មដា មានសភាពស្ងប់ស្ងាត់ឡើងវិញ។ ខ្ញុំ និងប្រពន្ធបានដឹះម៉ូតូចាកចេញពីទីរួមខេត្តពោធិ៍សាត់ ដើម្បីវិលត្រឡប់មកនៅផ្ទះស្ថិតនៅឃុំថ្មដាវិញ។ ប៉ុន្តែពេលខ្ញុំមកដល់ថ្មដា ខ្ញុំឃើញទាហានថៃបានដាក់ទូរកុងតឺន័រ និងរាយបន្ទាល់ស

ព័ទ្ធយកដី និងផ្ទះរបស់ប្រជាជនខ្មែរអស់ជាច្រើនខ្នង។ បន្ទាប់ពីឃើញបែបនេះ ខ្ញុំ និងប្រពន្ធបានបន្តដំណើរទៅផ្ទះរបស់ខ្ញុំ។ ផ្ទះរបស់ខ្ញុំមានចម្ងាយប្រហែលពាក់ គីឡូម៉ែត្រ ពីទីតាំងដែលទាហានថៃដាក់ទូរកុងតឺន័រ។ ពេលខ្ញុំដុះម៉ូតូចូលទៅដល់ផ្ទះ ខ្ញុំបានបាត់បង់សម្ភារប្រើប្រាស់ដូចជា ការបិតចប ធុងទឹក ស៊ីទែនទឹក និងបាត់មាន់ចំនួន៩០ក្បាល។ បន្ទាប់ពីឃើញសភាពការណ៍នៅតាមព្រំដែននៅមានសភាពតូរឱ្យព្រួយបារម្ភព្រោះទាហានបានដាក់កាំភ្លើងតម្រង់ចូលមកក្នុងភូមិសង្គមថ្មី ឃុំថ្មដា ខ្ញុំ និងប្រពន្ធមិនទាន់ហ៊ានចូលទៅរស់នៅក្នុងផ្ទះទេ។ ខ្ញុំនិងប្រពន្ធបានសម្រេចចិត្តទៅស្នាក់នៅជំរំជនភៀសសឹកស្ថិតក្នុងវិទ្យាល័យ ហ៊ុនសែនប្រម៉ោយបណ្តោះអាសន្នសិន។ នៅអំឡុងពេលខ្ញុំមកស្នាក់នៅជំរំភៀសសឹក ខ្ញុំទទួលបានអាហារហូបចុកគ្រប់គ្រាន់មិនមានការខ្វះខាតឡើយ និងមានទឹកមានភ្លើង មានបង្គន់អនាម័យ និងមានគ្រូពេទ្យចាំព្យាបាលជំងឺ។ ដោយឡែកដលវិបាករបស់ខ្ញុំដែលរស់នៅក្នុងតង់គឺមានសភាពក្តៅខ្លាំងនៅរដូវប្រាំង។ ខ្ញុំនឹកផ្ទះសម្បែងខ្ញុំណាស់។ បច្ចុប្បន្ន ភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ត្រូវបានទាហានថៃចូលមកឈ្លានពាន និងកាន់កាប់ទឹកដីចំនួន២ទីតាំងគឺ ទីតាំងអូរកង់ឈូប និងច្រកអន្តរជាតិថ្មដា។ ចំណែកភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ទាហានថៃបានចូលមកឈ្លានពាននិងកាន់កាប់ទឹកដីចំនួន២ទីតាំងគឺ តំបន់អូរភ្លុកដំរី និងច្រកច១។



ថ្នាក់រៀនបណ្តោះអាសន្ន នៅមណ្ឌលជនភៀសសឹក ស្ថិតក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជនភៀសសឹក ដែលកំពុងរង់ចាំភាពយុត្តិធម៌ និងឆាប់បានទិលត្រឡប់ទៅរស់នៅផ្ទះសម្បែងខ្លួនវិញ

ម៉ឿន ស្រីណុច

ខ្ញុំឈ្មោះ អ៊ុង ណាត ភេទស្រី អាយុ៥០ឆ្នាំ កើតនៅក្នុងភូមិត្រពាំងកោះ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ អ៊ុង វន (ស្លាប់) និងម្តាយឈ្មោះ គង់ មុំ (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់ ក្នុងនោះមានស្រី៤នាក់ ហើយខ្ញុំជាកូនទី៥ក្នុងគ្រួសារ។

កាលនៅវ័យកុមារ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៤ នៅសាលាក្នុងភូមិត្រពាំងកោះ។ បន្ទាប់ពីឈប់រៀនខ្ញុំបាននៅជួយធ្វើស្រែចម្ការឪពុកម្តាយ។ ក្រៅពីជួយការងារឪពុកម្តាយ ខ្ញុំបានដើររកក្តាមរកខ្យងយកទៅលក់ ដើម្បីបានប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។

នៅឆ្នាំ២០០៧ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ ឈូក ថន។ ប្តីរបស់ខ្ញុំមានស្រុកកំណើតនៅខេត្តកំពត។ បន្ទាប់ពីរៀបការរួច ខ្ញុំបានធ្វើដំណើរចាកចេញពីខេត្តតាកែវតាមមករស់នៅជាមួយប្តីនៅព្រំដែនថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ប្តីប្រពន្ធខ្ញុំមានកូនស្រីចំនួន២នាក់។ ប្តីរបស់ខ្ញុំគឺជាកងទ័ពក្នុងកងការពារព្រំដែនគោកលេខ៥០១ ដែលត្រូវបានរដ្ឋាភិបាលបញ្ជូនចេញពីខេត្តកំពតឱ្យមកការពារនៅតាមព្រំដែនថ្មដា តាំងពីឆ្នាំ១៩៩៨មកម៉្លេះ។ ប្រធានកងពលប្តីរបស់ខ្ញុំឈ្មោះ សុខ អ៊ុល (ស្លាប់) និងអនុប្រធានឈ្មោះ ហ៊ាន (ឈ្មោះហៅក្រៅ)។ ប្តីរបស់ខ្ញុំនៅកងល្បាតទី២ មានតួនាទីការពារនៅទីតាំងចម្ការចេកដែលស្ថិតនៅទិសខាងលិចក្នុងភូមិសាស្ត្រភូមិសង្គមថ្មី ឃុំថ្មដា មានចម្ងាយប្រហែល២០គីឡូម៉ែត្រពីរង្វង់មូលឃុំថ្មដា និងមានចម្ងាយប្រហែល១២គីឡូម៉ែត្រ



អ៊ុង ណាត អាយុ៥០ឆ្នាំ ភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បច្ចុប្បន្ន ណាត មកស្នាក់នៅជីវិតភៀសសឹក, វិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ ស្ថិតនៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ បណ្តោះអាសន្ន ដោយសារការឈ្លានពានទឹកដីពីកងទ័ពថៃ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីច្រកអន្តរជាតិថ្មដា និងមានព្រំប្រទល់ជាប់ខេត្តពោធិ៍សាត់ ខេត្តកោះកុង។ ខ្ញុំបានចូលទៅរស់នៅក្នុងបន្ទាយអនុសេនាធំលេខ២ នៅចំណុចចម្ការចេក។ អំឡុងពេលខ្ញុំមករស់នៅចម្ការចេកមានក្រុមគ្រួសារកងទ័ពប្រហែល៨-១០គ្រួសារប៉ុណ្ណោះ។ ខ្ញុំរស់នៅហូបរបបអង្គររបស់កងទ័ព ហើយមិនបានប្រកបមុខរបរអ្វីនោះទេ។ ជាញឹកញាប់ ខ្ញុំបានដើរឡើងទៅលេងលើភ្នំតយគន់ឬភ្នំតាកុច (នៅម្តុំចម្ការចេក) ហើយខ្ញុំបានមើលឃើញទឹកដីរបស់ប្រទេសថៃនៅខាងក្រោមភ្នំ។

នៅឆ្នាំ២០០៨ ពេលកើតមានជម្លោះប្រដាប់អាវុធរវាងកងទ័ពកម្ពុជា និងទាហានថៃនៅជុំវិញប្រាសាទព្រះវិហារ ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ក្នុងពេលជាមួយគ្នា ទាហានថៃបានទាំបក្ខពួកឡើងមកលើភ្នំគយគន់ហើយទាហានថៃបានបើកខ្ទមម្ភាគចក្រមកទម្លាក់ស្បៀង និងរបស់របរបម្រុងនឹងសាងសង់ប៉ុស្តិ៍យាមនៅលើភ្នំគយគន់។ ប៉ុន្តែកងទ័ពកម្ពុជាបានបណ្តេញទាហានថៃចុះទៅក្រោមខាងទឹកដីប្រទេសថៃវិញ។ ទាហានថៃតែងតែមានមហិច្ឆតាចង់ឡើងមកគ្រប់គ្រង និងកាន់កាប់នៅលើភ្នំគយគន់ប៉ុន្តែមិនបានសម្រេចឡើយ។

អំឡុងពេលដុះអាវុធនៅប្រាសាទព្រះវិហារកងទ័ពកម្ពុជានៅការពារតាមព្រំដែនថ្មដាបានប្រុងប្រៀបនិងត្រៀមខ្លួនរួចជាស្រេចក្នុងការការពារបូរណភាពទឹកដីរបស់ប្រទេសកម្ពុជាក្នុងតំបន់ថ្មដា ហើយមិនអាចឱ្យទាហានថៃឡើងមកគ្រប់គ្រងបានជាដាច់ខាត។ ចំណែកខ្ញុំ និងប្រពន្ធៗរបស់កងទ័ពទាំងអស់បានត្រៀមអង្ករ និងវេចខ្ចប់ម្ហូបអាហារទុកត្រៃងមានការដុះអាវុធនៅតំបន់ថ្មដា។ ក្រោយមកសភាពការណ៍នៅព្រំដែនថ្មដាប្រែមកជាស្ងប់ស្ងាត់ធម្មតា។ នៅពេលស្ងប់ស្ងាត់សង្គ្រាមនៅប្រាសាទព្រះវិហារ ខ្ញុំបានបន្តការរស់នៅចម្ការចេក ហើយទាហានថៃមិនហ៊ានឡើងមកលើភ្នំគយគន់ទៀតទេ។ នៅពេលខ្ញុំឈឺ និងត្រូវការទិញរបស់របរប្រើប្រាស់ផ្សេងៗ ខ្ញុំត្រូវដើរដោយថ្មើរជើងចូលទៅទិញនៅផ្សារក្នុងខេត្តត្រាតប្រទេសថៃ។ ខ្ញុំបានចំណាយរយៈពេលប្រហែល១-២ម៉ោង ដើរទៅតាមខ្នងភ្នំទម្រាំធ្វើដំណើរចុះដល់ផ្លូវកៅស៊ូរបស់ប្រទេសថៃ។ រៀងរាល់ពេលខ្ញុំត្រូវចូលទៅខាងថៃ ខ្ញុំតែងតែមានប្តីទៅជាមួយ និងមានកងទ័ពកម្ពុជាជូនធ្វើដំណើរពីទីតាំងកងល្បាតកម្ពុជាដោយឆ្លងកាត់ត្រង់តំបន់សរវាងកងទ័ពកម្ពុជា និងទាហានថៃរួចទាហានថៃបាននាំខ្ញុំធ្វើដំណើរបន្តទៅដល់ផ្សារថៃ។ ចម្ងាយពីទីតាំងកងល្បាតការពារព្រំដែនកម្ពុជាទៅទីតាំងកងល្បាតរបស់ទាហានថៃមានចម្ងាយប្រហែល៣០០ម៉ែត្រ។ អំឡុងពេលជាមួយគ្នា ខ្ញុំមិនសូវបានដើរមកតំបន់ច្រកអន្តរជាតិថ្មដានោះទេព្រោះមិនមានប្រជាជនលក់ដូររបស់របរហើយផ្លូវដំណើរសុទ្ធតែព្រៃពិបាកណាស់។

នៅឆ្នាំ២០១៨ បន្ទាយអនុសេនាធំលេខ២ នៅចម្ការចេកចាប់ផ្តើមមានក្រុមគ្រួសារកងទ័ពកម្ពុជាចូលមករស់នៅបន្តបន្ទាប់សរុបប្រហែល៣០គ្រួសារ។ ផ្លូវធ្វើដំណើរចាប់ពីចម្ការចេកទៅកាន់ច្រកអន្តរជាតិថ្មដាបានសាងសង់ និងមានភាពងាយស្រួលធ្វើដំណើរជាងមុន។ ខ្ញុំបានចេញចូលមកទិញម្ហូបអាហារ និងរបស់របរនៅខាងថ្មដាវិញ។

នៅឆ្នាំ២០២១ ប្តីរបស់ខ្ញុំបានចូលនិវត្តន៍ពីកងទ័ព និងបានប្រកបមុខរបរធ្វើចម្ការ ដាំដុះដំណាំបន្តិចបន្តួចនៅជុំវិញផ្ទះ។ ខ្ញុំ និងប្តីរស់នៅក្នុងផ្ទះតែ២នាក់។ ចំណែកកូនៗរបស់ខ្ញុំកំពុងសិក្សារៀនសូត្រនៅវិទ្យាល័យហ៊ុនសែនប្រម៉ោយ និងស្នាក់នៅក្នុងឃុំប្រម៉ោយ ស្រុកភ្នំលែង ខេត្តពោធិ៍សាត់។ នៅមុនពេលកើតមានសង្គ្រាមរវាងកងទ័ពកម្ពុជា និងទាហានថៃ ខ្ញុំ និងប្រជាជនទាំងអស់ក្នុងឃុំថ្មដារស់នៅប្រកបដោយភាពសប្បាយរីករាយ។ ខ្ញុំប្រកបមុខរបរចិញ្ចឹមជីវិតមិនមានការខ្វះឡើយ។ ខ្ញុំបានរស់នៅដោយភាពស្ងប់សុខ និងមិនមានការលំបាកឡើយ។

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំបានដឹងថាទាហានថៃបានជ្រាញមកលើទីតាំងឈរជើងរបស់កងទ័ពកម្ពុជានៅខេត្តព្រះវិហារ និងខេត្តឧត្តរមាន-ជ័យ។ បន្ទាប់មក ប្រជាជនរស់នៅក្នុងឃុំថ្មដាបានចាប់ផ្តើមភៀសខ្លួនទៅកាន់ទីកន្លែងមានសុវត្ថិភាព។ រីឯខ្ញុំ និងក្រុមគ្រួសារកងទ័ពរស់នៅចម្ការចេកមិនទាន់បានភៀសខ្លួននៅឡើយទេព្រោះគិតថានៅព្រំដែនថ្មដាប្រហែលជាមិនមានការដុះឡើយ។ ខ្ញុំ និងប្តីបានដើរកត្រើនៅតាមអូរនៅចម្ការចេកធម្មតា។ នៅយប់ថ្ងៃដដែល ទាហានថៃបានប្រើប្រាស់យន្តហោះគ្មានមនុស្សបើក (ដ្រូន) បង្ហោះចូលមកទីតាំងចម្ការចេក និងត្រប់ទិសទីក្នុងឃុំថ្មដា។

នៅព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំ និងប្តីបានដឹងថាសភាពការណ៍នៅតាមព្រំដែនថ្មដាមានភាព

តានតឹង ទើបខ្ញុំ និងប្តីបានធ្វើដំណើរតាមម៉ូតូដិះចេញពីចម្ការចេកសំដៅមកច្រកអន្តរជាតិថ្នដាដើម្បីទៅកាន់កន្លែងមានសុវត្ថិភាព។ នៅពេលខ្ញុំធ្វើដំណើរនៅតាមផ្លូវ ស្រាប់តែទាហានថៃបានផ្ទោងគ្រាប់ចូលតំបន់អូរភ្លុកដរី ស្ថិតក្នុងភូមិឯកភាព ឃុំថ្នដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ភ្លាមៗនោះសំឡេងគ្រាប់ផ្ទោង និងគ្រាប់កាំភ្លើងផ្ទុះឡើងនៅថ្នដាធ្វើឱ្យខ្ញុំភិតភ័យយ៉ាងខ្លាំង ព្រោះខ្ញុំ និងប្តីកំពុងនៅលើផ្លូវធ្វើដំណើរខ្លាចគ្រាប់ផ្ទោងរបស់ទាហានថៃខ្ទាតត្រូវ។ ខ្ញុំនិងប្តីបានធ្វើដំណើរមកកាន់ជំរំភៀសសឹកក្នុងឃុំប្រម៉ោយដោយសុវត្ថិភាព។ ខ្ញុំបានស្នាក់នៅក្នុងជំរំភៀសសឹកអស់រយៈពេលមួយសប្តាហ៍ទើបធ្វើដំណើរត្រឡប់ទៅផ្ទះនៅចម្ការចេកវិញ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃបានបង្កសង្គ្រាមមួងទៀតនៅតាមព្រំដែនខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ។ នៅតាមព្រំដែនថ្នដាមិនទាន់មានផ្ទុះអាវុធទេ។ ខ្ញុំបានគិតថាប្រហែលជាមិនការផ្ទុះអាវុធទៀតនោះទេ ទើបខ្ញុំមិនទាន់ភៀសខ្លួនចេញពីផ្ទះដូចរាល់ដង។ បន្ទាប់មកទាហានថៃបានប្រើប្រាស់យន្តហោះគ្មានមនុស្សបើក (ដ្រូន) បង្ហោះចូលមកក្នុងឃុំថ្នដាទ្វាត់ខ្សែងទាំងយប់ទាំងថ្ងៃ។ មិនតែប៉ុណ្ណោះ ទាហានថៃបានបាញ់ផ្សែងពុលចូលមកតំបន់ថ្នដាទាំងដែលមានប្រជាជនកំពុងរស់នៅពេញក្នុងឃុំថ្នដា។

នៅព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃបានចាប់ផ្តើមផ្ទោងគ្រាប់ចូលតំបន់ច្រកអន្តរជាតិថ្នដា អគារកាស៊ីណូថ្នដា និងតំបន់អូរភ្លុកដរី។ ខ្ញុំ និងប្តីបានរៀបចំរបស់របរចាំបាច់មួយចំនួន និងសម្លៀកបំពាក់បន្តិចបន្តួចភៀសខ្លួនតាមម៉ូតូចាកចេញពីផ្ទះនៅចម្ការចេកធ្វើដំណើរកាត់តាមកាស៊ីណូថ្នដា។ នៅពេលខ្ញុំមកដល់កាស៊ីណូថ្នដា ខ្ញុំបានឃើញអគារកាស៊ីណូត្រូវបានទាហានថៃទម្លាក់គ្រាប់ចំដំបូលកាស៊ីណូ និងជាក់ធ្លាក់មកលើដីខ្ទាត់ខ្ចាយ។ ខ្ញុំនិងប្តីបានធ្វើដំណើរបន្តមកដល់រង្វង់មូលច្រមុះជ្រូក ស្ថិតក្នុងភូមិសង្គមថ្មី ឃុំថ្នដា បានឃើញគូបលក់ដូរទាំងអស់របស់ប្រជាជនបិទទ្វារ។ ខ្ញុំបានឃើញគូបលក់សាច់ជ្រូក សាច់គោ គូបលក់បន្លែផ្លែឈើ ទូទឹកកក ត្រូវបានម្ចាស់ទុកចោលនៅពាសពេញតាមដងផ្លូវក្នុងឃុំថ្នដា ហើយមិនមានប្រជាជននៅតាមផ្ទះសម្បែងទៀតទេ។ នៅតាមផ្លូវខ្ញុំបានកាត់យកសាច់ជ្រូករបស់ប្រជាជនក្នុងឃុំថ្នដាប្រហែល១គីឡូក្រាមយកមកតាមខ្លួន។ នៅពេលធ្វើដំណើរតាមផ្លូវខ្ញុំមិនឃើញមានប្រជាជនជម្លៀសទៀតទេ។ ខ្ញុំឮតែសំឡេងគ្រាប់កងរំពងពេញព្រៃ។ នៅម៉ោង១១-១២ថ្ងៃត្រង់ ខ្ញុំនិងប្តីបានធ្វើដំណើរមកជំរំភៀសសឹកក្នុងឃុំប្រម៉ោយ។

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ សភាពការណ៍នៅថ្នដាមានសភាពស្ងប់ស្ងាត់ ប្តីរបស់ខ្ញុំបានធ្វើដំណើរចេញពីឃុំប្រម៉ោយត្រឡប់ទៅផ្ទះនៅចម្ការចេកវិញដើម្បីរៀបចំ និងជញ្ជូនរបស់របរមានម៉ាស៊ីនបូមទឹក ម៉ាស៊ីនកាត់ស្មៅ និងទ្រព្យសម្បត្តិផ្សេងៗទៀតយកចាក់សោដាក់ទុកនៅលើផ្ទះ។ បន្ទាប់មក នៅព្រំដែនថ្នដាចាប់ផ្តើមមានការប្រយុទ្ធខ្លាំងធ្វើឱ្យប្តីរបស់ខ្ញុំមិនអាចធ្វើដំណើរចេញមកតាមច្រកអន្តរជាតិថ្នដាបានទេ។ ប្តីរបស់ខ្ញុំបានធ្វើដំណើរទៅតាមផ្លូវចេញពីចម្ការចេកកាត់ទៅតាមផ្លូវក្នុងឃុំអូរសោមរួចធ្វើដំណើរបន្តមកកាន់ឃុំប្រម៉ោយ។ បន្ទាប់មកខ្ញុំ និងប្តីបានបន្តស្នាក់នៅក្នុងជំរំភៀសសឹករហូតដល់ស្ងប់ស្ងាត់សង្គ្រាម។

នៅខែមករា ឆ្នាំ២០២៦ អាជ្ញាធរស្រុកវាលវែងបានអនុញ្ញាតឱ្យប្រជាជនភៀសសឹកដែលមិនមានផ្ទះសម្បែងប្តីធ្លីដែលបាត់ពាល់ក្នុងសង្គ្រាមរវាងកងទ័ពកម្ពុជា និងទាហានថៃអាចវិលត្រឡប់ទៅរស់នៅក្នុងផ្ទះសម្បែងក្នុងឃុំថ្នដាវិញ ទើបខ្ញុំនិងប្តីបានធ្វើដំណើរចាកចេញពីជំរំភៀសសឹកទៅផ្ទះនៅចម្ការចេកវិញ។ នៅពេលទៅដល់ផ្ទះ ខ្ញុំមានការសោកស្តាយណាស់ព្រោះមាន់ទាដែលខ្ញុំធ្លាប់ និងបាត់អស់ពីផ្ទះដោយមិនដឹងថាត្រូវធ្លាប់ដោយសារអត់បាយឬយ៉ាងណា។ បន្ទាប់ពីរៀបចំផ្ទះសម្បែងបានរួចរាល់ ខ្ញុំ និងប្តីបានធ្វើដំណើរមកស្នាក់នៅក្នុងជំរំភៀសសឹកវិញ ព្រោះផ្ទះរបស់ខ្ញុំនៅកៀកទីតាំងទាហានថៃ។

បច្ចុប្បន្នខ្ញុំស្នាក់នៅជំរំភៀសសឹក ប៉ុន្តែចិត្តខ្ញុំនៅព្រួយបារម្ភពីផ្ទះ ព្រោះឥឡូវសម្បូរចោរចូលលួចរបស់របរថែមទាំងគាស់លួចយកទ្រព្យសម្បត្តិខាងក្នុងផ្ទះទៀតៗ។ រហូតសព្វថ្ងៃនេះ ខ្ញុំមិនអាចរស់នៅក្នុងជំរំភៀសសឹកតែមួយកន្លែងបាននោះទេ ព្រោះខ្ញុំត្រូវរកលុយចិញ្ចឹមជីវិត និងផ្គត់ផ្គង់ដល់ការសិក្សារៀនសូត្ររបស់កូនៗ។ ខ្ញុំតែងតែធ្វើដំណើរត្រឡប់ទៅផ្ទះនៅចម្ការចេកដើម្បីរកត្រីយកមកលក់។ រៀងរាល់ពេលខ្ញុំនិងប្តីត្រឡប់ទៅផ្ទះ ខ្ញុំមិនហ៊ានស្នាក់ក្នុងផ្ទះយូរថ្ងៃទេ ព្រោះខ្ញុំខ្លាចទាហានថៃផ្លោងគ្រាប់ចូលមកថ្មដាទៀតៗ។ ខ្ញុំគិតថា ប្រសិនបើទាហានថៃផ្លោងគ្រាប់ចូលថ្មដាមួងទៀត ខ្ញុំមិនអាចភៀសខ្លួនចេញមកខាងក្រៅទាន់ពេលវេលាឡើយ ដោយសារការសង្គ្រាមលើកទី២ ប្តីរបស់ខ្ញុំស្ទើរតែមិនអាចភៀសខ្លួនបានៗ។ រាល់ថ្ងៃនេះ ខ្ញុំសូមឱ្យតែប្រទេសជាតិរឆាប់ទទួលបានយុត្តិធម៌ និងមានសន្តិភាពឡើងវិញ។ ខ្ញុំចង់មានសុខភាពល្អចង់ឃើញកូនៗរបស់ខ្ញុំរៀនសូត្រមានចំណេះដឹង ហើយខ្ញុំចង់ឃើញការអភិវឌ្ឍន៍របស់ប្រទេសជាតិទៅថ្ងៃអនាគតៗ។



ប្រជាជននៅមណ្ឌលជនភៀសសឹក ក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ កំពុងចងអំបោសលក់ដើម្បីយកប្រាក់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សួន ចិន្តា៖ ផ្ទះខ្ញុំត្រូវបានដុតបំផ្លាញ

ចាន់ ណារិទ្ធ

ខ្ញុំឈ្មោះ សួន ចិន្តា អាយុ៨៦ឆ្នាំ កើតនៅភូមិខ្ពបតាងួន ឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកកាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ យិន ថា អាយុ៧៦ឆ្នាំ កំពុងរស់នៅស្រុកកំណើតភូមិខ្ពបតាងួន ឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ចំណែកម្តាយឈ្មោះ ដាន់ ចាន់ណា អាយុ៧២ឆ្នាំ។ ខ្ញុំមានបងប្អូនស្រីចំនួន៨នាក់។ ខ្ញុំគឺជាកូនទី១ នៅក្នុងគ្រួសារ ចំណែកប្អូនៗខ្ញុំមានឈ្មោះដូចជា ថា ស្រីនាង, ថា សុជា និង ថា ដល្លា។ ខ្ញុំមានប្តីឈ្មោះ សេង ហ៊ីន អាយុ៨៥ឆ្នាំ សព្វថ្ងៃធ្វើជាកងទ័ព។ ប្តីខ្ញុំមានស្រុកកំណើតនៅឃុំកាលវេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ក្រោយរៀបការរួច ប្តីប្រពន្ធខ្ញុំមានកូនចំនួន៣នាក់ គឺស្រី២នាក់ និងប្រុសម្នាក់ ចំណែកខ្ញុំសព្វថ្ងៃប្រកបមុខរបរលក់ដាយ។

កាលពីក្មេង ខ្ញុំរៀនបានត្រឹមថ្នាក់ទី៨។ ក្រោយមកខ្ញុំបានឈប់រៀនដោយសារតែឪពុកម្តាយរបស់ខ្ញុំបានលែងលះគ្នា ហើយខ្ញុំត្រូវជួយម្តាយរកស៊ីចិញ្ចឹមប្អូនៗ។ ខ្ញុំបានដើរស៊ីឈ្នួលបោកខោអាវ និង ដូតផ្ទះសម្បែងឱ្យអ្នកភូមិបានប្រហែលកន្លះឆ្នាំ ទើបម្តាយខ្ញុំហៅខ្ញុំ និងប្អូនស្រីទី២ឱ្យមករស់នៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកកាលវែង ខេត្តពោធិ៍សាត់។ ពេលខ្ញុំមករស់នៅក្នុងភូមិសង្គមថ្មីដំបូង ខ្ញុំបានឃើញម្តាយរបស់ខ្ញុំធ្វើការងារនៅក្នុងចម្ការកៅស៊ូ។

នៅឆ្នាំ២០០២ ម្តាយរបស់ខ្ញុំបានរៀបចំឱ្យខ្ញុំមានគ្រួសារ។ បន្ទាប់ពីខ្ញុំរៀបការរួច ខ្ញុំបានបែកចេញពីម្តាយមកប្រកបមុខរបរលក់បន្លែ និងលក់ចាប់ហួយបន្តិចបន្តួច។ ចំណែកប្តីរបស់ខ្ញុំគឺជាកងទ័ពនៅក្នុងកងពលតូចអន្តរាគមន៍លេខ១៤ ដែលមានទីតាំងនៅភូមិឈើទាល ឃុំគ្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់។ ប្រធានកងពលតូចរបស់ប្តីខ្ញុំឈ្មោះ គឹម សេងឆន។ នៅឆ្នាំ២០១៩ ខ្ញុំ និងប្តីបានសម្រេចចិត្តលែងលះគ្នាដោយសារតែការរស់នៅមិនចុះសម្រុងនឹងគ្នា។ បន្ទាប់ពីលែងលះជាមួយប្តី ខ្ញុំបានខិតខំប្រឹងរកស៊ីចិញ្ចឹមកូនទាំងលំបាកវេទនា។



សួន ចិន្តា អាយុ៨៦ឆ្នាំ រស់នៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកកាលវែង ខេត្តពោធិ៍សាត់។ បច្ចុប្បន្ន ចិន្តា មកស្នាក់នៅជំរំជនភៀសសឹក វិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ ស្ថិតនៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកកាលវែង ខេត្តពោធិ៍សាត់ បណ្តោះអាសន្ន ដោយសារការឈ្លានពានទីតដីពីកងទ័ពថៃ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥ ទាហានថៃបានដឹករថពាសដែក និងដឹកជញ្ជូនទាហានជាច្រើន

យកមកដាក់នៅតាមព្រំដែនក្បែរឃុំថ្មដា។ នៅវេលាម៉ោង៩:៣០នាទីទៀបភ្លឺ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំ និងម្តាយរបស់ខ្ញុំបានរៀបចំសម្លៀកបំពាក់និងរបស់របរប្រើប្រាស់មួយចំនួនដើម្បីភៀសខ្លួនទៅរកកន្លែងដែលមានសុវត្ថិភាព។ បន្ទាប់ពីរៀបចំអីវ៉ាន់រួចរាល់ ខ្ញុំ និងម្តាយបានឡើងជិះម៉ូតូឌុបកូនៗចាកចេញពីភូមិសង្គមថ្មី។ បន្ទាប់ពីជិះម៉ូតូអស់រយៈ២ម៉ោង ខ្ញុំ និងម្តាយបានទៅដល់វិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ ស្ថិតនៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកភ្នំលវែង ខេត្តពោធិ៍សាត់។ ខណៈពេលចូលមកស្នាក់នៅក្នុងជំរំភៀសសឹកលើកដំបូង ខ្ញុំបានឃើញប្រជាជនជាច្រើនបានចូលមកស្នាក់នៅជាបន្តបន្ទាប់។

អំឡុងពេលនោះ លោកគ្រូ អ្នកគ្រូ និងក្រុមការងារស្រុកភ្នំលវែង បានចុះមកជួយរៀបចំកន្លែងស្នាក់នៅ និងចែកអាហារហូបចុកដល់ខ្ញុំ និងប្រជាជនភៀសសឹកឯទៀត។ បន្ទាប់ពីខ្ញុំស្នាក់នៅក្នុងជំរំភៀសសឹកបានប្រហែលកន្លះខែ សភាពការណ៍នៅតាមព្រំដែនថ្មដាមានសភាពស្ងប់ស្ងាត់ឡើងវិញ។ ខណៈពេលនោះ ខ្ញុំ និងកូនបានជិះម៉ូតូចាកចេញពីជំរំភៀសសឹកវិលត្រឡប់ទៅរស់នៅផ្ទះ ដែលស្ថិតនៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកភ្នំលវែង ខេត្តពោធិ៍សាត់វិញ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃបានចាប់តស៊ូវុឌធុនធ្ងន់ និងបានដាក់ពង្រាយទាហានយ៉ាងច្រើនលើសលប់ចូលមកក្បែរព្រំដែនឃុំថ្មដាបន្តទៀត។ ខណៈពេលនោះនៅតាមព្រំដែនថ្មដា ចាប់ផ្តើមមានភាពតានតឹងសាឡើងវិញ។ បន្ទាប់ពីមានសភាពការណ៍មិនស្រួលមេភូមិសង្គមថ្មីឈ្មោះ រ៉ែត និងមេឃុំថ្មដាឈ្មោះ ព្រឹង្គុន បានប្រកាសជ្រាបប្រជាជនឱ្យភៀសខ្លួនចេញពីភូមិសង្គមថ្មីជាបន្ទាន់ ពីព្រោះទាហានថៃអាចនឹងបើកការវាយប្រហារចូលមកក្នុងឃុំថ្មដាម្តងទៀត។ នៅវេលាម៉ោង៨:០០នាទីទៀបភ្លឺ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានដាស់កូនឱ្យក្រោកពីដំណេក រួចបានដឹកកូនទាំងយប់ចាកចេញពីភូមិសង្គមថ្មី សំដៅទៅរកកន្លែងដែលមានសុវត្ថិភាព ដែលមានទីតាំងនៅក្នុងវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ ក្រោយពីមានបទឈប់បាញ់រវាងកងទ័ពកម្ពុជា និងទាហានថៃលើកទី២ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ប្រជាជនដែលរស់នៅឃុំថ្មដា បានចាកចេញពីជំរំភៀសសឹកវិលត្រឡប់ទៅកាន់លំនៅឋានរៀងៗខ្លួនវិញ។ ខ្ញុំនិងកូនបានជិះម៉ូតូចាកចេញពីជំរំភៀសសឹក ដើម្បីវិលត្រឡប់ទៅរស់នៅផ្ទះរបស់ខ្លួនវិញ។ ខណៈពេលជិះម៉ូតូចូលទៅដល់ភូមិសង្គមថ្មី ឃុំថ្មដា ស្រុកភ្នំលវែង ខេត្តពោធិ៍សាត់ ខ្ញុំបានឃើញទាហានថៃបានដាក់ទូរកុងតឺន័រ និងរាយបន្ទាលួសព័ទ្ធយកដី និងផ្ទះរបស់ប្រជាជនខ្មែរ។ ខ្ញុំបានជិះម៉ូតូសំដៅទៅផ្ទះរបស់ខ្ញុំ។ ពេលធ្វើដំណើរចូលទៅដល់មុខផ្ទះ ខ្ញុំមានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង ពីព្រោះផ្ទះរបស់ខ្ញុំត្រូវបានដុតបំផ្លាញឆេះគ្មានសល់។ ពេលនោះខ្ញុំគិតអ្វីមិនចេញ ខ្ញុំគិតតែអង្គុយយំព្រោះស្តាយផ្ទះសម្បែងដែលខំរកមកយ៉ាងលំបាក។ បន្ទាប់មកខ្ញុំ និងកូនបានជិះម៉ូតូវិលត្រឡប់មករស់នៅជំរំភៀសសឹកដែលមានទីតាំងនៅក្នុងវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយវិញ។ បច្ចុប្បន្នខ្ញុំបន្តស្នាក់នៅជំរំភៀសសឹកព្រោះតែសភាពការណ៍នៅតាមព្រំដែនមិនទាន់ស្ងប់ស្ងាត់ ហើយខ្ញុំមិនទាន់មានលទ្ធភាពសាងសង់ផ្ទះសម្បែងរស់នៅ។



កុមារនៅមណ្ឌលជនភៀសសឹកក្នុងឃុំប្រម៉ោយ ស្រុកភ្នំលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម កាន់តែថយ ការចងចាំចាប់ផ្តើមរសាត់បាត់ទៅ

សាន ចិន្តា



ក្រុមការងារព្រះរាជបណ្ណាល័យហ្គេតម៉ែយករទេះរុញជូនយាយ ប៉ក់ ភួង នៅផ្ទះរបស់គាត់ ស្ថិតនៅភូមិវើនសៀន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការចងចាំកំពុងតែរសាត់បាត់ទៅបន្តិចម្តងៗ ទៅតាមវ័យកាន់តែជររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដូច្នេះ ការចងក្រង ការកត់ត្រា និងការផ្សព្វផ្សាយរឿងរ៉ាវរបស់អ្នកទាំងនេះទៅដល់ក្មេងជំនាន់ក្រោយ គឺពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងការថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហម។

យាយ ប៉ក់ ភួង អាយុ១០៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិវើនសៀន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្វាយរៀង។ យាយ ភួង កើតនៅភូមិអូរតាឡាស់ ឃុំព្រះរំកិល ស្រុកថា ឡាបរ៉ាំត់ (បច្ចុប្បន្នស្ថិតក្នុងស្រុកបុរីអូរស្វាយសែនជ័យ) ខេត្តស្វាយរៀង។ យាយ ភួង មានឪពុកឈ្មោះ ប៉ក់ និងម្តាយឈ្មោះ ខៀវ ហើយគាត់គឺជាកូនពៅក្នុងចំណោមបងប្អូនស្រីចំនួន២នាក់។ យាយ ភួង មានកូនប្រុសស្រីចំនួន៨នាក់ និងមានកូន ចៅរហូតដល់៥ជំនាន់គឺកូន, ចៅ, ចៅទួត, ចៅលួត និងចៅលោ។ ជីវិតរបស់យាយ ភួង បានឆ្លងកាត់ការផ្លាស់ប្តូរតាមសម័យកាលសំខាន់ៗជាច្រើនក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសម័យអាណានិគមនិយមបារាំង សម័យសង្គមរាស្ត្រនិយម សម័យ លន់ នល់ របបខ្មែរក្រហម សម័យរដ្ឋកម្ពុជា រហូតដល់សម័យបច្ចុប្បន្ន។

បើទោះការចងចាំរបស់យាយ ភួង ចាប់ផ្តើមស្រពេចស្រពិលទៅតាមវ័យចាស់ជរា ប៉ុន្តែនៅមានជំនួយពីកូនស្រីច្បងដែលរស់ជិតគ្នា នៅតែអាចរៀប

រាប់អំពីព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដែលមិនអាចបំភ្លេចបានគឺនៅពេលដែលទៅទទួលព្រះរាជដំណើរបស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋយាងមកសម្ពោធព្រះសមិទ្ធដ្ឋលនានានៅបុរីអូរស្វាយក្នុងឆ្នាំ១៩៦៨, ការរស់នៅអំឡុងពេលប្រទេសមានសង្គ្រាម, បទពិសោធន៍និងការហូបចុកមិនគ្រប់គ្រាន់នៅក្នុងរបបខ្មែរក្រហម, ការចាប់ផ្តើមជីវិតឡើងវិញក្រោយរបបខ្មែរក្រហមដួលរលំ និងការធ្វើដំណើរទៅកាន់ព្រះបរមរាជវាំង ក្នុងរាជធានីភ្នំពេញ ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដើម្បីទទួលព្រះរាជអំណោយដែលជ្រោសព្រះរាជទានដោយផ្ទាល់ពីសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ។

ការស្តាប់ និងកត់ត្រាការចងចាំដែលនៅសេសសល់របស់យាយ ភួង មានតម្លៃយ៉ាងខ្លាំងសម្រាប់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងជីវិតរស់នៅរបស់ប្រជាជនកម្ពុជាក្នុងដំណាក់កាលនីមួយៗ។ ការចងចាំរបស់គាត់មិនមែនគ្រាន់តែជារឿងរ៉ាវផ្ទាល់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែជាផ្នែកមួយនៃប្រវត្តិសាស្ត្រដែលត្រូវបានរក្សាទុកពីអ្នករស់រានមានជីវិត និងឆ្លងកាត់មនុស្សជាច្រើនជំនាន់។ ពេលវេលាកំពុងតែដើរទៅមុខហើយ ការបាត់បង់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺអាចឱ្យយើងបាត់បង់សាច់រឿង និងបទពិសោធន៍ដែលមិនទាន់ត្រូវបានចងក្រង។ ដូច្នេះ ភាតព្វកិច្ចរបស់យើងគឺស្តាប់ កត់ត្រា រក្សាទុក និងបន្តនិយាយប្រាប់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីធានាថាសាច់រឿង និងការចងចាំដ៏មានតម្លៃរបស់គាត់នឹងមិនត្រូវបាត់បង់ទៅតាមពេលវេលា ហើយអាចបន្តទៅដល់មនុស្សជំនាន់ក្រោយ។

ភូមិវើនសៀន៖ សហគមន៍ជាប់ស្រយាលតាមដងទន្លេមេគង្គនៃស្រុកបុរីអូរស្វាយសែនជ័យ

ភូមិវើនសៀនគឺជាភូមិមួយស្ថិតក្នុងឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលមានទីតាំងស្ថិតនៅលើកោះដាច់ស្រយាល និងមានចម្ងាយប្រមាណ១៨គី ឡូម៉ែត្រពីដីគោក។ ភូមិនេះមានប្រជាពលរដ្ឋរស់នៅសរុបចំនួន៨៨គ្រួសារ ស្មើនឹង៨០៤នាក់ ក្នុងនោះមានស្ត្រីចំនួន២០៨នាក់។ ដោយស្ថិតនៅក្នុងតំបន់ដែលព័ទ្ធជុំវិញដោយទន្លេមេគង្គ ការធ្វើដំណើររបស់ប្រជាពលរដ្ឋភាគច្រើនត្រូវពឹងផ្អែកលើទូក។ ប្រជាពលរដ្ឋក្នុងភូមិភាគច្រើនប្រកបរបរកសិកម្ម និងនេសាទ ដោយពឹងផ្អែកជាចម្បងលើធនធានធម្មជាតិនៅតាមដងទន្លេមេគង្គ ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។

បើទោះបីទន្លេមេគង្គ និងដួងទឹកជាប្រភពធនធានដ៏សំខាន់សម្រាប់ជីវភាពរស់នៅប៉ុន្តែទីតាំងភូមិសាស្ត្រដាច់ស្រយាលបង្កការលំបាកក្នុងការទទួលបានសេវាសាធារណៈជាពិសេសសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានវ័យចាស់ជរា និងមានពិការភាព។ ការធ្វើដំណើរពីកោះទៅដីគោកបានចំណាយពេលវេលា និងថវិកា ហើយកាន់តែលំបាកនៅពេលអាកាសធាតុមិនអំណោយផល។ សម្រាប់អ្នករស់រានមានជីវិតដែលមានវ័យចាស់ជរា និងមិនអាចដើរបានការធ្វើដំណើរទៅទទួលសេវាពិនិត្យ និងថែទាំសុខភាពនៅមណ្ឌលសុខភាពអាចក្លាយជាបញ្ហាប្រឈមធ្ងន់ធ្ងរ។

ពីការលំបាកក្នុងការធ្វើដំណើរ ទៅកាន់ស្នាមញញឹម

ដោយមើលឃើញពីការលំបាកក្នុងការធ្វើដំណើររបស់យាយ ភួង ទៅកាន់មណ្ឌលសុខភាពព្រះនរោត្តម សីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនីនាថ សីហនុអូរស្វាយ ក្រុមការងាររបស់ព្រះរាជបណ្ណាល័យហ្វូម៉ែបានផ្តល់រទេះរុញជូនគាត់ដើម្បីសម្រួលដល់ការធ្វើដំណើរ និងការចល័តប្រចាំថ្ងៃ ជាពិសេសការធ្វើដំណើរទៅពិនិត្យសុខភាព និងទទួលសេវាថែទាំសុខភាពនៅមណ្ឌលសុខភាពក្បែរផ្ទះ។ ការលំបាកក្នុងការធ្វើដំណើររបស់យាយ ភួង កន្លងមក ត្រូវបានជំនួសដោយស្នាមញញឹម និងក្តីរំភើប នៅពេលគាត់បានអង្គុយលើរទេះរុញថ្មីនេះ។

ការថែទាំសុខភាព និងការផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានវ័យជរា ការបន្តយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាកិច្ចការដែលកំពុងតែប្រណាំងជាមួយពេលវេលាដែលមិនអាចបញ្ឈប់បាន។ ជរាភាព និងការថយចុះនៃសុខភាពអាចធ្វើឱ្យការចងចាំរបស់អ្នករស់រានមានជីវិតកាន់តែស្រពេចស្រពិល ឬបាត់បង់ទៅតាមពេលវេលា។ សាច់រឿងរបស់យាយ ប៉ក់ ភួង គឺជាការរំឭកថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមិនត្រឹមតែត្រូវការយកចិត្តទុកដាក់ចំពោះសុខុមាលភាព និងជីវភាពរស់នៅតែប៉ុណ្ណោះទេ ប៉ុន្តែការចងចាំ និងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមត្រូវការការចងក្រង និងថែរក្សា។ នៅពេលដែលការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងតែ



យាយ ប៉ក់ ភួង អាយុ១០៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិវើនសៀន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាត់បង់ទៅតាមវ័យ, ការស្តាប់ ការចងក្រង និងការថែរក្សាទុកសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាការងារដែលមិនគួររង់ចាំ។



ក្រុមការងារព្រះរាជបណ្ណាល័យហ្គូធម៌យករទេះរុញជូនយាយ ប៉ក់ ភួង នៅផ្ទះរបស់គាត់ ស្ថិតនៅក្នុងភូមិវើនសៀន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គការចាត់តាំងឱ្យក្បាញ្ជ្រូកមានៅភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ

ឌី ស៊ីថា



យួន សុត មានអាយុ៧៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិដំនុំពល ឃុំជាំគាម៉ោ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាងខ្ញុំឈ្មោះ យួន សុត មានអាយុ៧៣ឆ្នាំ កើតនៅភូមិដំនុំពល ឃុំជាំគាម៉ោ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិដំនុំពល ឃុំជាំគាម៉ោ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ យួន និងម្តាយឈ្មោះ ដួង សុំអ្នកទាំងពីរស្លាប់ដោយសារជរាពាធ។ ខ្ញុំជាកូនច្បងនៅក្នុងគ្រួសារដែលមានបងប្អូនសរុបចំនួន៥នាក់ ក្នុងនោះមានប្រុស៣នាក់ និងស្រី២នាក់។ ខ្ញុំមានប្តីឈ្មោះ ធឹម ថន ស្លាប់ដោយសារជំងឺរបេងកាលពី៧ឆ្នាំមុន។ ខ្ញុំមានកូនចំនួន៥នាក់ ក្នុងនោះមានកូនប្រុស៣នាក់ និងស្រី២នាក់។

កាលពីកុមារភាព ខ្ញុំមិនបានចូលរៀនសូត្រអ៊ីទេ ព្រោះភូមិដំនុំពល ពុំទាន់មានសាលាសម្រាប់ក្មេងរៀនសូត្រនៅឡើយ។ នៅជុំវិញភូមិសម្បូរទៅដោយព្រៃឈើធំៗ។ ប្រជាជននៅក្នុងភូមិដំនុំពលរស់នៅពឹងផ្អែកលើការធ្វើស្រែ និងនេសាទត្រីពីព្រែកឆ្លូង ខេត្តក្រចេះ។ ភូមិដំនុំពល ពុំសូវមានប្រជាជនរស់នៅច្រើនទេប៉ុន្តែប្រជាជនរស់នៅអាស្រ័យគ្នាយោគយល់គ្នា មានទំនាក់ទំនងល្អនឹងគ្នា និងចេះចែករំលែកឱ្យគ្នាទៅវិញទៅមក។

ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារក្នុងឆ្នាំ១៩៧០ ក្នុងភូមិដំនុំពល ស្រាប់តែមានយន្តហោះអាមេរិកហោះមកទម្លាក់គ្រាប់បែក ប៉ុន្តែមិនបានបណ្តាលឱ្យមានការខូចខាតផ្ទះសម្បែង និងទ្រព្យសម្បត្តិឡើយ។ នៅឆ្នាំ១៩៧៤ ប្រជាជននៅក្នុងភូមិដំនុំពលចាប់ផ្តើមធ្វើស្រែចម្ការរវេរប្រាស់គ្នាទៅវិញទៅមក ប៉ុន្តែប្រជាជននៅហូបចុកយ៉ាងតាមផ្ទះរៀងៗខ្លួន។

នៅឆ្នាំ១៩៧៥ អង្គការបានបង្កើតសហករណ៍រួមនិងចាត់តាំងកម្មាភិបាលមួយក្រុមឱ្យដើរប្រមូលទ្រព្យសម្បត្តិនៅតាមផ្ទះប្រជាជនមានដូចជា មាស ប្រាក់ និងសម្ភារប្រើប្រាស់ផ្សេងៗយកទៅទុកនៅឃ្លាំងសហករណ៍។ អង្គការបានសាងសង់រោងបាយរួម ទុកឱ្យប្រជាជនហូបអាហាររួមគ្នា។ អង្គការបានកំណត់ឱ្យប្រជាជនហូបអាហារក្នុងមួយថ្ងៃចំនួនពីរពេល។ អង្គការកំណត់ឱ្យប្រជាជនគ្រប់រូបមានការងារធ្វើទាំងអស់មិនថា កុមារ យុវជន-យុវនារី និងក្រមចាស់ជរា។ ពេលនោះ ខ្ញុំត្រូវអង្គការចាត់តាំងឱ្យធ្វើការនៅ

កងចល័តឃុំជាំតាម៉ៅ។ ក្រុមចល័តខ្ញុំមានសមាជិកចំនួន១២នាក់។ ខ្ញុំត្រូវទៅធ្វើស្រែនៅភូមិ បុស្សតាអឹម។ ទិន្នផលស្រូវ កាលនោះធ្វើបានផលច្រើនប៉ុន្តែខ្ញុំមិនដឹងថា អង្គការដឹកយកទៅណានោះទេ។

បន្ទាប់មកខ្ញុំត្រូវអង្គការជម្លៀសឱ្យទៅរស់នៅក្នុងភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ។ អង្គការបានចាត់តាំងខ្ញុំឱ្យត្បាញក្រមា។ ក្រុមតម្បាញខ្ញុំមានសមាជិកនារីចំនួន១៨នាក់។ ក្រុមត្បាញក្រមាទទួលបានអាហារហូបចុកគ្រប់គ្រាន់ដោយក្នុងមួយថ្ងៃទទួលបានអាហារបីពេល។ ខ្ញុំធ្វើការក្នុងក្រុមតម្បាញរយៈពេលមួយឆ្នាំ។ នៅពេលបិទវគ្គតម្បាញ អង្គការបានចែកសំពត់ពណ៌សឱ្យនារីតម្បាញម្នាក់មួយ។ ក្រោយមក ខ្ញុំបានយកសំពត់ពណ៌សទៅជ្រលក់ពណ៌ខ្មៅដើម្បីទុកប្រើប្រាស់ជាប្រចាំថ្ងៃ។ ក្រោយមកទៀត អង្គការបានជម្លៀសខ្ញុំទៅស្រុកស្ទឹងត្រង់ ខេត្តកំពង់-ចាម។ អង្គការប្រើខ្ញុំឱ្យច្រូតស្រូវរហូតប្រទេសជាតិត្រូវបានរំដោះ។ ខ្ញុំសម្រេចចិត្តធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ សព្វថ្ងៃនេះខ្ញុំមានជំងឺក្រពះពោះវៀន។



ក្រៅពីធ្វើស្រែ និងចម្ការ ប្រជាជននៅភូមិឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចង់អំពោសលក់ដើម្បីយកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជីវិតជានិគមជន និងបទពិសោធន៍ជាប្រធានសហជីព ក្នុងរបបខ្មែរក្រហម

ហូ លីនីត

ខ្ញុំឈ្មោះ ជា ចាន់ធឿន អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិតាម៉ៅ ស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិអូរសុាយ ឃុំអូរសុាយ ស្រុកបុរីអូរសុាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមានឪពុកឈ្មោះ ជា ពេញ (ស្លាប់) និងម្តាយឈ្មោះ អុង កាយ (ស្លាប់)។ ខ្ញុំមានបងប្អូនប្រុសស្រីចំនួន៨នាក់។

កាលពីវ័យកុមារ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ ក្នុងសង្គមចាស់។ នៅឆ្នាំ១៩៦៥ ក្រុសាររបស់ខ្ញុំបានផ្លាស់មករស់នៅបុរីអូរសុាយ។ ពេលមកដល់បុរីអូរសុាយដំបូង ខ្ញុំឃើញមានប្រជាជនរស់នៅប្រមាណជា៧០ទៅ ៨០ ក្រុសារតែប៉ុណ្ណោះ។ ទេសភាពនៅជុំវិញបុរីអូរសុាយ គឺហ៊ុមព័ទ្ធទៅដោយព្រៃក្រាស់ៗ និងទន្លេមេគង្គ។ ទោះបីជាយ៉ាងណា ហេដ្ឋារចនាសម្ព័ន្ធ និងសមិទ្ធដលសំខាន់ៗមួយចំនួនត្រូវបានកសាងរួចជាស្រេច ដើម្បីបម្រើដល់ការរស់នៅរបស់ប្រជាជនក្នុងនោះមានដូចជា៖ ដ្ឋារសហគមន៍ សាលាឆានវត្ត បន្ទាយទាហានមន្ទីរពេទ្យ រោងតម្បាញ និងរោងចក្រដលិតស្ករ។ ប៉ុន្តែសម្រាប់អ្នកដែលទើបមករស់នៅថ្មីៗ មើលឃើញនៅបុរីអូរសុាយ គឺពោរពេញដោយព្រៃស្ងាត់ និងធម្មជាតិ។



ជា ចាន់ធឿន អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរសុាយ ឃុំអូរសុាយ ស្រុកបុរីអូរសុាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលល្ងាច ខ្ញុំតែងតែឮសំឡេងសត្វសុាង និងសត្វខ្លាត្រហឹមពេញព្រៃជាពិសេសគឺនៅពេលយប់។ ពេលខ្ញុំមកដល់បុរីអូរសុាយដំបូង ក្រុសាររបស់ខ្ញុំទទួលបានដុះកាឡឹងមួយខ្នង និងដីមួយកន្លែងដែលមានទទឹង៤០ម៉ែត្រ និងបណ្តោយ៥០ម៉ែត្រ សម្រាប់រស់នៅ និងប្រកបរបរចិញ្ចឹមជីវិត។ បើទោះបីជាមានសមិទ្ធដលមួយចំនួនត្រូវបានកសាងរួចហើយក៏ដោយ ប៉ុន្តែប្រជាជននៅបុរីអូរសុាយមួយចំនួននៅតែប្រឈមនឹងជំងឺ។ បញ្ហាដ៏ធំបំផុតរបស់និគមជនគឺជំងឺគ្រុនចាញ់ ដោយសារតែបុរីអូរសុាយសម្បូរទៅដោយព្រៃក្រាស់និងមូស។ ជំងឺគ្រុនចាញ់នេះបានបណ្តាលឱ្យប្រជាជនមួយចំនួនស្លាប់ដែរ។ បើទោះបីជាការរស់នៅមានការលំបាក និងប្រឈមនឹងជំងឺ ក៏ប្រជាជននៅតែតស៊ូ និងកសាងជីវិតនៅលើទឹកដីបុរីអូរសុាយ។ ឪពុកម្តាយខ្ញុំ គឺជាផ្នែកមួយនៃនិគមជន

ដែលបានតស៊ូរស់នៅបុរីអូរស្វាយរហូតមកដល់សព្វថ្ងៃនេះ។ ដូច្នេះ បទពិសោធន៍និងការចងចាំអំពីការមកតាំងទីលំនៅ នៅឆ្នាំ១៩៦៥ មិនត្រឹមតែជាការចងចាំអំពីការចាប់ផ្តើមជីវិតនៅក្នុងតំបន់ថ្មីតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការចងចាំអំពីការតស៊ូ និងការអត់ធ្មត់របស់និគមជនដែលបានចូលរួមបង្កើតសហគមន៍បុរីអូរស្វាយ។

នៅឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ដែលពេលនេះខ្ញុំកំពុងរៀនថ្នាក់ទី១០ បានឈប់រៀនដោយសារតែប្រទេសជាតិធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល។ នៅបុរីអូរស្វាយទាំងមូលត្រូវរងការទម្លាក់គ្រាប់បែកដោយយន្តហោះរបស់កងទ័ពអាមេរិក។ គ្រួសារខ្ញុំបានទៅលាក់ខ្លួននៅក្នុងព្រៃរួចហើយភៀសខ្លួនទៅរស់នៅក្នុងភូមិអូរឫនិងអូរកុំ។ កាលនោះ គ្រួសារខ្ញុំចូលទៅលាក់ខ្លួនក្នុងលេណដ្ឋានតាហុក។ នៅពេលខ្ញុំចេញពីលេណដ្ឋាន តាហុក ខ្ញុំឃើញយន្តហោះមកទម្លាក់គ្រាប់បែកចំស្ពានអូរស្វាយរួចបន្តទម្លាក់នៅផ្សារ ធ្វើឱ្យគ្រួសារខ្ញុំប្រញាប់ភៀសខ្លួនទៅភូមិអូរឫនវិញ។ គ្រួសារខ្ញុំមានការលំបាកខ្លាំងណាស់ ហើយហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងអស់ ដូចជា ស្ពាន ពេទ្យ តម្បាញ សាលារៀន មន្ទីរពេទ្យ និងមន្ទីរកសិកម្ម ត្រូវបានបំផ្លិចបំផ្លាញស្ទើរទាំងស្រុង។

ក្រោយពីមានរដ្ឋប្រហារ លន់ នល់ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បុរីអូរស្វាយប្រែក្លាយទៅជាទីតាំងសមរភូមិរវាងកងទ័ពខ្មែរក្រហម និងទាហាន លន់ នល់។ សមិទ្ធផលកសាងនៅសម័យសង្គមរាស្ត្រ និយមត្រូវរងការបំផ្លិចបំផ្លាញ ហើយប្រជាជនត្រូវរស់នៅក្នុងសង្គ្រាម ដោយមិនអាចចាកចេញទៅកាន់ទីកន្លែងផ្សេងដោយងាយស្រួលបានឡើយ ពីព្រោះភូមិសាស្ត្របុរីអូរស្វាយគឺជាតំបន់ព្រៃក្រាស់ និងហ៊ុមព័ទ្ធដោយទឹកទន្លេមេគង្គ។

នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចូលមកគ្រប់គ្រងប្រទេសទាំងស្រុង នៅពេលនោះ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យទៅរស់នៅ និងធ្វើការក្នុងចម្ការកៅស៊ូខេត្តរតនគិរី។ ខ្ញុំត្រូវរស់នៅបែកចេញពីឪពុកម្តាយ។ ដោយសារតែការខិតខំប្រឹងប្រែងធ្វើការងាររបស់ខ្ញុំទើបខ្មែរក្រហមចាត់តាំងខ្ញុំឱ្យធ្វើជាប្រធានសហជីពនៅចម្ការកៅស៊ូ ខេត្តរតនគិរី។ ក្នុងតួនាទីប្រធានសហជីព ខ្ញុំមានភារកិច្ចគ្រប់គ្រងនារីចំនួន១០នាក់ និងប្រជាជនដែលជាជនជាតិដើមភាគតិចមួយចំនួនទៀត។ ក្នុងអំឡុងពេលដឹកនាំ ខ្ញុំបានព្យាយាមសម្របសម្រួល និងយកចិត្តទុកដាក់មើលថែប្រជាជននៅក្នុងអង្គភាពរបស់ខ្ញុំ ដោយខិតខំធ្វើយ៉ាងណាកុំឱ្យមានស្លាប់ជាតិបង់ជីវិត។ បើទោះបីជាស្ថានភាពនៅពេលនោះមានការលំបាកយ៉ាងណា ខ្ញុំនៅតែព្យាយាមអប់រំ និងណែនាំប្រជាជនកុំឱ្យប្រព្រឹត្តខុស និងកុំឱ្យអង្គការចាប់ខ្លួនយកទៅសម្លាប់។ ប្រសិនបើ នរណាម្នាក់មានកំហុសដោយសារលួចរបស់របរផ្សេងៗ ខ្ញុំតែងតែហៅអ្នកនោះមកអប់រំ និងណែនាំដោយស្ងាត់ៗនៅពេលយប់។ ចំពោះការងារប្រចាំថ្ងៃ កម្មករទាំងអស់ក្នុងសហជីពត្រូវបានចាត់តាំងឱ្យចៀរជីរកៅស៊ូឱ្យបាន៧០០ដើមក្នុងមួយថ្ងៃ។ កម្មករនៅក្នុងសហជីពត្រូវបែងចែកជាក្រុម ដោយក្នុងមួយក្រុមមានសមាជិក ២០នាក់។ ប្រសិនបើមានកម្មករណាម្នាក់នៅក្នុងក្រុមធ្វើការងារមិនទាន់ដែនការ ខ្ញុំតែងតែប្រាប់កម្មកររផ្សេងឱ្យជួយ ពីព្រោះប្រសិនបើធ្វើមិនហើយតាមដែនការកំណត់អ្នកនោះអាចត្រូវអង្គការយកទៅសម្លាប់ចោល។ ការងារនៅចម្ការកៅស៊ូ មិនមានការបែងចែករវាងបុរសនិងស្ត្រីទេ។ បុរសនិងស្ត្រីត្រូវធ្វើការដូចគ្នាដូចជាចៀរជីរកៅស៊ូ និងដាំបន្លែ។ នៅក្នុងអង្គភាពរបស់ខ្ញុំមានមន្ទីរពេទ្យមួយឈ្មោះ«មន្ទីរពេទ្យ-២» សម្រាប់ឱ្យស្ត្រីមានផ្ទៃពោះទៅសម្រាលកូន។ ស្ត្រីដែលមានបញ្ហាសុខភាពឬមានរដូវ ក្នុងនាមខ្ញុំជាអ្នកដឹកនាំស្ត្រីបានព្យាយាមយល់ពីតម្រូវការរបស់គាត់ និងជួយតាមលទ្ធភាពដែលមាន។ ខ្ញុំតែងតែសូងរកសម្ភារ និងថ្នាំសង្កូវមួយចំនួនឱ្យស្ត្រីក្នុងសហជីពដើម្បីព្យាបាលជំងឺ បើទោះបីជារបស់ទាំងនោះមានចំនួនតិច និងមិនសម្បូរក៏ដោយ។ ចំពោះស្ត្រីដែលទើបសម្រាលកូនរួច គឺខ្ញុំឱ្យម្តាយសម្រាករហូតដល់កូនរឹងដៃរឹងជើង ទើប

ឱ្យមកធ្វើការវិញ។ របបអាហារសម្រាប់សហជីពខ្ញុំគ្រប់គ្រងមានការខ្វះខាត និងមិនសូវបានគ្រប់គ្រាន់ឡើយ។ នៅភូងតំបន់របស់ខ្ញុំមិនថាអ្នកចេះដឹងឬអ្នកមិនចេះទេ គឺត្រូវចូលរួមធ្វើការងារដូចគ្នា គឺធ្វើស្រែចម្ការ, លើកទំនប់ ប្រឡាយ និងចៀរជីរកៅស៊ូ។ ជីវិតប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម គឺត្រូវជួបប្រទះការងារធ្ងន់ធ្ងរ, ការបង្គត់អាហារ និងការភ័យខ្លាចអង្គការចាប់យកទៅកសាងឬសម្លាប់ចោល។

នៅចុងឆ្នាំ១៩៧៨ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយចូលមក ពេលនោះខ្ញុំនិងប្រជាជនផ្សេងទៀតត្រូវអង្គការជម្លៀសទៅកាន់ខេត្តព្រះវិហារជាប់ព្រំដែនថៃ។ ខ្ញុំ និងខ្មែរក្រហមផ្សេងទៀត ត្រូវគោងវល្ល៍ឡើងទៅលើកំពូលភ្នំដងរែក។ ដោយសារខ្ញុំឡើងភ្នំមិនរួច ទើបខ្ញុំសម្រេចចិត្តវិលត្រឡប់មកភូមិកំណើតវិញ។ ពេលនោះ ខ្ញុំបានសុំរថយន្តអ្នកធ្វើដំណើរស្របផ្លូវគ្នាដើរមកកាន់ខេត្តស្ទឹងត្រែង និងស្នាក់នៅទីរួមខេត្តស្ទឹងត្រែងអស់រយៈពេលមួយឆ្នាំ។ ក្រោយមក ខ្ញុំបានផ្លាស់មករស់នៅបុរីអូរសាយ ហើយបន្តរស់នៅទីនេះរហូតមកដល់សព្វថ្ងៃ។

បច្ចុប្បន្ន ខ្ញុំមានជំងឺប្រចាំកាយ ដូចជា ជំងឺលើសឈាម និងជំងឺបេះដូង។ កាលពីប៉ុន្មានថ្ងៃមុនចង្វាក់បេះដូងរបស់ខ្ញុំបានកើនឡើងដល់១៧០ដងក្នុងមួយនាទី ហើយខ្ញុំត្រូវបានបញ្ជូនទៅសង្គ្រោះនិងព្យាបាលនៅមណ្ឌលសុខភាព «សម្តេចព្រះនរោត្តម សីហនុរាជ និងសម្តេចព្រះវររាជមាតានរោត្តម មុនិនាថ សីហនុ» នៅបុរីអូរសាយ អស់មួយរយៈពេល ទើបអាការជំងឺរបស់ខ្ញុំបានធូរស្រាលនិងអាចវិលត្រឡប់មកផ្ទះវិញ។



ដំណាំនៅតាមផ្ទះប្រជាជនក្នុងភូមិអូរសាយ ឃុំអូរសាយ ស្រុកបុរីអូរសាយសែនជ័យ ខេត្តស្ទឹងត្រែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្មែរក្រហមបង្ខំឱ្យខ្ញុំធ្វើការងារហួតរលួតកូន

គី ចាន់ចូ

ខ្ញុំឈ្មោះ មាស ឆន អាយុ៨០ឆ្នាំ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិសែនបន ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ប្តីរបស់ខ្ញុំឈ្មោះ ចាន់តន ស្លាប់ដោយសារជំងឺក្នុងវ័យ៧៨ឆ្នាំ។ ខ្ញុំមានកូនចំនួន៧នាក់ គឺស្រី៤នាក់និងប្រុស៣នាក់។ កូនខ្ញុំម្នាក់ៗបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃ កូនៗទាំង៦នាក់របស់ខ្ញុំដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម សុទ្ធតែប្រកបរបរធ្វើស្រែចម្ការ។ ចំណែកខ្ញុំវិញមានជំងឺលើសឈាមប្រចាំកាយ និងកំពុងព្យាបាលដោយប្រើប្រាស់ថ្នាំពេទ្យជាប្រចាំថ្ងៃ។



មាស ឆន អាយុ៨០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសែនបន ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវអង្គការចាត់តាំងឱ្យធ្វើការក្នុងកងសេដ្ឋកិច្ច។ ដំបូងអង្គការបានបង្ខំខ្ញុំទៅសូងស្រូវនៅខាងជើងវត្តលាយបូរ ខណៈពេលដែលខ្ញុំកំពុងមានផ្ទៃពោះប្រហែលពាក់ទៅ៨ខែ។ នៅពេលនោះ អង្គការបានកំណត់ដែនការឱ្យមនុស្ស៨នាក់សូងស្រែប្រណាំងគ្នាឱ្យរួចរាល់លើផ្ទៃដី១ហិកតាក្នុងរយៈពេលតែមួយថ្ងៃ។ ដោយសារកំពុងចាញ់កូន និងអាការលើយក្នុងខ្លួនខ្លាំង ខ្ញុំបានប្រកែកគង្វាជាមួយប្រធានកងថា ខ្ញុំកំពុងមានផ្ទៃពោះ និងចាញ់កូនមិនអាចធ្វើការលឿនបានដូចនោះទេ។ ប៉ុន្តែប្រធានកងបានបដិសេធ និងចោទប្រកាន់ខ្ញុំវិញថា «អត់ទេ! យាយឯងកុហកខ្ញុំ ដើងដៃវែងៗបែបនេះធ្វើការងារបានលឿនណាស់»។

រយៈពេលប្រហែល២ទៅ៣ថ្ងៃក្រោយមក ដោយសារតែការបង្ខំឱ្យប្រឹងប្រែងធ្វើការហួសកម្លាំង ខ្ញុំមានអាការចុកពោះយ៉ាងខ្លាំងរហូតសង្ស័យថារលូតកូន។ ខ្ញុំបានសុំប្រធានកងត្រឡប់ទៅផ្ទះ ប៉ុន្តែប្រធានកងមិនព្រមឱ្យខ្ញុំទៅសម្រាកឡើយ ដោយចោទថាខ្ញុំមានជំងឺសតិអារម្មណ៍។ រំលងបានមួយថ្ងៃមួយយប់ អាការចុកពោះខ្ញុំកាន់តែធ្ងន់ធ្ងរឡើងៗ រហូតខ្ញុំទ្រាំមិនបានក៏ស្រែកយំដោយភាពឈឺចាប់ ទើបអង្គការព្រមបញ្ជូនខ្ញុំទៅកាន់មន្ទីរពេទ្យ។ បន្ទាប់ពីទៅដល់មន្ទីរពេទ្យបានមួយយប់ ខ្ញុំរលូតកូននៅវេលាថ្ងៃត្រង់។ ខ្ញុំបានស្រែកហៅគ្រូពេទ្យឱ្យជួយ ព្រោះខ្លួនខ្ញុំស្ពឹកស្រយង់មួយរំពេច និងមិនស្រួលក្នុងខ្លួន។ ពេលនោះគ្រូពេទ្យបានចាក់ថ្នាំឱ្យខ្ញុំមួយម្ជុល និងអនុញ្ញាតឱ្យខ្ញុំសុំត្រឡប់ទៅសហករណ៍វិញ។ ខ្ញុំចាំបានថា ខ្ញុំធ្លាប់រលូតកូនប៉ុន្តែគ្រូពេទ្យប្រាប់ខ្ញុំឱ្យត្រឡប់

ទៅកន្លែងធ្វើការវិញ។ ពេលត្រឡប់ទៅដល់កន្លែងធ្វើការ អង្គការបានប្តូរខ្ញុំឱ្យទៅធ្វើការស្រាលៗ និងមិនសូវលំបាកប៉ុន្មានឡើយ។ លុះជិតមួយខែក្រោយមក អង្គការចាត់តាំងខ្ញុំឱ្យទៅធ្វើការខាងក្រុមសែងដីជាមួយយាយៗ និងស្ត្រីឯទៀតៗ បន្ទាប់មកទៀត អង្គការផ្លាស់ប្តូរខ្ញុំឱ្យទៅរកបន្លែសម្រាប់ផ្គត់ផ្គង់រោងសហករណ៍វិញ។ ចំណែកឯប្តីរបស់ខ្ញុំវិញ អង្គការបានចាត់តាំងឱ្យទៅធ្វើការក្នុងកងសេដ្ឋកិច្ចដូចគ្នា ដោយត្រូវទទួលខុសត្រូវលើការនេសាទត្រី និងឡើងត្នោត។ មួយរយៈក្រោយមក ខ្ញុំចាប់ផ្តើមមានផ្ទៃពោះកូនមួយទៀត និងបានសម្រាលកូនដោយគ្មានឆ្មបជំនាញជួយឡើយ គឺមានត្រឹមតែស្ត្រីចំណាស់ម្នាក់នៅក្នុងភូមិមកជួយបង្កើតឱ្យប៉ុណ្ណោះ។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមកអង្គការបានកៀរខ្ញុំ និងប្តីទៅដល់ភ្នំមួយ (ខ្ញុំមិនចាំឈ្មោះ)។ ដោយសារតែពេលនោះខ្ញុំកំពុងមានផ្ទៃពោះ ខ្ញុំបានពិភាក្សាជាមួយប្តីនៅតាមផ្លូវថាយើងគួរតែគេចខ្លួនត្រឡប់មកស្រុកកំណើតវិញ។ ពេលនោះប្តីខ្ញុំបានយល់ព្រម ហើយប្តីប្រពន្ធខ្ញុំបានលួចធ្វើដំណើរត្រឡប់មកវិញដោយស្ងាត់ៗ។ ប្តីប្រពន្ធខ្ញុំធ្វើដំណើរដោយថ្មើរជើង និងមានរែកសម្ភារផ្សេងៗរហូតមកដល់វត្តអង្គរុន។ កាលនោះ ប្តីប្រពន្ធខ្ញុំបានបណ្តើរគោចំនួន៥ក្បាលមកជាមួយ។ ប៉ុន្តែដោយសារតែអស់កម្លាំងខ្លាំងពេក ប្តីខ្ញុំបានព្រលែងគោទាំងនោះចោលម្តងមួយក្បាលៗអស់ចំនួន៥ក្បាល។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំមានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំង ព្រោះត្រូវដើររំលងសាកសពជាច្រើនដែលនៅរាយប៉ាយតាមដងផ្លូវ។

ក្រោយរបបខ្មែរក្រហមដួលរលំភ្លាមៗ ខ្ញុំនិងគ្រួសារបានទៅស្នាក់នៅខាងលិចខេត្តកំពត មួយរយៈពេលខ្លី។ លុះដល់សភាពការណ៍ស្ងប់ស្ងាត់ទើបគ្រួសារខ្ញុំនាំគ្នាវិលត្រឡប់មករស់នៅជួបជុំគ្នាក្នុងស្រុកកំណើតវិញ។

រាល់ពេលនឹកឃើញដល់រឿង"រាវក្នុងរបបខ្មែរក្រហម ខ្ញុំនៅតែមានអារម្មណ៍តក់ស្លុត និងភ័យខ្លាចជានិច្ច ព្រោះកាលនោះ ខ្ញុំត្រូវបីបាច់ថែរក្សាកូនតូចៗនិងមានផ្ទៃពោះ។ ខ្ញុំពិតជាចង់ឱ្យក្មេងៗជំនាន់ក្រោយចងចាំ និងយល់ដឹងពីទុក្ខលំបាកក្នុងរបបខ្មែរក្រហម។ កាលពីថ្ងៃមុន មានក្មេងម្នាក់មកនិយាយគួញក្តែរប្រាប់ខ្ញុំថា ពេលដើរគឺហត់ខ្លាំងណាស់។ ខ្ញុំបានរៀបរាប់ប្រាប់ក្មេងនោះវិញ ពីការដែលប្រជាជនរស់នៅក្នុងរបបខ្មែរក្រហមត្រូវធ្វើការហួសកម្លាំង ខ្វះខាតអាហារហូបចុក និងត្រូវធ្វើដំណើរដោយដើងទទេជារៀងរាល់ថ្ងៃពីវាលស្រែទៅផ្ទះ និងពីផ្ទះទៅវាលស្រែ។ ជាក់ស្តែង ខ្ញុំនិងប្តីត្រូវដើរផ្លូវឆ្ងាយខ្លាំងណាស់ គឺដើរតាំងពីភូមិកំណើតរហូតទៅដល់ផ្សារគ្រាំកក់ ស្រុកគ្រាំកក់ ខេត្តតាកែវ។



ផ្លូវលំក្នុងស្រុកគ្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គការបានសម្លាប់ប្រធានភូមិ រួចជម្លៀសប្រជាជនចេញពីភូមិទាំងយប់

សិលា បញ្ញាភុជ

ខ្ញុំឈ្មោះ ម៉ម ម៉ាក់ អាយុ៥៨ឆ្នាំ រស់នៅភូមិស្ពានជ្រៃ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ខ្ញុំមានប្តីឈ្មោះ ទុយ ភ័ន់បានស្លាប់ក្នុងអាយុ៥៨ឆ្នាំ ដោយសារជំងឺហើមក។ ប្តីប្រពន្ធខ្ញុំមានកូនចំនួន៨នាក់ ក្នុងនោះមានកូនស្រីម្នាក់។

នៅក្នុងរបបខ្មែរក្រហម គឺខ្ញុំនៅវ័យក្មេងនៅឡើយ អង្គការមិនបានឱ្យខ្ញុំធ្វើការងារធ្ងន់ធ្ងរក្រៅពីរៀនសូត្របន្តិចបន្តួចជាមួយគ្រូ។ ពេលទំនេរពីការរៀន ខ្ញុំតែងតែទៅជួយធ្វើការងារម្តាយខ្ញុំ។ អង្គការប្រើម្តាយខ្ញុំឱ្យធ្វើការងារជាច្រើន។

មុនពេលខ្មែរក្រហមចូលកាន់កាប់ប្រទេសទាំងស្រុង ខ្ញុំបានបាត់បង់បងប្រុសម្នាក់។ បងប្រុសរបស់ខ្ញុំធ្លាប់បួសជាព្រះសង្ឃ ប៉ុន្តែក្រោយមកគាត់បានសឹកដោយសារធ្លាក់ខ្លួនឈឺ។ បន្ទាប់ពីជាសះស្បើយពីជំងឺ ក្រុមខ្មែរំដោះបានមកហៅគាត់ឱ្យស្ម័គ្រចិត្តធ្វើជាយោធា។ ការនោះម្តាយខ្ញុំបានឃាត់កូនមិនឱ្យទៅចូលរួមជាមួយកម្លាំងបដិវត្តន៍ ព្រោះប្រទេសជាតិជិតបានរំដោះហើយ ប៉ុន្តែនៅតែមិនអាចឃាត់គាត់បាន។ បងប្រុសខ្ញុំបានឡើងជិះរថយន្តជាមួយក្រុមខ្មែរំដោះរួចចាកចេញទៅបាត់សូន្យឈឹងរហូតមកដល់សព្វថ្ងៃ។ មកទល់ពេលនេះ ខ្ញុំគិតថាគាត់ប្រហែលជាស្លាប់បាត់បង់ជីវិតហើយ។

លុះចូលមកដល់របបខ្មែរក្រហម អង្គការប្រមូលទ្រព្យសម្បត្តិ និងរបស់របរប្រជាជនទាំងអស់យកទៅដាក់រួម ឪពុកម្តាយរបស់ខ្ញុំដែលជាមនុស្សស្លូតត្រង់ បានប្រគល់ចានស្លាំងទាំងអស់នៅ



ម៉ម ម៉ាក់ អាយុ៥៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្ពានជ្រៃ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងផ្ទះទៅឱ្យអង្គការ ដើម្បីប្រើប្រាស់ជាសម្បត្តិរួមដោយគ្មានការតវ៉ាឡើយ។ ក្រោយមក ឪពុករបស់ខ្ញុំត្រូវអង្គការដាក់ចូលក្នុងបញ្ជីត្រៀមយកទៅសម្លាប់ដោយគ្មានមូលហេតុជាច្រើនលើកច្រើនសារ។ កងឈ្លបបានមករកចាប់ឪពុកខ្ញុំពីរបីថ្ងៃជាប់ៗគ្នា ប៉ុន្តែពុំដែលជួបឪពុកខ្ញុំនៅផ្ទះឡើយ ព្រោះគាត់តែងតែលួចរត់គេចខ្លួនទាន់ពេលវេលា។ ឪពុកខ្ញុំបានផ្តាំថា បើសិនមានឧរណាមកសួររកគាត់ ត្រូវឆ្លើយតប

ប្រាប់ថាមិនដឹង។ តាំងពីដើមមក ឪពុកខ្ញុំជាមនុស្សមានចំណេះដឹង និងឆ្លាតវៃ ទើបគាត់អាចគេចផុតពីការតាមសម្លាប់របស់កម្មាភិបាលខ្មែរក្រហមបាន។

ក្រោយមក អង្គការបានសម្លាប់ប្រធានភូមិមួយចំនួន ហើយប្រជាជនភាគច្រើនត្រូវបានជម្លៀសទាំងយប់ចេញពីភូមិ ដោយខ្ញុំមិនដឹងពីមូលហេតុពិតប្រាកដនៃហេតុការណ៍នេះឡើយ។ កាលនោះ អ្នកដែលជម្លៀសប្រជាជន គឺជាកម្មាភិបាលក្មេងៗ មានអាយុខ្ចង់១០ឆ្នាំជាង និងមានស្ពាយកាំភ្លើងវែងអូសដី។ កម្មាភិបាលខ្មែរក្រហមមានវ័យក្មេងៗបានស្រែកសម្ដែតប្រជាជនឱ្យទំធ្វើដំណើរស្រួតទៅមុខឱ្យលឿន។ លុះធ្វើដំណើរមកដល់កណ្ដាលវាលស្រែដែលមានដើមពោធិ៍មួយដើម ស្ថិតក្នុងភូមិដើងខាលឃុំម៉ង់រៀវ ស្រុកត្បូងឃ្មុំ ទើបកម្មាភិបាលក្មេងៗទាំងនោះអនុញ្ញាតឱ្យប្រជាជនឈប់សម្រាកបន្តិចសិន ទើបបន្តដំណើរទៅមុខទៀត។ ខ្ញុំបានធ្វើដំណើរអស់រយៈពេលកន្លះខែ ទើបមកដល់ទឹកន្លែងមួយដែលត្រូវឆ្លងទឹក ប៉ុន្តែដោយសារជម្រៅទឹកជ្រៅពេក ហើយក្មេងតូចៗមិនអាចឆ្លងបាន កម្មាភិបាលបានបង្ខំឱ្យអ្នកជម្លៀសទាំងអស់កាប់ឫស្សីដើម្បីធ្វើស្ពានសម្រាប់ឆ្លង។ ក្នុងពេលដែលប្រជាជនកំពុងធ្វើស្ពាន កងទ័ពវៀតណាមបានវាយចូលមកដល់ឈូមហើយបានប្រាប់ឱ្យប្រជាជនវិលត្រឡប់ទៅផ្ទះវិញ។ ពេលនោះ អ្នកដែលមានរទេះគោ បានបររទេះត្រឡប់ទៅផ្ទះវិញភ្លាមៗ ចំណែកគ្រួសារខ្ញុំមានតែអង្រែកវែកអីវ៉ាន់ និងត្រូវធ្វើដំណើរដោយថ្មើរជើង។ ដូច្នេះបន្ទាប់ពីត្រូវបានរំដោះ ក្រុមគ្រួសារខ្ញុំបានស្នាក់នៅភូមិដំរិល ឃុំដំរិល ស្រុកអូររាំងឪរយៈពេលមួយយប់ ទើបបន្តធ្វើដំណើរត្រឡប់មកផ្ទះវិញ។

រាល់ពេលនឹកឃើញដល់បទពិសោធន៍ទាំងនេះ ខ្ញុំមានអារម្មណ៍ស្អប់ខ្ពើមរបបខ្មែរក្រហមខ្លាំងណាស់ ព្រោះជារបបឃោរឃៅព្រៃផ្សៃ និងសម្លាប់មនុស្សដោយគ្មានត្រាប្រណីឡើយ។ ខ្ញុំពិតជាចង់ឱ្យក្មេងៗជំនាន់ក្រោយបានចងចាំរឿងរ៉ាវប្រវត្តិសាស្ត្រដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ ខ្ញុំចង់ឱ្យយុវជនជំនាន់បានដឹងថា ជីដូនជីតារបស់ក្មេងៗទាំងអស់បានឆ្លងកាត់ទុក្ខវេទនាយ៉ាងណា ទម្រាំតែអាចរក្សាជីវិតរស់រាន និងទិតខំពូនជ្រុំឱ្យកូនចៅមានឱកាសបានរៀនសូត្រព្រមទាំងមានជីវភាពធូរធារ និងប្រសើរឡើងដូចសព្វថ្ងៃនេះ។



វាលស្រែនៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សើង សាវ៉ង ៖ ក្តីសង្ឃឹម និងការដឹងគុណ

រស្រេង លីដា



ក្រុមការងារអគារមរតកសង្គមរាស្ត្រនិយម សម្តេចម៉ី-សម្តេចម៉ែ បុរីអូរស្វាយ-សែនជ័យ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង បាននាំយកភួយថ្មីមួយគ្រឿងទៅប្រគល់ជូនលោកតា សើង សាវ៉ង អាយុ៧៣ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៦ ក្រុមការងារអគារមរតកសង្គមរាស្ត្រនិយម សម្តេចម៉ី-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង បាននាំយកភួយថ្មីមួយគ្រឿងទៅប្រគល់ជូន សើង សាវ៉ង អាយុ៧៣ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង ដើម្បីបង្ហាញនូវការដឹងគុណ និងការលើកកម្ពស់សុខុមាលភាពចំពោះចាស់ព្រឹទ្ធាចារ្យដែលជាអ្នកកសាងសហគមន៍ជំនាន់មុនៗ អំណោយមនុស្សធម៌នេះ មិនត្រឹមតែជាមធ្យោបាយសម្រួលដល់ការធ្វើដំណើរប្រចាំថ្ងៃតែប៉ុណ្ណោះទេ ប៉ុន្តែជាការបង្ហាញនូវការយកចិត្តទុកចំពោះលោកតាដែលបានលះបង់ពេញមួយជីវិតលើទឹកដីដាច់ស្រយាលនេះ។

ការកសាងនិគមថ្មនអូរស្វាយ

សើង សាវ៉ង មានស្រុកកំណើតនៅខេត្តកណ្តាល និងមានឪពុកឈ្មោះ សើង ង៉ាង និងម្តាយឈ្មោះ យ៊ុប ភឿង។ សាវ៉ងមានបងប្អូនចំនួន៦នាក់ គឺបង(ស្រីទី១) ឈ្មោះ សើង ធីខេង (ស្លាប់), ទី២) ឈ្មោះ សើង សាវ៉ង, ប្អូនស្រីទី៣) ឈ្មោះ



លោក ស្រេង លីដា ក្រមការងារអគារមរតកសង្គមរស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ បុរីអូរសុាយ-សែនជ័យ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង ជូនសៀវភៅនិងឯកសារប្រវត្តិសាស្ត្រ ដល់លោក សើង សាវ៉ាង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្ទះរបស់លោក សើង សាវ៉ាង នៅភូមិអូរសុាយ ឃុំអូរសុាយ ស្រុកបុរីអូរសុាយ សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សើង សាវ៉ែត, ប្អូនប្រុសទី៨) ឈ្មោះ សើង វ៉ាន់ (ស្លាប់), ប្អូនប្រុសទី៥) ឈ្មោះ សើង សុដល និង ប្អូនស្រីទី៦) ឈ្មោះ សើង សុភា។ ដំណើរជីវិតរបស់ សាវ៉ាង នៅលើទឹកដីអូរសុាយ បានចាប់ផ្តើមឡើងតាំងពីឆ្នាំ១៩៦៣ មកម្ល៉េះ គឺតាំងពីលោកមានអាយុ១១ឆ្នាំ ដែលតំបន់នេះមានព្រៃឈើដុះព័ទ្ធជុំជិត និងសម្បូរជំងឺគ្រុនចាញ់ដែលបណ្តាលឱ្យមនុស្សស្លាប់ជាច្រើន។

នៅឆ្នាំ១៩៦៤ ពេលលោក ម៉ៅ សង្ហែម បានដឹកនាំកងទ័ពប្រមាណ៥០០នាក់មកឈរជើងការពារព្រំដែន និងអភិវឌ្ឍន៍បុរីអូរសុាយ ដោយមានការកសាងបន្ទាយដ្ឋារមទ្វីរពេទ្យ សាលារៀនវត្តអារាម និងបង្កើតវង់តន្ត្រីយោធាការមួយ ពេលនោះ សើង សាវ៉ាង និងក្រុមគ្រួសារ គឺប្រជាពលរដ្ឋដំបូងដែលបានចូលរួមយ៉ាងសកម្មក្នុងសហគមន៍នេះ។ គ្រួសារ សាវ៉ាង បានទទួលដីស្រែទំហំ៥ហិកតា ដីផ្ទះទំហំ ៤០ម៉ែត្រការ៉ែ និងប្រាក់ខបត្តម្ភ ៧៥០រៀលក្នុងមួយខែ ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ សាវ៉ាង បានទទួលក្រណាត់សជាំក់ពាក្យ «សង្គមរស្ត្រនិយម» ដោយដាល់ព្រះហស្តពីសម្តេចព្រះ នរោត្តម សីហនុ ក្នុងដំណើរយាងចុះមកសួរសុខទុក្ខប្រជាជននៅបុរីអូរសុាយ កាលពីឆ្នាំ១៩៦៨។

សង្គ្រាម និងទុក្ខលំបាករលើសុខភាពបន្ទាប់ពីរបបខ្មែរក្រហម

ឆ្ងល់កាត់សម័យសង្គ្រាមទម្លាក់គ្រាប់បែកក្នុងរបប លន់ នល់ បានបង្ខំឱ្យអ្នកភូមិអូរសុាយត្រូវដឹកលេណដ្ឋានរាងអក្សរ «A» ដើម្បីការពារខ្លួនរហូតចូលដល់របបខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ពេលនោះ ខ្មែរក្រហមបានជម្លៀស សាវ៉ាង ទៅធ្វើការនៅក្នុងកងចល័តនៅតំបន់ «អូរនន្ទោង»។ សាវ៉ាង ត្រូវធ្វើការធ្ងន់ធ្ងរ ដូចជា កាប់គាស់ និងរានព្រៃឈើធំៗ ដោយគ្មានអាហារហូបគ្រប់គ្រាន់។ ការស្រេកឃ្លានធ្វើឱ្យលោកតា សាវ៉ាង ប្រថុយជីវិតលួចដីកមើមពោនមើមរកា និងមើមក្តួចយកមកហូបបន្តែម។ សាវ៉ាង បានជាប់បង់បងស្រឹបឆ្កើតឈ្មោះ សើង ធីខេង ដែលត្រូវខ្មែរក្រហមហោកបញ្ជោតថាយកទៅជួសជុលទូក ប៉ុន្តែធាតុពិតគឺយកទៅសម្លាប់ចោល។

ការធ្វើពលកម្មធ្ងន់ធ្ងរតាំងពីនៅក្មេង រួមដូរ

ជាមួយវ័យកាន់តែចាស់ជរា បានបណ្តាលឱ្យសាវ៉ាង មានជំងឺប្រចាំកាយរហូតមកដល់សព្វថ្ងៃ។ សាវ៉ាង ធ្លាប់ឈឺសន្លាក់ក្បាលជង្គង់ និងឈឺចង្កេះយ៉ាងខ្លាំង ធ្វើឱ្យការដើរបស់គាត់លែងមានភាពរហ័សរហួនដូចមុន។ ថ្មីៗនេះ សាវ៉ាង បានជួបខបទ្វារហេតុរអិលដួលបណ្តាលឱ្យប៉ះពាល់ និងរងរបួសត្រង់ដៃ និងស្មាផ្នែកខាងស្តាំបណ្តាលឱ្យគាត់ឈឺចុកចាប់យ៉ាងខ្លាំង។ សាវ៉ាង មានគម្រោងធ្វើដំណើរទៅពិនិត្យនៅមន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង ដើម្បីតាមដានស្ថានភាពរបួសរបស់គាត់ឱ្យបានច្បាស់លាស់។

ការសម្រាលទុក្ខលំបាកតាមរយៈការឱរនេះរុញ


ចំពោះ សាវ៉ាង ឈឺជើង និងស្មាខាងស្តាំ គាត់បានទទួលរនេះរុញមួយគ្រឿង ពីក្រុមការងារអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរសុាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តស្ទឹងត្រែង ដើម្បីជួយសម្រាលទុក្ខលំបាកប្រចាំថ្ងៃរបស់គាត់។ រនេះរុញនេះមិនត្រឹមតែជួយសម្រួលដល់ការចល័តក្នុងផ្ទះតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមធ្យោបាយដ៏សំខាន់សម្រាប់កូនចៅ សាវ៉ាង ប្រើប្រាស់ពេលជូនគាត់ទៅកាន់មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែងនាពេលខាងមុខ។

ទឹកមុខរបស់លោកតា សាវ៉ាង ដែលធ្លាប់តែស្រពោនដោយសារការឈឺចាប់ បានប្រែជាមានសង្ឃឹម និងពោរពេញដោយក្តីរំភើបពេលគាត់បានអង្គុយលើរនេះរុញថ្មី។ សើង សាវ៉ាង បានរៀបរាប់ទាំងអារម្មណ៍ត្កុកត្ករួល ព្រមទាំងបង្ហាញនូវក្តីសង្ឃឹម និងការដឹងគុណយ៉ាងជ្រាលជ្រៅថា៖

«ទូលព្រះបង្គំជាខ្ញុំ សូមថ្វែងអំណរព្រះគុណដ៏ជ្រាលជ្រៅបំផុតថ្វាយចំពោះ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាអម្ចាស់ជីវិតលើត្បូង ដែលព្រះអង្គតែងតែមានព្រះរាជហឫទ័យទុកដាក់ និង ច្រោសប្រណីដល់កូនចៅដែលរស់នៅតំបន់ដាច់ស្រយាលៗ។ កូនចៅដែលបានមករស់នៅអូរសុាយ និងឆ្ងងកាត់សម័យសង្គមរាស្ត្រនិយមរបប លន់ នល់ របបខ្មែរក្រហមរហូតមកដល់បច្ចុប្បន្ន សុទ្ធតែមានវ័យជរា ជាក់កម្លាំង និងមានជំងឺឈឺញាំញី ប៉ុន្តែហួងម៉ែតែងតែគិតគូរដល់សុខទុក្ខ និងសុខភាពរបស់ប្រជានុរាស្ត្រ ជានិច្ច តាមរយៈការខបត្តម្ភសម្ភារប្រើប្រាស់ដ៏មានតម្លៃ ដូចជា រនេះរុញនេះ។ ជាពិសេសហួងម៉ែតែងតែយកព្រះទ័យទុកដាក់ដល់ការអភិវឌ្ឍន៍ក្នុងតំបន់បុរីអូរសុាយ ដោយបានផ្តួចផ្តើមឱ្យមានការកសាង អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ សម្តេចម៉ែ (បុរីអូរសុាយ-សែនជ័យ) ដើម្បីតម្កល់ និងរក្សាទុកនូវឯកសារប្រវត្តិសាស្ត្រសម្បូរបែបសម្រាប់កូនចៅជំនាន់ក្រោយ»។

សិស្សានុសិស្សនៃអនុវិទ្យាល័យអន្លង់វែង ស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

សួត ឥចិត្រ





លោក សួត ឥចិត្រ ចាក់បញ្ចាំងខ្សែភាពយន្តឯកសារទាក់ទងនឹងរបបខ្មែរក្រហមឱ្យសិស្សទស្សនា ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៦ សិស្សានុសិស្សចំនួន៣នាក់ នៃអនុវិទ្យាល័យអន្លង់វែង បានមកស្វែងយល់ រៀនសូត្រពីព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ គោលបំណងរបស់សិស្សានុសិស្ស គឺចង់លើកកម្ពស់ការយល់ដឹងប្រវត្តិសាស្ត្រក្នុងតំបន់អន្លង់វែង ជំរុញការចងចាំដើម្បីឱ្យមានសន្តិភាព និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា។

បុគ្គលិកប្រចាំការិយាល័យនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ឈ្មោះ សួត ឥចិត្រ បានលើកយកព្រឹត្តិការណ៍ដែលធ្លាប់កើតឡើងក្នុងខែកញ្ញា ឆ្នាំ១៩៨៩ គឺកងទ័ពវៀតណាមដកកម្លាំងចេញពីប្រទេសកម្ពុជា។ សិស្សានុសិស្សបានទស្សនាវីដេអូឯកសារ និងប្រភពព័ត៌មានផ្សេងៗទាក់ទងនឹងដំណើរការនៃការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជាក្នុងខែកញ្ញា ឆ្នាំ១៩៨៩, អន្លង់វែងជាទីចុងបញ្ចប់នៃរបបប៉ុលពត និងបន្ទប់គោលស្រុកអន្លង់វែង ដើម្បីឈានទៅដល់ការសិក្សាប្រវត្តិសាស្ត្រមួយដែលតភ្ជាប់ទំនាក់ទំនងរវាងប្រវត្តិសាស្ត្រជាតិ និងទីកន្លែងកំណើតរបស់ខ្លួន។

កងទ័ពវៀតណាមបានចូលក្នុងប្រទេសកម្ពុជាក្រោមការមើលឃើញដោយទស្សនៈផ្សេងៗគ្នា។ ទីមួយ កងទ័ពវៀតណាមចូលមកដើម្បីរំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងទីពីរ គឺជាការឈ្លានពាន។ ប៉ុន្តែសៀវភៅប្រវត្តិ-

សាស្ត្រ«កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» បានលើកឡើងពីហេតុដលដ៏មានសារសំខាន់របស់វៀតណាមក្នុងការលើកកងទ័ពចូលកម្ពុជា ដោយយល់ឃើញថា មកពីខ្មែរក្រហមបានបង្កការគំរាមកំហែងដល់ប្រទេសរបស់ខ្លួន បើទោះបីជាការសម្រេចចិត្តនេះ ធ្វើឡើងអស់រយៈពេលជាយូរក៏ដោយ។ កងទ័ពវៀតណាមបានចូលមកដួលរំលំរបបប្រល័យពូជសាសន៍ខ្មែរក្រហមនិងមានវត្តមាននៅក្នុងទឹកដីកម្ពុជាអស់រយៈពេលជិតមួយទសវត្សរ៍។ រហូតដល់ខែកញ្ញាឆ្នាំ១៩៨៩ កងទ័ពវៀតណាមបានដកកម្លាំងទ័ពចេញពីប្រទេសកម្ពុជា បន្ទាប់ពីបានរុញច្រានកងទ័ពខ្មែរក្រហមឱ្យធ្លាក់ទៅតាមទល់ដែនកម្ពុជា-ថៃ។ ការសម្រេចចិត្តនេះមិនមែនកើតឡើងដោយសារតែមានសម្ពាធនយោបាយ សេដ្ឋកិច្ច និងការប្រែប្រួលនៃភូមិសាស្ត្រនយោបាយជាសកលក្នុងសម័យសង្គ្រាមត្រជាក់។ ការដាក់សម្ពាធ និងទណ្ឌកម្មសេដ្ឋកិច្ចពីសំណាក់សហគមន៍អន្តរជាតិ ព្រមទាំងការទាមទារយ៉ាងទូចពីបណ្តាប្រទេសអាស៊ាន និងចិនបានបង្ខំឱ្យរដ្ឋាភិបាលវៀតណាមដាស់ប្តូរជំហរ និងដកកងទ័ពចេញគឺជាយុទ្ធសាស្ត្រដើម្បីអាចស្តារទំនាក់ទំនង និងសេដ្ឋកិច្ចជាមួយប្រទេសជិតខាង និងបណ្តាប្រទេសលោកខាងលិចឡើងវិញ។

ទោះជាយ៉ាងណា ជម្លោះប្រដាប់អាវុធរវាងភាគីជម្លោះខ្មែរនឹងខ្មែរ នៅតែបន្តអូសបន្លាយអស់រយៈពេលជិតមួយទសវត្សរ៍បន្ថែមទៀត ដែលនេះគឺជារបត់នយោបាយ និងការប្រែប្រួលលើសមរភូមិមួយនៅកម្ពុជា។ នៅពេលនោះ សន្តិភាពហាក់ស្ថិតនៅឆ្ងាយពីក្រសែភ្នែកនៅឡើយ។ ប៉ុន្តែរបត់នេះ គឺជាកត្តាជំរុញឱ្យមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ការបោះឆ្នោតជាតិជាលើកដំបូងរបស់កម្ពុជាក្នុងឆ្នាំ១៩៩៣ និងការធ្វើសមាហរណកម្មខ្មែរក្រហមចុងក្រោយនៅតំបន់អន្លង់វែង ចូលទៅក្នុងរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៨។

សិស្សានុសិស្សបានយកចិត្តទុកដាក់ទស្សនានូវរូបភាពនៃដំណើរការសង្គ្រាម និងគ្រឿងយុទ្ធោបករណ៍ដែលកងទ័ពវៀតណាមបានដឹកចូលក្នុងប្រទេសកម្ពុជា។ ចំណែកឯទិដ្ឋភាពមួយផ្សេងទៀតគឺការបែកបាក់ផ្ទៃក្នុងខ្មែរក្រហមដែលឈានទៅដល់ការចាប់ខ្លួនប៉ុល ពត និងការកាត់ទោសចំពោះមុខប្រជាជននៅស្រុកអន្លង់វែង។ សិស្សានុសិស្សបានគិតអំពីទំនាក់ទំនងគ្នារវាងយាយតារបស់ខ្លួនដែលធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមរហូតរសាត់ខ្លួនមកដល់អន្លង់វែងមកទល់សព្វថ្ងៃ។ បន្ថែមលើសពីនេះ សិស្សានុសិស្សអាចយល់ដឹងបន្ថែមថា ទឹកន្លែងកំណើត និងប្រទេសរបស់ខ្លួន មិនមែនទើបតែមានជម្លោះជាមួយប្រទេសថៃប៉ុណ្ណោះទេ ប៉ុន្តែធ្លាប់ឆ្លងកាត់សង្គ្រាមដ៏វែងអន្លាយអស់រយៈពេលជាច្រើនដំនាន់មកហើយ។ ដូច្នេះក្នុងនាមជាយុវជន ត្រូវខិតខំសិក្សារៀនសូត្រ ដើម្បីឱ្យក្លាយជាធនធានមនុស្សសម្រាប់អភិវឌ្ឍន៍សហគមន៍ និងប្រទេសជាតិរបស់ខ្លួននាថ្ងៃអនាគត។



លោក សួត វិចិត្រ ចែកឯកសារទាក់ទងនឹងប្រវត្តិសាស្ត្ររបបខ្មែរក្រហមឱ្យសិស្សអាន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សអានឯកសារទាក់ទងនឹងប្រវត្តិសាស្ត្ររបបខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ មកសិក្សាស្វែងយល់អំពីការបែងចែកភូមិសាស្ត្ររដ្ឋបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ថុន ស្រីរតនៈ







សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ មកសិក្សាស្វែងយល់អំពីការបែងចែកភូមិសាស្ត្ររដ្ឋបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៦ នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង លោក ដេង ពង្សវ៉ាសុី បានធ្វើបទបង្ហាញ និងពិភាក្សាអំពីមេរៀនទាក់ទងភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ដែលមាននៅក្នុងជំពូកទី៦ នៃសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សានុសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ក្រុងព្រៃវែង។

មុនដំបូង សិស្សានុសិស្សត្រូវបានណែនាំឱ្យស្វែងយល់ពីផ្ទាំងរូបថតពិព័រណ៍អចិន្ត្រៃយ៍ដែលដាក់តាំងបង្ហាញនៅក្នុងបរិវេណការិយាល័យនិងឯកសារមួយចំនួនទៀតដែលតម្កល់នៅក្នុងការិយាល័យ។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានចាប់ផ្តើមធ្វើបទបង្ហាញ និងពិភាក្សាអំពីមេរៀនប្រវត្តិសាស្ត្រខ្មែរក្រហមជាមួយសិស្សានុសិស្សរួមជាមួយសំណួរស្នាបស្ទង់ចំណេះដឹងរបស់សិស្សានុសិស្សទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម។

បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានលើកយកជំពូកទី៦ នៃសៀវភៅប្រវត្តិ-

សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មកបង្ហាញដល់សិស្សានុសិស្សក្នុងគោលបំណងផ្តល់ចំណេះដឹងបន្ថែមទៀតអំពីការបែងចែកភូមិសាស្ត្ររដ្ឋបាល នៅក្នុងរបបខ្មែរក្រហម។ មុននឹងចូលដល់ខ្លឹមសារសំខាន់ ក្រុមការងារបានសួរសំណួរទៅកាន់សិស្សានុសិស្សថា តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រទេសកម្ពុជាបានបែងចែកជាប៉ុន្មានភូមិភាគ ដើម្បីឱ្យសិស្សានុសិស្សឆ្លើយ។

តមកទៀត ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានបែងចែកសិស្សានុសិស្សទាំង៨នាក់ទៅជាពីរក្រុម។ ដោយក្រុមនីមួយៗ ទទួលបន្ទុកអានជំពូកនៃមេរៀនរួចឆ្លើយនឹងសំណួរមួយចំនួន ដែលក្រុមការងារបានដាក់ឱ្យឆ្លើយ។ ក្រុមទី១) មានសិស្សឈ្មោះ ខាត់ សុខខេង និងអ្នកស្រីកែវ ដែលទទួលសំណួរចំនួន៥ គឺ១) តើភូមិភាគដែលត្រូវបានបង្កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានចំនួនប៉ុន្មាន? ២) តើភូមិភាគទាំងអស់នោះត្រូវបានបែងចែកជាប៉ុន្មានតំបន់? ៣) តើលេខភូមិភាគបូព៌ាពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨មានឈ្មោះអ្វី? ៤) តើលេខភូមិភាគនិរតីមានឈ្មោះអ្វី? ៥) តើលេខភូមិភាគខត្តរពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៦មានឈ្មោះអ្វី? ចំណែកក្រុមទី២ មានសិស្សឈ្មោះ រ៉ុម បញ្ញារាជ និង រុន ការម្យ ត្រូវឆ្លើយសំណួរចំនួនចំនួន៥ គឺ១) តើលេខភូមិភាគខត្តរពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៦មានឈ្មោះអ្វី? ២) តើលេខភូមិភាគខត្តរពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ មានឈ្មោះអ្វី? ៣) តើលេខភូមិភាគពាយ័ព្យជានរណា? ៤) តើលេខភូមិភាគបស្ចិមជានរណា? ៥) តើលេខភូមិភាគឦសានពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៦ មានឈ្មោះអ្វី?

ក្នុងពេលអាន និងកត់ត្រាចម្លើយ សិស្សខ្លះបានសួរសំណួរទាក់ទងពាក្យពិបាក ឬពាក្យគន្លឹះដែលខ្លួនពុំទាន់យល់ច្បាស់ដូចជា៖ ពាក្យ អត្តឃាត, សហករណ៍, ភូមិភាគ, សូយ៉ត និង ស្រុកព្រៃប្រសព្វ។ ក្រុមទាំងពីរមានរយៈពេល២០នាទីដើម្បីអានមេរៀន និងឆ្លើយសំណួរ។ បន្ទាប់មក សិស្សទាំងពីរក្រុម ឡើងធ្វើបទបង្ហាញពីលទ្ធផលដែលក្រុមរបស់ខ្លួនបានធ្វើ។ រាល់ចម្លើយរបស់ក្រុមនីមួយៗដែលបានធ្វើបទបង្ហាញ គឺត្រឹមត្រូវទាំងអស់តាមមេរៀនដែលសិស្សបានអាន។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានបង្ហាញដែនទីភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យបោះពុម្ពឆ្នាំ១៩៧៦ ដល់សិស្ស ដើម្បីស្វែងយល់បន្ថែមពីអ្វីដែលបានកើតឡើង។

នៅចុងបញ្ចប់នៃការបទបង្ហាញគឺជាការពិភាក្សាពីសំណួរទូទៅអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលសិស្សទាំងអស់នៅមានចម្ងល់ក្នុងចិត្តតាំងពីយូរមកហើយ។ សិស្សានុសិស្សបានសួរសំណួរមួយចំនួនទៅកាន់លោក ដេង ពង្រ៉ាសុី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដើម្បីឱ្យជួយស្រាយចម្ងល់ មានដូចជា៖ ១) តើលេខភូមិភាគរូបណាដែលមានអំណាចឬមានតួនាទីធំជាងគេ? ២) ហេតុអ្វីបានជា សោ ភីម ធ្វើអត្តឃាត? ៣) ហេតុអ្វីបានជាមានការចាប់ខ្លួនមនុស្សយកទៅដាក់គុកទួលស្លែង និងស្លាប់នៅទីនោះ? ៤) នៅពេលដែលប្រជាជនឈឺ ហេតុអ្វីបានជាត្រូវបង្ខំឱ្យទៅធ្វើការទៀត? ៥) តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានការបោះពុម្ពប្រាក់ដែរឬទេ? ប្រសិនបើបោះពុម្ព តើប្រាក់ទាំងនោះត្រូវបានប្រើប្រាស់សម្រាប់ធ្វើអ្វី? ៦) តើខេត្តព្រៃវែងត្រូវបានរំដោះនៅថ្ងៃខែឆ្នាំណា? ជាចុងក្រោយគឺសិស្សានុសិស្សបានបង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

ខ្ញុំឈ្មោះ **អូន ស្រីកែវ** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ថ្មីនៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ នៅពេលដែលខ្ញុំបានមកសិក្សាមេរៀនទាក់ទងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃនេះ ធ្វើឱ្យខ្ញុំទទួលបានចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដឹងពីរបៀបមើលដែនទី។

ខ្ញុំឈ្មោះ **ខាត់ សុខេង** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ថ្មីនៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ បន្ទាប់ពីខ្ញុំបានចូលរួមពិភាក្សាមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃនេះ ធ្វើឱ្យខ្ញុំស្គាល់ពីភូមិ

សាស្ត្ររដ្ឋបាលរបស់ខ្មែរក្រហមតាមរយៈការមើលដែនទី ដូច្នេះខ្ញុំចង់ឱ្យមានកម្មវិធីពិភាក្សាទាក់ទងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យម្តងទៀត។

ខ្ញុំឈ្មោះ **រ៉ុម បញ្ញារាជ** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ថ្មី នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ ខ្ញុំបានស្គាល់ឈ្មោះថ្នាក់ដឹកនាំសំខាន់ៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានគ្រប់គ្រងភូមិភាគនានា។ ខ្ញុំសប្បាយរីករាយ និងចង់ឱ្យមានកម្មវិធីសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមបន្តទៀត ដើម្បីឱ្យយុវជននិងក្មេងៗជំនាន់ក្រោយបានស្គាល់ និងយល់ដឹងអំពីប្រវត្តិសាស្ត្រនេះ។

ខ្ញុំឈ្មោះ **រុន ការម្យ** អាយុ១៩ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ថ្មី នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ ខ្ញុំបានស្គាល់អំពីភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ព្រមទាំងស្គាល់មេដឹកនាំខ្មែរក្រហម ដូចជា ប៉ុល ពត និងលេខាភូមិភាគផ្សេងទៀត។ ខ្ញុំសប្បាយរីករាយណាស់ដែលបានមកសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តព្រៃវែង។






សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ មកសិក្សាស្វែងយល់អំពីការបែងចែកភូមិសាស្ត្ររដ្ឋបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


ការិយាល័យព័ត៌មានសាធារណៈ











«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានច្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្ធឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើដែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានដលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងទូរសព្ទបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។


ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨:០០ ដល់ម៉ោង ១២:០០ និងពេលរសៀលពីម៉ោង ២:០០ ដល់ ម៉ោង ៥:០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្រប


សម្រួលតាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ


អ៊ីម៉ែល៖ truthsampeou.r@dccam.org


សូមអរគុណ!











ជាតិនេះ ខ្ញុំប៉ិះតែនឹងស្លាប់ចំនួន១៤លើក (ត)

សៀវ សុផុន



កាតសិស្សរបស់ សៀវ សុផុន ពេលរៀននៅអនុវិទ្យាល័យ ឆ្នាំ១៩៧២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដំបូលព្រះបរមរាជវាំងនៅជិតបង្អើយ។ ក្រោយពេលមកដល់ត្រើយខាងលិច និងទូទាត់ថ្លៃឈ្នួលទូកចម្ងាយដល់ម្ចាស់ទូករួចរាល់ យើងទាំងបួននាក់ដើរជុំគ្នាឆ្ពោះទៅម្តុំតឹ ឡូម៉ែត្រលេខ៦ ភ្នងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ក្រាន់តែយើងដើរទៅមុខបានបន្តិច ស្តិតនៅខាងស្តាំដៃយើងឃើញមានសាកសពគាចិនម្នាក់ ស្លៀកពាក់ខោអាវ ភីសង្ហាម៉ាដែលកូនចៅទុកចោលនៅប្របង្អួរដើរដោយមានសតូស្រមោចមួយៗរោមភ្នែករបស់សាកសព។ លុះយើងដើរទៅមុខបានបន្តិចទៀតទើបជួបមនុស្សរាប់រយនាក់កំពុងសម្រុកចូលទៅភ្នងឃ្លាំងសេដ្ឋកិច្ចមួយ ប៉ុន្តែខ្ញុំមិនឃើញរបស់របរអ្វីទេព្រោះជាឃ្លាំងប្រេងសណ្តែក។ ខ្ញុំឮស្នូរគ្រាប់កាំភ្លើងដៃចំនួនបីគ្រាប់បន្ទាប់មកឃើញមនុស្សផ្លើលរត់ចេញមកក្រៅវិញ។ ខ្ញុំមនុស្សប្រុសពីរនាក់ ទទឹកប្រេងសណ្តែកដោតគាំងពីសក់ក្បាលរហូតដល់ជើងដោយពុំដឹងមូលហេតុ។ ខណៈនោះបួនជាបានរត់ទៅមុខដងនិងសើចដង ព្រោះឃើញអ្នកទាំងពីរនាក់នោះឈរស្ទើមទ្រីងនិងឈ្លោកមើលខោអាវរបស់ខ្លួនដែលប្រឡាក់ដោយប្រេងឆាដោកជាំ បីដូចជាមុជចូលទៅភ្នងអាងប្រេងសណ្តែក។ ខ្ញុំគិតក្នងចិត្តថា ទីនេះគឺជាសមរភូមិការបំចាក់ និងដណ្តើមគ្នាដូច្នេះខ្ញុំត្រូវតែឱ្យក្លាហាន និងមុតស្រួចដូចពាក្យឪពុករបស់ខ្ញុំតែងដួលជាទីវ៉ាទ ថា ចូលដ្យារ កាំបិតយើងត្រូវតែមុតជានិច្ច។ ប្រជាជនបាននាំគ្នាមកទីនេះកាន់តែច្រើនព្រោះមានឃ្លាំងអីវ៉ាន់ច្រើននិងស្តិតនៅក្បែរកំពង់ដែភ្នំពេញ។ ឃ្លាំងស្តុកអង្ករត្រូវប្រជាជនចូលយកអស់មុនហើយ ដូច្នេះគឺនៅសល់តែឃ្លាំងទំនិញផ្សេងទៀតដើម្បីយកមកចម្អែតក្រពះ។ នៅពេលយើងឃ្លានបាយ ទើបដឹងពីការធ្វេសប្រហែសរបស់យើងដែលមើលស្រាលចំពោះរឿងនេះ។ យើងនាំគ្នាដើរចូល ដុះប្រក់សីង្គ័សីមួយកន្លែងដែលសង់ជាប់នឹងមាត់ទន្លេគឺដុះមួយកំណាត់ខាងមុខ សង់កើយលើមាត់ច្រាំង និងមួយកំណាត់ខាងក្រោយបានសង់លយចូលទៅលើដងទន្លេ។ នៅទីនេះពុំមានរបស់អ្វីដើម្បីអាចហូបចុកបានទេ ប៉ុន្តែនៅរានហាលខាងក្រោយដុះ យើងបានឃើញស្បែកជ្រូកសម្បុរខ្មៅមួយក្បាលបះភេមប្រាន់ឡើងលើ និងភាយក្លិនមិនល្អមកតិចៗ ព្រោះមានមនុស្សចូលមកវះយកសាច់ទៅអស់ហើយ។ លុះដើរយើងដើរចូលទៅភ្នងបន្ទប់មួយខ្ញុំបានឃើញទូដែកមួយគ្រឿងមានកំពស់ត្រឹមស្មាមនុស្សធំដែតទុកចោលក្បែរជញ្ជាំងដុះ។ យើងទាំងបួននាក់បានដួលទូដែករួចហើយអូសយកមកកណ្តាលដុះដើម្បីវាយបំបែក ក្រែងលោកមានវត្ថុមានតម្លៃសម្រាប់ធ្វើការដោះដូរយកអង្ករដែលយើងរកពុំបានសោះ។ បន្តិចក្រោយមក ស្រាប់តែមានមនុស្សមួយក្រុមទៀតមានភ្នាក់ចំនួនបីនាក់បានដើរចូលមកសហការជាមួយយើងដើម្បីវាយបំបែកទូដែកនេះចោល។ ដំបូងគឺយើងសាកល្បងវាយថតតូចខាងលើសិន ហើយនៅទីបំផុតយើងអាចបំបែកបានដោយមានបន្ទះដែកបីបួនសន្លាត់ប៉ុន្តែខាងក្នងតែពុំមានអ្វីបន្តិចសោះ។ បន្ទាប់មកយើងត្រូវប្តូរវេនគ្នាទាំង៧នាក់វាយបំបែកថតធំខាងក្រោមទៀត។ យើងវាយទូដែករហូតអស់កម្លាំងគ្រប់គ្នាទើបអាចបំបែកថតធំខាងក្រោមនេះបានជោគជ័យ ប៉ុន្តែជាលទ្ធផលគ្មានអ្វីឡើយ។ ដោយហត់ហៀខ្លាំងពេកយើងបាននាំគ្នាដេកហើយបន្តិចក្រោយមកយុវជនម្នាក់ក្នង

ចំណោមក្រុមបីនាក់ បានក្រោកឡើងទាំងទោមនស្ស សុះទៅទាញយកដងញញួរទៅត្រវែងចូលក្នុងទឹកទន្លេ។ បន្ទាប់មកបងប្រុសម្នាក់ទៀតក្នុងក្រុមដដែលនោះ ដែលមានពុកមាត់ដូចតួកុនឥណ្ឌា បានឆើបឈរឡើង ហើយនិយាយខ្លាំងៗថា ពួកយើងកុំអស់សង្ឃឹមភាពជោគជ័យគឺកំពុងរង់ចាំយើងនៅខាងមុខ។ បន្ទាប់មក យើងទាំង៨នាក់បានដើរទៅកាន់កន្លែងផ្សេងទៀត។ ដោយសារមេឃក្តៅខ្លាំង បងវែងបានដោះអាវយកមកទទូរនៅលើក្បាលព្រោះពេលនោះគឺមានមនុស្សតិចបំផុតដែលមានមួកពាក់។ យើងបានដើរចូលទៅក្នុងឃ្លាំងមួយ ស្តិតនៅក្បែរមាត់ទន្លេ និងរាយបំបែកតែសឈើអស់ចំនួនបី។ យើងយកបានការម៉ែលទាហានសំប៉ែតៗម៉ាក់USA មានស្រោបក្រដាសវែងប្រវែណ៌លឿង។ យើងយកការម៉ែលមកចងព្យួរយេងរយោងនៅជុំវិញចង្កើនក្នុងម្នាក់ៗពី៨ទៅ៩ការម៉ែល។ ថ្ងៃនោះដោយសារអាកាសធាតុក្តៅ ខ្ញុំស្រេកទឹកយ៉ាងខ្លាំង ហើយបានប្រាប់អ្នកនៅក្រុមឱ្យជូនដំណើរខ្ញុំទៅដឹកទឹកទន្លេនៅឯមាត់កំពង់។ ប្រាំងទន្លេនៅទីនោះមានសភាពចោតខ្លាំងណាស់។ ខ្ញុំដើរចុះទៅមាត់ទឹកដែលស្តិតនៅឆ្ងាយ ព្រោះរដូវប្រាំងទឹកស្រកអស់ច្រើន។ ពេលនោះច្របុះខ្ញុំជុំកិនចម្អែក ជះមកកាន់តែខ្លាំង លុះខ្ញុំក្រឡេកភ្នែកមើលនៅក្បែរនោះ ស្រាប់តែឃើញសាកសពទាហានប៉ាវ៉ាចំនួនពីរនាក់ហើមឡើងប្រេះអាវ អណ្តែតផ្តាប់មុខលាយឡំគ្នាជាមួយដើមកំឈេក។ ពេលខ្ញុំឡើងមកវិញ អ្នកនៅក្នុងក្រុមទាំងអស់ដែលឈរង់ចាំនៅលើមាត់ប្រាំងបានស្រែកសួរថា ដូន ឯងប្រញាប់ឡើងមកម៉្លេះ ម្តេចមិនដឹកទឹកនោះទៅ។ ខ្ញុំស្រែកតបវិញតាមហេតុការណ៍ដែលខ្ញុំឃើញ ប៉ុន្តែបងវែង បានលើកដៃបង្ហួលទៅមុខ និងស្រែកប្រាប់ខ្ញុំថា នៅខាងមុខមិនមានកំពង់ទូកទេដូន ឯងត្រូវតែដឹកទឹកនោះទៅ។ ខ្ញុំបានដាច់ចិត្តឡើងទៅលើក្បាលទូកមួយ ហើយយកដៃទាំងពីរក្បាំទឹកដឹកទាំងអត់ហ៊ានដកដង្ហើមដើម្បីកុំឱ្យធំក្លិន និងបិទភ្នែកទាំងពីរហូតដល់ឆ្អែត។

លុះយើងដើរត្រឡប់វិញបានស្រួយបន្តិច យើងបានចូលទៅក្នុងឃ្លាំងមួយទៀតដែលមានសុទ្ធតែមេអ្នា សាគូតម្រៀបជាជួររាប់រយពាន់ការុង។ យើងបានលើមេអ្នាសាគូម្នាក់មួយការុង និងរៀបចំដើរចេញព្រោះថ្ងៃរសៀលណាស់ទៅហើយ។ ស្របពេលនោះ ស្រាប់មានស្នូរគ្រាប់កាំភ្លើងដៃ៨ទៅ៩គ្រាប់បាញ់ជាប់ៗគ្នា ព្រមទាំងឮសំឡេងយោធាខ្មែរក្រហមម្នាក់ស្រែកសន្ធប់ឱ្យចាកចេញជាប្រញាប់។ យើងបានលើការុងមេអ្នាសាគូរត់បកក្រោយ ដោយគ្មានសំចៃកម្លាំងឡើយ។ យើងទាំងបួននាក់មិនមានទូកឆ្លងទៅត្រើយម្ខាងឡើយ ដូច្នេះយើងនាំគ្នាយកធុងសាំងចំនួន២មកចងផ្ដោបជាប់គ្នាធ្វើជាកូនទូកនិងយកស័ង្កសីមួយសន្ទឹកទៀត ត្របពីលើមេអ្នាសាគូបួនការុងចៀសវាងកុំឱ្យត្រូវទឹកភ្លៀង ព្រោះមេឃខ្មៅខ្លាំងណាស់។ យើងទាំងអស់ហែលរុញធុងសាំងក្នុងមួយជ្រុងម្នាក់សំដៅទៅត្រើយខាងកើតដែលមានចម្ងាយជិតមួយគីឡូម៉ែត្រ។ បន្តិចក្រោយមកភ្លៀងធ្លាក់មកខ្លោកៗ គ្រាប់ធំៗព្រមទាំងមានខ្យល់បក់មកយ៉ាងខ្លាំងពីទិសនិរតីស្រាប់តែភ្លាមៗនោះ ខ្ញុំបានឮសំឡេងដាំង ទ្រហឹងស្ទើរធ្លាយក្រដាសត្រចៀក។ ខ្ញុំស្មានតែខ្មែរក្រហមបាញ់គ្រាប់បេ-៤០ ដើម្បីបំបែកកូនយើងចោលប៉ុន្តែពេលសម្លឹងមើលទៅខាងលើមេឃគឺពុំឃើញអ្វីឡើយ។ ដោយទឹកទន្លេហូរខ្លាំងពេកបានបណ្តាលឱ្យយើងគ្រប់គ្នាលើកដៃលើកដើងហែលស្ទើរមិនចង់រួច។ យើងហៀបតែនឹងលិចចូលក្នុងទឹកទើបខ្ញុំខំប្រឹងស្រែកប្រាប់អ្នកផ្សេងទៀតឱ្យដោះអាវ និងស្រាតខោវែងចេញឱ្យអស់យកដាក់នៅលើកូនគឺឱ្យទុកតែខោខ្លីតែប៉ុណ្ណោះ ដើម្បីឱ្យស្រាលខ្លួន។ យើងបានមកដល់ត្រើយខាងកើតទន្លេ និងបានជញ្ជួនអីវ៉ាន់ដាក់លើច្រាំង ចំណែកកូនបានអណ្តែតតាមខ្សែទឹកឆ្ពោះទៅមុខព្រះបរមរាជវាំង។ ក្រោយពីយើងនាំគ្នាចុះមុជទឹកជម្រះរាងកាយរួចហើយ យើងក៏ឡើងលើមាត់ច្រាំងវិញ ស្រាប់តែចោរបានលួចទ្រនាប់ដើងថ្មីរបស់ខ្ញុំបាត់។ ស្បែកដើងរបស់ខ្ញុំទើបតែទិញនៅផ្សារអូ ម្ភាពិចនៅប៉ុន្មានថ្ងៃមុនខ្មែរក្រហមចូលក្រុងភ្នំពេញតែប៉ុណ្ណោះ។

យើងបានលីការុងមេអ្នាសាគូនៅលើស្មាម្នាក់មួយការុង។ ដើររួមគ្នាជាមួយអ្នកជម្លៀសប្រមាណជា៥ទៅ៦នាក់ទៀត។ ខ្ញុំដើរបានប្រហែលជា៣០០ម៉ែត្រ ស្រាប់តែបាតដើងខ្ញុំមាន ចាប់ផ្តើមឈឺខ្លាំងឡើង។ ដោយសារពងបែក និងដើរមិនបានលឿន បណ្តាលឱ្យអ្នកនៅក្នុងក្រុមរង់ចាំជាញឹកញាប់។ ខ្ញុំដើរបានមួយសន្ទុះ បាតដើងរបស់ខ្ញុំម្ខាងទៀតឡើងពងបែកបន្តទៀត។ យើងដើរកន្លែងមួយក៏ឃើញផ្លូវបំបែក ប៉ុន្តែយើងដើរនៅមុខត្រង់។ ដោយសារមេអ្នាសាគូនៅលើស្មាកាន់តែធ្ងន់ទៅ។ ខ្ញុំបានចាក់មេអ្នាសាគូខ្លះចោលនៅតាមផ្លូវជាញឹកញាប់ និងស្រាយការម៉ែលពីចង្កើនចោះចោលម្តងមួយ។ ហើយចុងក្រោយនៅសល់ការម៉ែល ពីរប៉ុណ្ណោះ។ ផ្លូវដែលយើងដើរ គឺកាត់ចំបុរាសណ្តែកទ្រើង និងឃើញមានរបងធាងគ្នោតបញ្ឈរខ្ទីៗកម្ពស់ត្រឹមក្បាលជង្គង់សម្រាប់យើងដើរកន្ត្រងចេញចូលបាន។ នៅពេលដែលខ្ញុំលើកដើងម្ខាងឆ្លងរបងគឿនោះភ្លាម ស្រាប់តែខ្ញុំភ្ញាក់ក្រញាង និងច្រឡោតទៅមុខបិះតែនឹងដួល ព្រោះនៅក្រោមដើងរបស់ខ្ញុំ គឺមានខ្មោចមនុស្សប្រុសម្នាក់កំបុតក្បាលបាត់ដេកផ្ងារស្តុកស្តឹងប្របនឹងដើងរបង។ លុះដើរមកមុខបន្តិច ខ្ញុំបានធុំក្លិនស្អុយអសោចៗ ខ្ញុំក្រឡេកមកក្រោមផ្ទះស្បូវចាំចម្ការនៅខាងឆ្នេងដៃ ស្រាប់តែឃើញសាកសពស្ត្រីម្នាក់ដេកស្ងាប់ផ្ងារពោះជង្អាង។ នៅលើត្រែ ហើយដើមទ្រូងរបស់គាត់

ទាំងសងខាងបានហើមប្រេះដាច់ឡើងអាវ ចំណែកសក់ក្បាលធ្លាក់ពីលើត្រែចុះមកក្រោមជិតដល់ដី។ ពេលដែលខ្ញុំក្រឡេកមើលម្តងទៀត ស្រាប់តែឃើញសពមនុស្សប្រុសពីរនាក់បានស្លាប់លើដីនៅក្បែរផ្ទះនោះដែរ ដោយសាកសពមួយស្តិតនៅខាងមុខផ្ទះ និងសាកសពមួយទៀតនៅខាងលិចផ្ទះ។ ខ្ញុំដើរនៅក្នុងចម្ការនោះមិនទាន់ផុតផង ក៏ឃើញអ្នកនៅក្នុងក្រមទាំងបីនាក់នៅឈររង់ចាំដណ្តើរខ្ញុំ។ បងវែងយកដៃម្ខាងច្រតទប់ខ្លួនទីងើចម្រើងទ្រើសសណ្តែកហើយប្អូនប្រុសឈ្មោះ ជា និងឈ្មោះ ឌី បានបក់ដៃហៅខ្ញុំឱ្យស្រួតដណ្តើរឱ្យលឿន។ ទោះបីពេញមួយថ្ងៃយើងដឹកតែទឹក ក៏យើងពុំហ៊ានលួចបេះសណ្តែកគួរហូបដែរព្រោះធំភ្ញាក់ស្តួយសាកសព។ ពេលយើងដើរចេញពីចម្ការបានបន្តិចមក យើងឃើញផ្ទះស្បូវតូចមួយសង់ខ្ពស់ពីដីដើរផុតក្បាលនៅខាងឆ្វេងដៃ និងឃើញម្ចាស់ផ្ទះប្តីប្រពន្ធពីរនាក់អង្គុយនៅមាត់ទ្វារ និងបានបក់ដៃហៅយើងឱ្យចូលដឹកទឹកដោយរាក់ទាក់បំផុតមួយ។ លុះចូលទៅដល់ជិតជណ្តើរផ្ទះ បុរសជាប្តីបានកាន់ដឹងទឹកមួយចុះមកដល់ដី និងហុចមកឱ្យយើងដឹក។ ចំណែកឯប្រពន្ធដែលអង្គុយខាងលើផ្ទះបានសួរមកយើងថា នៅពេលដើរចូលក្នុងចម្ការអម្បាញ់មិញ តើបងៗមានឃើញអ្វីប្លែកដែរឬទេ? យើងឆ្លើយតបប្រាប់ទៅគាត់វិញតាមហេតុការណ៍ដែលយើងឃើញដោយផ្ទាល់ភ្នែក។ បន្ទាប់មកស្ត្រីម្ចាស់ផ្ទះបាននិយាយប្រាប់យើងថា ជនរងគ្រោះទាំងបួនរូបនោះត្រូវបានយោធាខ្មែរក្រហមចាំបម្ការជាញឹកញាប់ចោលថ្មីៗ ហើយអ្នកដណ្តើរទាំងអស់មិនហ៊ានដើរលើផ្លូវនោះជិតពីរថ្ងៃមកហើយ។ ស្ត្រីម្ចាស់ផ្ទះនិយាយផុតពីមាត់ ស្រាប់តែមានឮហ្វូងបើកដំបូលមួយគ្រឿងបើកចេញពីព្រៃខាងកើតផ្លូវមកដល់ជិតចម្ការក៏ឈប់រថយន្តហើយពេទីម៉ាស៊ីនឮសូរង៉ោង! ង៉ោង! ង៉ោង! ហាក់បីដូចអ្នកបើកបរនោះស្រវឹងស្រាជោគជាំ។ យើងទាំងអស់គ្នាបានក្រឡេកមើលទៅកាន់រថយន្តនោះ និងឃើញយោធាខ្មែរក្រហមឈរប្រជ្រៀតគ្នាលើរថយន្តហើយខ្លះឈរដាក់ជើងម្ខាងចេញក្រៅរថយន្ត។ ភ្លាមៗនោះ ស្ត្រីម្ចាស់ផ្ទះបានបើកភ្នែកធំៗសម្លឹងមើលយើងពីលើផ្ទះ និងនិយាយតិចៗប្រាប់យើងថា អ្នកទាំងបួនពិតជាមានសំណាងណាស់ បើនៅយឺតតែបន្តិចទៀតប្អាស់ជាត្រូវយោធាខ្មែរក្រហមទាំងនេះ បាញ់សម្លាប់ដូចសាកសពក្នុងចម្ការនោះដែរហើយ។ ដោយភិតភ័យខ្លាំងពេកយើងបានសុំលាប្តីប្រពន្ធម្ចាស់ផ្ទះ ហើយខ្ញុំបានស្រាយយកការម៉ែលពីចង្កេះ ជូនដល់គាត់ទាំងពីរនាក់ទុកជាអនុស្សាវរីយ៍ ដូច្នេះខ្ញុំនៅសល់ការម៉ែលមួយតែប៉ុណ្ណោះ ចង់ជាប់នឹងចង្កេះ។ យើងនាំគ្នាបន្តដំណើរទៅមុខទៀត ព្រោះជិតដល់គោលដៅហើយ។ នៅពេលព្រលប់ៗយើងបានដើរមកដល់ដើមខ្នុរដែលដុះជាគុម្ព តំបាកន្លែងដែលយើងឈរផ្តក់ដៃគ្នា ទាំងបួននាក់កាលពីព្រលឹមព្រឹកមិញមុនចេញដំណើរដោយសច្ចាថាក្នុងថ្ងៃនេះ ទោះយ៉ាងណាក៏យើងដើរជុំគ្នាជានិច្ច។ លុះដល់ទីបំផុតយើងទាំង៨នាក់បានមកដល់កន្លែងដើមវិញដូចការសន្យាគ្នាមែនហើយចាប់ពីពេលនោះមក ខ្ញុំបានបែកពីពួកគាត់រហូតលង់លុះឥឡូវ។

រលឹកទី៨ លួចរត់រលឹកទី៣ ដោយចេញពីក្នុងសហករណ៍មួយ (ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៥)

រត់លើកទី១ គឺក្រោយពីប្តូរជីវិតចូលទៅរុករកស្បៀងពេញមួយថ្ងៃនៅទីក្រុងភ្នំពេញ លុះស្កែកឡើងខ្ញុំបានពន្យល់ប្រាប់ខ្ញុំថា យើងត្រូវតែលួចចេញពីទីនេះទៅស្រុកកំណើតឯខេត្តសៀមរាបរបស់យើងវិញ។ បើយើងរស់នៅទីនេះបន្តទៀត គឺគ្មានស្បៀងហូបចុកឡើយ មា៉ាងទៀតបើយើងចេញទៅមុនគេមានមនុស្សតិចងាយក្នុងការរកអង្ករត្រីសាច់បរិភោគ។ នៅពេលរត់ចេញពីចម្ការល្មុត នៅម្តុំជ្រោយអំពិលដែលមានមនុស្សណែនណាន់គាន់តាប់ខ្ញុំពុកខ្ញុំបានឱ្យមេភ្លាសាគូកន្ទុះការុងទៅអ្នកជិតខាងដែលដេកក្រោមដើមល្មុតដូចគ្នា ម្នាក់បន្តិចៗហូតអស់។ យើងនៅសល់តែការម៉ែលសំបែតមួយតែប៉ុណ្ណោះ។ ព្រឹកនោះយើងស្តាយកាបូបដើរចេញជាធម្មតា ដោយគ្រាន់តែភ្លែចប្រាប់អ្នកជិតខាងថាដូរកន្លែងទៅសម្រាកនៅខាងមុខនេះបន្តិច ព្រោះម្តាយមីងបង្កើតរបស់ខ្ញុំម្នាក់គាត់ស្នាក់នៅទីនោះស្រាប់។

រត់លើកទី២ គឺកៀសខ្លួនចេញពីវត្តគ្នោត ស្តិតនៅទល់មុខនឹងដងទន្លេតូចមួយ ក្នុងខេត្តកំពង់ចាម ដែលខ្ញុំពុំបានចាំកាលបរិច្ឆេទ។ ក្រោយពីអង្គការកុហកភូតភរនៅទីបំផុតខ្ញុំពីរនាក់ឪពុកត្រូវបានខ្មែរក្រហមក្លង់ឱ្យឡើងជិះការណ្តតធំមួយគ្រឿងមានដំបូលពីរជាន់ជាមួយនឹងមនុស្សយ៉ាងច្រើនដោយបើកបរបញ្ជ្រាសទឹកហូរក្នុងដងទន្លេមេគង្គ ប្រមាណពីរយប់ពីរថ្ងៃ។ យប់ទីមួយគឺយើងដេកនៅលើការណ្តតជាន់ខាងលើ។ ហើយជាន់ខាងលើនេះហើយដែលត្រូវបានគេលួចស្រាយក្រមាត្បាញពីសូត្រដ៏ថ្លៃសន្ធរបស់ខ្ញុំមួយពីស្មាលខោអាវខាងលើ យកទៅជាតំ។ នៅយប់ទី២ ម៉ោងប្រហែលជា ១០យប់ មានក្មួនរនេះមួយក្រមបានមកដឹកពួកយើងយកចេញពីការណ្តត ហើយនៅមុនពេលឡើងជិះរនេះ គេមានបាយកញ្ចប់ស្លឹកចេកត្រៀមសម្រាប់ឱ្យយើងទទួលទានបានយ៉ាងហ៊ាមៗទៀត។ មុខព្រួញនេះគឺចំណាងជម្ងៀសយើងយកទៅកាន់កន្លែងដ៏សែនឆ្ងាយមួយ តែលុះដល់ជិតភ្លឺអ្នកបររនេះបរចូលក្នុងវត្តគ្នោត ដែលគ្មានព្រះសង្ឃគង់នៅមួយអង្គសោះ ទម្លាក់ឱ្យយើងសម្រាកនៅទីនេះសិន។ នៅក្នុងវត្ត ខ្ញុំពុំបានសម្រាកនៅជាមួយហ្វូងមនុស្សច្រើនកុះករនោះឡើយ គឺបានទៅរកកន្លែងកៀនកោះដើម្បីលាក់ខ្លួនពួនអាត្មា ទើបល្អជាជាង

នៅគ្នាច្រើនៗ យប់បន្ទាប់មកឪពុកខ្ញុំបានចាត់ចែង ដឹកដៃខ្ញុំរត់ចេញពីវត្ត ដោយជួលស្ត្រីខ្មែរអ៊ុំស្ទាមពីរនាក់កូនប្រុសតូចមួយទៀតឱ្យអ៊ុំទុកចម្ងាំនៅការ៉ែយម្ភាងវិញ ហើយដាន់រត់របស់យើងទាំងពីរនាក់ឪកូនគឺអង្គការពុំអាចរកឃើញទេ ព្រោះត្រូវបានលិចកប់ចូលជ្រៅទៅក្នុងបាតទន្លេអស់ហើយ។

ក្រោយពីបានកប់ប្រសពូជាមួយម្នាលអង្គការករ (ខ្មែរក្រហម) មកពេលណាម្ដែ្ងៗឆាប់តែនឹងចាញ់ការកុហកបោកបញ្ឆោតរបស់ពួកគេពុំសូវជាទំនេរនៅថ្ងៃណាមួយឡើយ។ នៅលើកនេះទៀតគឺក្រោយពីអង្គការអាវខ្មៅបោកក្បូចហើយទើបឪពុកខ្ញុំគាត់រុករកឃើញថា បើអង្គការកាត់ផ្លូវឱ្យចុះប្រវត្តិរូប ត្រូវឆ្លើយកុហកតបវិញទើបសុក្រិត្យ ព្រោះបើឆ្លើយត្រង់ថានៅឆ្ងាយ រហូតដល់ខេត្តសៀមរាបដូចលើកនេះទៀតនោះ ច្បាស់ជាត្រូវបានជាប់អន្ទាក់អង្គការជាពុំខាន។ ដូចជានៅកាល:ទេស:នេះក្តី ការឆ្លើយត្រង់របស់យើង គឺត្រូវបានគេចុះឈ្មោះឱ្យរស់នៅភូមិដ្ឋោង សង្កាត់ស្រែឡៅ ស្រុកបាវាយណ៍ ខេត្តកំពង់ធំ ដែលស្ថិតនៅតាមដងផ្លូវជាតិលេខ៦ គឺនៅខុះតែមួយគីឡូម៉ែត្រទៅមុខទៀត នឹងដល់ភូមិរំលង។ ដោយយើងមានលេខក្រមឈ្មោះពួកបានត្រឹមត្រូវហើយនោះអង្គការចាត់តាំងឱ្យឪពុកខ្ញុំទៅដាំដំឡូងមីជាមួយអ្នកភូមិជារៀងរាល់ថ្ងៃពុំសូវទំនេរឡើយ។ ម៉្យាងដែរអភ័ព្វខ្លួនតែទទួលបានដំឡូងតបមកវិញ ព្រោះដើរអត់មានស្បែកជើងពាក់ មានថ្ងៃមួយខ្ញុំត្រូវមុតចំកែងជើងស្តាំ និងបន្ទាដើមអញ្ចាញ បាក់ចុងកប់ជ្រៅយកចេញវិញពុំបាន គឺត្រូវខ្ទិនដើរកាន់តែឈឺច្រត់រហូតមក។ សហ-ករណ៍នេះ អង្គការមិនប្រើខ្ញុំទេ គ្រាន់តែឱ្យជួយជាន់អង្គរដោយជើងម្ខាងម្ខាងឯង ជាមួយម្ចាស់ផ្ទះស្រីឈ្មោះ ជី ទុកគ្រាន់តែសម្រាប់បរិភោគនៅក្នុងផ្ទះយើងតែប៉ុណ្ណោះ។ ភាគច្រើនគឺទំនេរខ្ញុំតែងចេញទៅអង្គុយលេង នៅក្រោមដើមអំពិលធំមួយដើម ក្បែរមាត់ថ្នល់ជាតិ ដើម្បីសម្លឹងមើលអ្នកជម្លៀសពីភ្នំពេញ ដែលដើរមកត្រែងបានជួបម្ដាយមីងឈ្មោះ សៀវ លឿម ដែលត្រូវជាបួនស្រីពៅរបស់ឪពុកខ្ញុំ ខ្លាចត្រែងគាត់ចេញមកជាមួយនឹងអ្នកស្រុកឯទៀត។ គាប់ជួនជាថ្ងៃមួយត្រូវបានជួបមេខ្មែរក្រហមម្នាក់ជិះម៉ូតូ ហុងដាសេអិល ឧបកងការពារម្នាក់មានស្ពាយកាំភ្លើងអាកា-៤៧ មួយដើមបានឆៀងចូលមកឈប់ ក្រោមម្លប់ដើមអំពិលធំព្រោះថ្ងៃក្តៅខ្លាំងណាស់។ គឺពេលនោះហើយដែលខ្ញុំចាប់ចងពាក្យសម្ដីរបស់ខ្មែរក្រហមរូបនោះបានច្បាស់ថា បើយើងមិនរត់ទេ គឺគេឱ្យយើងធ្វើស្រែនៅទីនេះរហូតដល់ថ្ងៃស្លាប់ជាពុំខានឡើយ។ ព្រលប់ៗឡើងនៅពេលលោកឪពុកត្រឡប់មកពីដាំដំឡូងឈើវិញ ខ្ញុំបានជម្រាបកិច្ចការសម្ងាត់នេះជូនដល់គាត់ និងផ្តល់ជាអនុសាសន៍មួយបន្តែមទៀតថា ខ្ញុំសុខចិត្តចំណាយនាឡិកាដៃ ៣ដួ.៩៩៩ រត់ចេញទៅប្រកបដោយសុវត្ថិភាព។ ឪពុកខ្ញុំបាននិយាយដោយការប្រុងប្រយ័ត្នជាមួយម្ចាស់ផ្ទះ ដល់ពេលត្រូវរ៉ូវគ្នាជាមួយម្ចាស់ផ្ទះប្រុសឈ្មោះ សៀង (កើតឆ្នាំមមី ១៩២៩) ហើយខ្ញុំយកនាឡិកាដៃទៅសួរប្រធានក្រុមឈ្មោះ ហាំង ដែលរស់នៅភ្នំងផ្ទះស្ត្រីតូចមួយ នាមុខផ្ទះដែលយើងរស់នៅ។ ពួកគាត់ទាំងពីរនាក់បានយកលេសឆ្កេជាបរររនេះក្របីចុះទៅនេសាទត្រីឆ្ងាយនៅឯវាលក្រោមទាំងពីរនាក់ គឺបើកចំហរផ្តល់ឱកាសឱ្យយើងរត់។

នាថ្ងៃពុធទី៧ ខែឧសភា ឆ្នាំ១៩៧៥ ជិតភ្លឺមុននឹងរត់ចេញមក ខ្ញុំបានបត់ខោអាវសិស្សមួយសម្រាប់ ដាក់នៅលើកន្ទេលដំណេក ទុកជាសតុណ ជូនដល់ម្ចាស់ផ្ទះ។ លុះដល់ក្រោយពីចូលនិវត្តន៍ពីការងារជាមន្ត្រីរាជការនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ ខ្ញុំបានធ្វើដំណើរទៅភ្នំពេញ និងឆៀងចូលលេងលោកពូ សៀង នៅភូមិដ្ឋោង បានបន្តិច គឺពេលនោះពូមានអាយុ៨២ឆ្នាំ ហើយប្រពន្ធគាត់ឈ្មោះ ជី និងកូនប្រុសម្នាក់សម្បុរស ជ្រេះឈ្មោះ សុខ មានដុះដុំពកពីកំណើតមកមួយដុំលើខ្នងច្រមុះនោះ ត្រូវបានទទួលអនិច្ចកម្មទាំងពីរនាក់ម្ដាយអស់ហើយ។ ដើមអំពិលធំមួយដើមដែលស្ថិតនៅក្បែរថ្នល់ជាតិនោះ ត្រូវបានរដ្ឋបាលភូមិឃុំកាប់ចោលក្នុងពេលពង្រីកផ្លូវឱ្យធំជាងមុន។ រីឯប្រធានក្រុមឈ្មោះ ហាំង បានដាស់ប្តូរលំនៅឋានដោយចូលទៅរស់នៅក្នុងក្រុងកំពង់ធំនៅក្រោយឆ្នាំ ១៩៧៩។ ពូ សៀង គាត់និយាយប្រាប់ថា ក្រោយពេលដែលខ្ញុំពីរនាក់លោកឪពុករត់ចេញផុតពីភូមិមក ត្រូវបានគេយកមនុស្សថ្មីមួយគ្រួសារឱ្យទៅរស់នៅលើផ្ទះគាត់ដូចមុនទៀត។ ក្រោយមកមនុស្សទាំងអស់ក្នុងមួយគ្រួសារនេះត្រូវអង្គការយកទៅសម្លាប់ចោលអស់ហើយចុងក្រោយគាត់បានលើកសរសើរខ្ញុំថា ក្មួយប្រុសមានភ័ព្វសំណាងល្អណាស់ គឺបានរួចរស់ជីវិត ដូចបានកើតម្ដងទៀត។

លើកទី៩ លួចធើលអង្គការចងស្លាបសេកមនុស្ស ចោះជាក់លើច្បាន នៅឆ្នាំ១៩៧៥

ជុំវិញការរត់លូនរបស់ខ្ញុំ ពីរបីសារកន្ទុងមកនេះ គឺព្រោះតែនឹកស្រុកកំណើតនិងជាពិសេសគឺនឹកអ្នកម្ដាយបងស្រីនិងប្អូនស្រីៗ ព្រមទាំងក្មួយប្រុសម្នាក់យ៉ាងខ្លាំង ហើយពុំបានគិតអ៊ីឱ្យបានសុីជម្រៅលើសពីនេះទៀតឡើយ។ គឺគ្រាន់តែដឹងដោយឃើញច្បាស់ នឹងភ្នែកថា ទាហានខ្មែរក្រហម គឺកាចសាហាវ និងឃោរឃៅខ្លាំង ទើបគ្រប់ភ្នាក្ងីភ្នែកដឹងថារបបខ្មែរក្រហម គឺជារបបតិរច្ឆាន ឬរបបសម្លាប់មនុស្ស ដែលយុវជនប្រុសស្រីទៅមើលរំលង។ ក្រោយពេលដែលខ្ញុំបានមកជួបម្ដាយវិញនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៥ នៅក្នុងភូមិដ្ឋល់តាសិត ឃុំគោកធ្លកក្រោម ស្រុកជីក្រែង


(តទៅលេខក្រោយ)

រូបក្រុមខ្ទះ

អ៊ូ សាខន អាយុ៦៨ឆ្នាំ រស់នៅឃុំមេសថូក ស្រុកចន្ទ្រា ខេត្តស្វាយរៀង បានផ្តល់បទសម្ភាសន៍ទាក់ទងរឿងរ៉ាវឆ្នងកាត់របបខ្មែរក្រហម និងសុខភាពរបស់គាត់ជ្រាប់ដល់ ជា រដ្ឋា អ្នកស្ម័ត្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្រុបក្រោយ ៖

សេក សាម៉ែត អាយុ៦៨ឆ្នាំ រស់នៅភូមិសាលារៀន ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង បានផ្តល់បទសម្ភាសន៍ទាក់ទងរឿងរ៉ាវឆ្នងកាត់របបខ្មែរក្រហម និងសុខភាពរបស់គាត់ជ្រាប់ដល់ ពេជ សានអ្នកស្ម័ត្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 321, September 2026

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.